## ២. កំណែទំរង់អាជ្ញាធរខេត្ត

សៀមរាបមានលក្ខណៈខុសពីខេត្តដទៃទៀតត្រង់ថា សៀមរាបពឹងអាស្រ័យជាសំខាន់ទៅលើវិស័យទេសចរណ៍ និងសេដ្ឋកិច្ចក្រុង ហើយខេត្តដទៃទៀតពឹងផ្អែកភាគច្រើនលើតំបន់ជនបទ។ អាស្រ័យហេតុនេះ មានវិធីច្រើនយ៉ាងដើម្បីពង្រឹងការគ្រប់គ្រងការអភិវឌ្ឍន៍ក្នុងខេត្តសៀមរាប។ នៅក្នុងរយៈពេលវែង ការប្រែក្លាយខេត្តឱ្យទៅជា "ក្រុង"មួយអាចជាជំរើសមួយ។ នៅក្នុងរយៈពេលមធ្យម គេត្រូវចាប់ផ្តើមដោយការពង្រឹង និងកំណែទំរង់រចនាសម្ព័ន្ធដែលមានស្រាប់ដោយយកចិត្តទុកដាក់ទៅលើតួនាទីរបស់ខេត្តលើគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុង។ និន្នាការបច្ចុប្បន្នលើកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការក៏មាន លក្ខណៈប្រហាក់ប្រហែលនេះដែរ។

មូលហេតុដែលត្រូវយកចិត្តទុកដាក់ទៅលើរចនាសម្ព័ន្ធបច្ចុប្បន្នមាន :

១. រចនាសម្ព័ន្ធបច្ចុប្បន្ននៃអាជ្ញាធរមូលដ្ឋានគួរធ្វើឱ្យមានលក្ខណៈសាមញ្ញបំផុតតាមដែលអាចធ្វើទៅបានយ៉ាងហោចណាស់ ធ្វើឱ្យជោគជ័យនូវរដ្ឋបាលឯកភាពនៅថ្នាក់ខេត្ត

២. ចំនួនតួនាទីនៅថ្នាក់ខេត្ត/ស្រុកគួរបន្ថយឱ្យដល់កំរិតអប្បបរមា ដោយសារតែកង្វះធនធានមនុស្សដែលមានសមត្ថភាពនៅក្នុងខេត្តសៀមរាប

៣. ក្រុងសៀមរាប/អង្គរពឹងផ្អែកទៅលើតំបន់ផ្សេងៗទៀតក្នុងខេត្ត លើវិស័យធនធានទឹក ដី កំលាំងពលកម្ម និងលទ្ធភាពធ្វើដំណើរចេញចូល។ មានតែអាជ្ញាធរខេត្តប៉ុណ្ណោះដែលអាចពិនិត្យមើលលើវិស័យទាំងនោះបាន។

ដូចនេះ ទី១ : កំណែទំរង់រចនាសម្ព័នរបស់អាជ្ញាធរខេត្តគួរយកចិត្តទុកដាក់លើការលុបបំបាត់តួនាទីត្រួតគ្នានៅក្នុងអាជ្ញាធរ។ ទី២ : កំណែទំរង់គួរយកចិត្តទុកដាក់លើការងារគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុង និងគួរតែមានលក្ខណៈស្របគ្នាទៅនឹងកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានពីរដំណាក់កាលដូចខាងក្រោម :

**ដំណាក់កាលទី១ :** មុនពេលអនុវត្តច្បាប់អង្គការនៅថ្នាក់ខេត្ត (២០០៦-២០០៩)

- ការបង្កើតគណៈកម្មការអភិវឌ្ឍន៍សំរាប់រដ្ឋបាលឯកភាព និងធានាឱ្យបានតម្លាភាព
- ការបង្កើតមូលនិធិអភិវឌ្ឍន៍ខេត្តសៀមរាប ដើម្បីធានាឱ្យមានថវិកាផ្ទាល់របស់ខេត្តសំរាប់ផលប្រយោជន៍ជាក់លាក់របស់សាធារណៈ
- បង្កើតអង្គភាពពិសេស ឬអភិបាលខេត្តរងទទួលបន្ទុកគោលនយោបាយ/ការគ្រប់គ្រងក្រុង

**ដំណាក់កាលទី២ :** បន្ទាប់ពីការអនុវត្តច្បាប់អង្គការនៅថ្នាក់ខេត្ត (២០១០-២០២០)

- លុបបំបាត់ការកំណត់ចំនួនថវិកាសំរាប់គំរោងអភិវឌ្ឍន៍ដោយអភិបាលខេត្ត (ដែលបច្ចុប្បន្នមានចំនួន២លានដុល្លារ)
- បង្កើតក្រុមប្រឹក្សាខេត្តដើម្បីធានាតម្លាភាព និងគណនេយ្យភាព
- បែកចែកឱ្យដាច់នូវសាខាអំណាចទាំង៣ ពោលគឺ នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការនៅថ្នាក់ខេត្ត

## ៣. ការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងអាជ្ញាធរខេត្ត

ដើម្បីអនុវត្តយុទ្ធសាស្ត្រ ក និង ខ ចាំបាច់ត្រូវពង្រឹងសមត្ថភាពមន្ត្រីរដ្ឋអំណាចមូលដ្ឋានលើការគ្រប់គ្រង និងត្រួតពិនិត្យការងារសាធារណៈ។ អនុសាសន៍នៃកម្មវិធីកសាងសមត្ថភាពសំរាប់មន្ត្រីថ្នាក់ខេត្ត នៅក្នុងរយៈពេលខ្លីមាននៅក្នុង

តារាង២១។

តារាង ២១ : អនុសាសន៍សំរាប់កម្មវិធីកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត

| សេវាសាធារណៈដែលរំពឹងទុក | អនុសាសន៍ស្តីពីកម្មវិធីពង្រឹងសមត្ថភាព | ក្រុមគោលដៅសំរាប់ពង្រឹងសមត្ថភាព |
|---|---|---|
| ១. ធ្វើផែនការមេសំរាប់ក្រុង និងផែនការគំរោងនានា | ធ្វើផែនការគំរោងដោយផ្អែកលើផែនការមេ | • អភិបាលខេត្ត និងប្រធានមន្ទីរខេត្ត |
| ២. អនុវត្ត និងគ្រប់គ្រងការងារសាធារណៈ (គំរោង) | • វិធីសាស្ត្រគ្រប់គ្រងគំរោង និងត្រួតពិនិត្យ គំរោង<br>• ការវាយតំលៃគំរោង | • មន្ត្រីគ្រប់គ្រងការងារសាធារណៈក្នុងខេត្ត<br>• មន្ត្រីទាំងអស់នៅតាមមន្ទីរខេត្ត |
| | • វិធីដោះស្រាយទំនាស់ដីធ្លី | • មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកខាងការគ្រប់គ្រងដីធ្លី ផែនការនិងអភិវឌ្ឍន៍ និងវិនិយោគ<br>• មន្ត្រីមន្ទីរខេត្តខាងការគ្រប់គ្រងដីធ្លី នគរូបនីយកម្ម សំណង់ និងកម្មសិទ្ធិដីធ្លី |
| ៣. ការងាររដ្ឋបាល | • រៀបចំមូលដ្ឋានទិន្នន័យសំរាប់មន្ត្រីរដ្ឋអំណាចថ្នាក់ខេត្ត និងមន្ត្រីតាមមន្ទីរ<br>• មូលដ្ឋានទិន្នន័យស្ថិតិសំរាប់ ការវិនិយោគ និងនីតិវិធីរបស់វា<br>• ចុះបញ្ជីសហគ្រិនដោយកុំព្យូទ័រ | • មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកខាង ការគ្រប់គ្រងដីធ្លី ផែនការ និងការអភិវឌ្ឍន៍ និងការវិនិយោគ<br>• មន្ត្រីមន្ទីរខេត្តខាងការគ្រប់គ្រងដីធ្លី នគរូបនីយកម្ម សំណង់ និងកម្មសិទ្ធិដីធ្លី |
| ៤. ផ្នែកហិរញ្ញវត្ថុ | • ជំនាញបច្ចេកទេសសំរាប់គ្រប់គ្រងថវិកាដោយកុំព្យូទ័រ | • មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ខេត្ត<br>• មន្ត្រីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត |
| ៥. ជំនាញមូលដ្ឋានគ្រឹះសំរាប់ការងាររដ្ឋបាល | • ការគ្រប់គ្រង និងវិភាគទិន្នន័យ<br>• ការវិភាគស្ថិតិ<br>• ជំនាញកុំព្យូទ័រ (ថែរក្សា និងប្រើប្រាស់)<br>• ភាសាអង់គ្លេស<br>• រៀបចំឯកសារ | • មន្ត្រីរដ្ឋអំណាចថ្នាក់ខេត្តទាំងអស់<br>• មន្ត្រីតាមមន្ទីរខេត្តទាំងអស់ |
| ៦. ការផ្សព្វផ្សាយពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ | • ការយល់ដឹងពីច្បាប់អង្គការ<br>• រៀបចំប្រព័ន្ធក្រុមប្រឹក្សា<br>• រៀបចំការបោះឆ្នោត<br>• ការយល់ដឹងពីកំណែទំរង់ហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធ | • មន្ត្រីរដ្ឋអំណាចថ្នាក់ខេត្តទាំងអស់<br>• មន្ត្រីតាមមន្ទីរខេត្តទាំងអស់ |

## ៤. ការបង្កើត និងការអនុវត្តន៍ច្បាប់ និងបទដ្ឋានច្បាប់

ដើម្បីធ្វើឱ្យសំរេចយុទ្ធសាស្ត្រ ក និង ង ចាំបាច់គេត្រូវបង្កើតច្បាប់ និងក្រឹត្យច្បាប់បន្ថែម និងបញ្ចូលក្រឹត្យច្បាប់ដែលមានខ្លឹមសារត្រួតគ្នាទាក់ទងនឹងការងាររដ្ឋបាលមូលដ្ឋាន។ ជាពិសេស រដ្ឋាភិបាលថ្នាក់កណ្តាលគួរចាត់វិធានការដូចខាង

ក្រោមឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

**១) សមាហរណកម្មសិទ្ធិលើការរៀបចំផែនការប្រើប្រាស់ដីធ្លី**

តួនាទីក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីគួរចែករំលែករវាងមន្ទីររៀបចំដែនដី មន្ត្រីស្រុកសៀមរាប និងអាជ្ញាធរអប្សរា ។ ការងាររៀបចំផែនការប្រើប្រាស់ដីធ្លីនេះគួរតែចែងឱ្យបានច្បាស់ថាតើស្ថាប័ននីមួយៗទទួលខុសត្រូវលើអ្វីខ្លះ ។

**២) អនុម័តច្បាប់សំខាន់ៗដែលទាក់ទងរដ្ឋបាលមូលដ្ឋាន**

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ដោយរួមបញ្ចូលទាំងសិទ្ធិក្នុងការប្រើប្រាស់ទឹក និងច្បាប់ទេសចរណ៍មិនទាន់បានអនុម័តនៅឡើយ បើទោះជាពង្រាងច្បាប់ទាំងនេះត្រូវបានដាក់ជូនរដ្ឋសភាហើយកក្តី ។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកមិនទាន់បានអនុម័តដោយសភាជាតិនៅឡើយ ដោយហេតុថានីតិវិធីមានការយឺតយ៉ាវ ។ ចំណែកឯច្បាប់ទេសចរណ៍វិញត្រូវបានគេនិយាយថា ច្បាប់នេះត្រូវតែធ្វើឱ្យស៊ីសង្វាក់នឹងច្បាប់ និងបទបញ្ញាផ្សេងៗទៀត ទោះបីជានាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើខ្លឹមសារតាំងពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ហើយក៏ដោយ ។ នីតិវិធីនៃការអនុម័ច្បាប់នេះត្រូវតែធ្វើឱ្យបានលឿន ។

**៣) ភាពចាំបាច់នៃការបង្កើតច្បាប់ផ្សេងៗទៀតដែលទាក់ទងនឹងរដ្ឋបាលមូលដ្ឋាន**

ទោះបីជាច្បាប់ និងក្រឹត្យច្បាប់ត្រូវបានអនុម័តហើយក៏ដោយ គេសង្កេតឃើញបញ្ហានានា ដែលទាក់ទងនឹងការបកស្រាយមិនគ្រប់គ្រាន់ ការអនុវត្តន៍មិនបានត្រឹមត្រូវ និងការត្រួតគ្នា ។ ទោះបីជាក្រសួងនីមួយៗមានតួនាទីរៀបចំក្រឹត្យ ច្បាប់ និងអនុក្រឹត្យក៏ដោយ ក៏ពុំមានស្ថាប័នណាមួយទទួលខុសត្រូវក្នុងការរៀបចំ និងសំរបសំរួលក្រឹត្យ និងអនុក្រឹត្យជារួមទេ ។ ដើម្បីកែលំអ ស្ថានភាពបែបនេះ ក្របខ័ណ្ឌច្បាប់ ច្បាប់ និងបទដ្ឋានច្បាប់នីមួយៗនឹងត្រូវរៀបចំឡើងឱ្យមានលក្ខណៈឯកភាពគ្នាដោយស្ថាប័នទទួលខុសត្រូវមួយ ។

## ៧.២ ការផ្តល់ហិរញ្ញវត្ថុមូលដ្ឋាន

ហិរញ្ញវត្ថុមូលដ្ឋានត្រូវតែពង្រឹង ។ ខេត្តសៀមរាបមានហេតុផលយ៉ាងពិសេសក្នុងការពង្រឹងមូលដ្ឋានហិរញ្ញវត្ថុរបស់ខ្លួន ។ ទីមួយ : មូលដ្ឋានហិរញ្ញវត្ថុខ្លាំង គឺមានទំនាក់ទំនងគ្នាទៅវិញទៅមកទៅនឹងកំណើនសេដ្ឋកិច្ចដែលបានមកពីភ្ញៀវទេសចរ ។ ទីពីរ : ចំណែកមួយនៃផលទុនដែលបានមកពីការដម្លើងថ្លៃដីគួរតែរក្សាទុកសំរាប់ការប្រើប្រាស់ជាផលប្រយោជន៍រួមនៅក្នុងមូលដ្ឋាន ។ ចុងក្រោយ គំរោងដែលផ្តល់ថវិកាដោយអន្តរជាតិជាច្រើនប្រមូលផ្តុំនៅខេត្តសៀមរាប តែពួកគេមិនបានផ្តល់ថវិកាគ្រប់គ្រាន់សំរាប់សេវាថែទាំទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពស្រស់បំព្រង និងបរិស្ថានល្អជាទូទៅអាស្រ័យលើការថែទាំ ហើយទាមទារឱ្យមានការវិនិយោគតិចតួចប៉ុណ្ណោះ ដូចជាការវិនិយោគដែលធ្វើឡើងដោយភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ។

### ៧.២.១ បញ្ហា

បញ្ហាសំខាន់ៗដែលទាក់ទងនឹងហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្តសៀមរាបត្រូវបានសង្ខេបដូចខាងក្រោម ។

**១. ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់**

ធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរខេត្តសៀមរាបមានមិនគ្រប់គ្រាន់ទេ ដោយសារហេតុផលសំខាន់ៗដូចខាងក្រោម :

- ពន្ធសំខាន់ៗដូចជាពន្ធប្រាក់ចំណេញត្រូវប្រគល់ឱ្យទៅរដ្ឋាភិបាលថ្នាក់ជាតិ ហើយពន្ធភាគច្រើនដែលខេត្តទទួលបានជាពន្ធដែលមានប្រាក់បន្តិចបន្តួចប៉ុណ្ណោះ
- កិច្ចខិតខំប្រមូលពន្ធនៅមានកំរិតទាបនៅឡើយ
- ថ្វីបើរដ្ឋាភិបាលថ្នាក់ជាតិមានតួនាទីផ្តល់ប្រាក់ឧត្តម្ភទៅឱ្យខេត្តនីមួយៗ តែប្រាក់សំរាប់ខេត្តសៀមរាបមិនគ្រប់គ្រាន់ទេ
- ទោះបីជាប្រាក់ដែលភ្ញៀវទេសចរបង់ដើម្បីចូលទស្សនារមណីយដ្ឋានអង្គរកាន់តែមានចំនួនច្រើនឡើងជារៀងរាល់ឆ្នាំក៏ដោយ ក៏ប្រាក់ទាំងអស់នោះមិនដែលត្រូវបានគេបង្វិលឱ្យទៅរដ្ឋអំណាចខេត្តឡើយ

## ២. ការធ្វើផែនការថវិកាមិនបានគ្រប់គ្រាន់ និងការប្រើប្រាស់ថវិកាគ្មានប្រសិទ្ធភាព

ថវិកាដែលមានបន្តិចបន្តួចហាក់ដូចជាមិនត្រូវបានបែងចែក និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាព។ ប្រព័ន្ធនៃការគ្រប់គ្រង ដោយរដ្ឋាភិបាលត្រូវបានកាត់ជាកំណាត់ៗដោយការបំពេញការងារត្រូវធ្វើតាមរយៈខ្សែទទឹង ហើយសកម្មភាពសំរបសំរួលខ្សែបណ្តោយនៅថ្នាក់ខេត្តជួបការលំបាកជាច្រើន។ គំរោងវិនិយោគនានាត្រូវបានរៀបចំដោយរដ្ឋាភិបាលថ្នាក់ជាតិលើកលែងតែករណីមួយចំនួននៅក្នុងកម្មវិធីសិលាប៉ុណ្ណោះ។ ដូចនេះ ពុំមាននរណាម្នាក់នៅក្នុងខេត្តដឹងច្បាស់លាស់អំពីសកម្មភាពនានាដែលកំពុងតែកើតមាននៅក្នុងខេត្តនោះទេ។ សភាពបែបនេះធ្វើឱ្យមានការលំបាកក្នុងការបែងចែកថវិកាដែលមានបន្តិចបន្តួចឱ្យមានប្រសិទ្ធភាពដល់គំរោងដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ខេត្តណាស់។

ការប្រើប្រាស់ថវិកាមិនបានទាន់ពេល និងមិនរលូន។ ការបែងចែកថវិកាត្រូវធ្វើឡើងដោយផ្អែកលើការដាក់ពាក្យសុំដែលត្រូវត្រួតពិនិត្យដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាទូទៅ គេត្រូវការហត្ថលេខាជាច្រើននៅដំណាក់កាលខុសៗគ្នាដើម្បីបើកប្រាក់។ ការងារលទ្ធកម្មក៏ត្រូវការសំណុំឯកសារជាច្រើនដែរ។ ជាទូទៅ ការបើកសាច់ប្រាក់តែងតែមានការយឺតយ៉ាវ។

## ៣. កង្វះធនធានមនុស្ស

ធនធានមនុស្សនៅខេត្តក៏មានមិនគ្រប់គ្រាន់ដែរ។ ឧទាហរណ៍ មន្ត្រីនៅមន្ទីរហិរញ្ញវត្ថុខេត្តសៀមរាបបានទទួលស្គាល់ថា ពួកគេពុំមានចំណេះដឹងគ្រប់គ្រាន់លើបញ្ហាសារពើពន្ធទេ។ លើសពីនេះទៀត ដោយហេតុថា ពួកគេបានធ្វើការជាច្រើនឆ្នាំមកហើយ នៅក្នុងប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ ពួកគេហាក់បីដូចជាតែងតែរង់ចាំការណែនាំពីរដ្ឋាភិបាលថ្នាក់ជាតិដើម្បីបំពេញការងារ។

ធនធានមនុស្សមិនអាចត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពបានឡើយ បើគ្មានព័ត៌មាន និងសម្ភារៈទ្រទ្រង់គ្រប់គ្រាន់។ ជាងនេះទៀត ពុំមានធនធានមនុស្សគ្រប់គ្រាន់នៅឡើយ។ ឧទាហរណ៍ ពុំមានម៉ាស៊ីនកុំព្យូទ័រគ្រប់គ្រាន់សំរាប់ការប្រើប្រាស់នៅឡើយ ។ ម្យ៉ាងទៀត នៅពេលមានម៉ាស៊ីនហើយ ពុំមានមន្ត្រីច្រើនឡើយដែលបានប្រើប្រាស់ម៉ាស៊ីនទាំងនោះ។ ជាលទ្ធផល មូលដ្ឋានទិន្នន័យទៅតាមវិស័យជាច្រើនមិនត្រូវបានគេបង្កើតឡើងឡើយ។

## ៤. កង្វះតម្លាភាព

មានព័ត៌មានសារពើពន្ធរដ្ឋបន្តិចបន្តួចប៉ុណ្ណោះដែលផ្សព្វផ្សាយដល់អ្នករស់នៅក្នុងមូលដ្ឋាន និងភ្ញៀវទេសចរ។ ឯកសារហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្ត អន្តរមន្ទីរ (ចំណែកថវិកាខេត្តដែលបានមកពីថវិកាជាតិ) និងអាជ្ញាធរអប្សរាមិនបាន

ផ្សព្វផ្សាយដល់សាធារណជនទេ។ ទោះបីជាប្រាក់បង់ចូលទស្សនារមណីយដ្ឋានអង្គរ គឺជាប្រភពប្រាក់ចំណូលដ៏ធំជាងគេបង្អស់ក៏ដោយ ក៏ពុំមានអ្នកណាដឹងថាប្រាក់ចំណូលនោះមានចំនួនប៉ុន្មានពិតប្រាកដឡើយ ហើយប្រាក់នោះត្រូវបែងចែកដោយរបៀបណានោះទេ។

កង្វះតម្លាភាពក៏បានកើតមាននៅក្នុងការប្រមូលពន្ធដែរ បើទោះជាមន្ទីរពន្ធដារតែងប្រមូលបានទៅតាមទិសដៅនៃការប្រមូលពន្ធ ដែលបានកំណត់ទុកមុនជារៀងរាល់ឆ្នាំក៏ដោយ។ ដូចបានលើកឡើងខាងដើមរួចហើយ ចំនួនប្រាក់ពន្ធ ដែលត្រូវប្រមូលគឺជាចំនួន ដែលគេអាចកំណត់ដោយការចរចារគ្នា ដែលអ្នកប្រមូលពន្ធអាចនឹងធ្វើដោយការប្រុងប្រយ័ត្ន។

គួរកត់សំគាល់ថា បញ្ហាដែលបានលើកឡើងខាងលើមានទំនាក់ទំនងមួយចំណែកប៉ុណ្ណោះ ជាមួយនឹងរចនាសម្ព័ន្ធរដ្ឋាភិបាលមជ្ឈការបច្ចុប្បន្ននៅកម្ពុជា។ ឧទាហរណ៍ រដ្ឋអំណាចថ្នាក់ខេត្តជួបប្រទះកង្វះប្រាក់ចំណូល ប៉ុន្តែរដ្ឋាភិបាលក៏មិនអាចឱ្យមានការប្រមូលពន្ធថ្មីនៅក្នុងខេត្តសៀមរាបដែរ ដោយហេតុថាការប្រមូលពន្ធជាតួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិ។ ដូចគ្នានេះដែរ ការសំរបសំរួល និងការផ្សព្វផ្សាយព័ត៌មានរវាងរដ្ឋអំណាចខេត្ត និងអន្តរមន្ទីរក៏នៅមានកំរិតនៅឡើយ ដែលបញ្ហានេះក៏ជាប់ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋាភិបាលកម្ពុជាដែលគ្រប់គ្រងតាមរបៀបខ្សែទទឹងដែរ។

ទោះបីព័ត៌មានលំអិតពុំមានភាពច្បាស់លាស់នៅឡើយ (មកដល់ខែធ្នូ ឆ្នាំ២០០៥) រដ្ឋអំណាចខេត្តអាចនឹងមានការប្រយ័ត្នប្រយែងជាងមុនក្នុងការប្រមូលពន្ធ ដូចជា ការកំណត់អត្រាពន្ធ និងពន្ធថ្នាក់ជាតិមួយចំនួនអាចនឹងផ្ទេរមកនៅត្រឹមថ្នាក់ខេត្ត ដែលអាចនឹងបង្កើនប្រាក់ចំណូលសំរាប់អាជ្ញាធរថ្នាក់ខេត្ត។ លើសពីនេះទៀត ការបង្កើតរដ្ឋបាលឯកភាព លំហូរថវិកា២របៀបដែលកំពុងតែប្រើប្រាស់បច្ចុប្បន្នអាចនឹងត្រូវបញ្ចូលគ្នា និងថវិការបស់អន្តរមន្ទីរនឹងត្រូវបង្វែរទិសដៅ តាមរយៈអាជ្ញាធរខេត្ត។ មានការរំពឹងថា សមត្ថភាពសំរបសំរួលការងាររបស់អភិបាលខេត្តនឹងត្រូវបានពង្រឹង។ ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនឹងមានឥទ្ធិពលលើបញ្ហា ដែលបានកំណត់នៅក្នុងផ្នែកនេះ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្ងៃអនាគត។

**៧.២.២ គោលដៅ**

**(១) គោលដៅរយៈពេលខ្លី**

មានសំណូមពរថា គោលដៅមួយដែលមានទំនាក់ទំនងជាមួយហិរញ្ញវត្ថុមូលដ្ឋាននៅក្នុងខេត្តសៀមរាបនោះគឺថា:

**"រដ្ឋាភិបាលត្រូវផ្តល់នូវធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដើម្បីធានាឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់ខេត្តសៀមរាប"**

ខេត្តសៀមរាបមានជោគជ័យច្រើនក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាលទ្ធផល វិស័យទេសចរណ៍បានផ្តល់ការងារឱ្យមនុស្សនៅមូលដ្ឋានខេត្តសៀមជាច្រើនបន្ថែមលើវិស័យកសិកម្ម។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយហេតុថាការអភិវឌ្ឍន៍វិស័យទេសចរណ៍មានការរីកចំរើនយ៉ាងឆាប់រហ័ស រដ្ឋាភិបាលហាក់ដូចជាពុំមានលទ្ធភាពក្នុងការគ្រប់គ្រង វិស័យនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពនៅឡើយទេ។ ទោះបីជាចំនួនភ្ញៀវទេសចរ និងតំលៃដីធ្លីកំពុងតែកើនឡើងយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលមិនអាចទាញយកផលប្រយោជន៍ឱ្យបានពេញលេញពីការរីកចំរើនទាំងនេះដែរ។ ជាលទ្ធផល រដ្ឋាភិបាលមិនអាចផ្តល់នូវធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដើម្បីធានាឱ្យបាននូវ

ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ខេត្តសៀមរាបទេ។

បញ្ហាដែលទាក់ទងគ្នានេះដែរ គឺការពឹងពាក់ទៅលើការផ្តល់ប្រាក់ឧបត្ថម្ភទាំងស្រុងពីរដ្ឋាភិបាលជាតិ។ នៅពេលដែលរដ្ឋអំណាចខេត្តសៀមរាប និងអន្តរមន្ទីរ (ចំណែកថវិការបស់ខេត្តបានមកពីចំណែកថវិកាជាតិ) ត្រូវបានគេដាក់បញ្ចូលគ្នាចំនួនប្រាក់ពន្ធ និងប្រាក់មិនមែនពន្ធដែលគេប្រមូលបាននៅក្នុងខេត្តសៀមរាប ដែលត្រូវផ្តល់ទៅឱ្យរដ្ឋាភិបាលជាតិមានចំនួនតិចជាងប្រាក់ឧបត្ថម្ភ និងលំហូរថវិកាផ្សេងទៀតពីរដ្ឋាភិបាលជាតិមកខេត្ត។ ការនេះបង្ហាញថា រដ្ឋអំណាចខេត្តសៀមរាបនឹងមានទំនោរទៅលើការពឹងពាក់ទាំងស្រុងខាងហិរញ្ញវត្ថុទៅលើរដ្ឋាភិបាលជាតិ។ គេចង់ឱ្យខេត្តសៀមរាបជាអ្នកប្រមូលប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់នៅក្នុងខេត្ត ដើម្បីផ្តល់ជាថវិកាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ខេត្តសៀមរាប និងធ្វើឱ្យខេត្តសៀមរាបក្លាយជាអ្នកម្ចាស់ការផ្នែកហិរញ្ញវត្ថុដោយខ្លួនឯង។

**(២) គោលដៅរយៈពេលវែង**

គោលដៅរយៈពេលវែងរបស់ខេត្តសៀមរាប ទាក់ទងនឹងហិរញ្ញវត្ថុមូលដ្ឋានគឺ :

**"ប្រាក់ចំណូលសារពើពន្ធនៅខេត្តសៀមរាប ជួយជំរុញឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា"**

មានការរំពឹងទុកថា ខេត្តសៀមរាបនឹងក្លាយជាកំលាំងជំរុញដ៏សំខាន់របស់ប្រទេស ដោយការផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដែលប្រមូលបានក្នុងខេត្តសៀមរាបទៅដល់ខេត្តផ្សេងៗទៀតនៅទូទាំងប្រទេស។ ទោះបីជាយ៉ាងនេះក្តី ថ្មីៗនេះខេត្តសៀមរាបគឺជាខេត្តក្រីក្រជាងគេបង្អស់ទី២ ហើយប្រហែលជាមិនអាចបំពេញតួនាទីនោះបានទេ។

មិនចាំបាច់និយាយទេថា ការបែងចែកប្រាក់ចំណូលគឺជាតួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិ ពោលគឺមិនមែនជាតួនាទីរបស់រដ្ឋអំណាចខេត្តសៀមរាបទេ។ ទោះបីជាយ៉ាងនេះក៏ដោយ គេនៅតែចង់ឱ្យរដ្ឋាភិបាលប្រមូលធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់នៅក្នុងខេត្តសៀមរាប តាមរយៈការយកពន្ធ/កំរៃ និងវិធីសាស្ត្រផ្សេងទៀត ហើយផ្ទេរធនធានដែលប្រមូលបានទាំងនេះទៅឱ្យរដ្ឋាភិបាលថ្នាក់ជាតិ។

**៧.២.២ យុទ្ធសាស្ត្រ**

ដើម្បីសំរេចឱ្យបាននូវគោលដៅរយៈពេលខ្លី និងរយៈពេលវែងខាងលើ យុទ្ធសាស្ត្រ ៣ ខាងក្រោមនេះគួរតែយកមកអនុវត្ត :

- បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្ត
- កែលំអផែនការថវិកា/ការប្រើប្រាស់ថវិកា និងធនធានមនុស្ស
- ពង្រឹងតម្លាភាពដែលទាក់ទងទៅនឹងបញ្ហាហិរញ្ញវត្ថុ

ខាងក្រោមនេះគឺជាការពិភាក្សាស៊ីជំរៅអំពីយុទ្ធសាស្ត្រនីមួយៗ ខាងលើនេះ

**(១) បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្ត**

បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្តគឺជាការចាំបាច់នៅក្នុងវិស័យជាច្រើន។ នៅពេលដែលមានតំរូវការច្រើន គេបានផ្តល់យោបល់ថា មុនដំបូងចំនួនពិតប្រាកដណាមួយនោះគួរតែបែងចែកទៅឱ្យការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុង ពីព្រោះវាមានឥទ្ធិពលច្រើនលើការអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តសៀមរាបតាមរយៈការអភិវឌ្ឍន៍វិស័យទេសចរណ៍។

ចំនួនភ្ញៀវទេសចរមកកាន់ខេត្តសៀមរាបមានការកើនឡើងយ៉ាងឆាប់រហ័ស ជាហេតុនាំឱ្យមានកំណើនហេដ្ឋារចនាសម្ព័ន្ធក្រុងឱ្យបានគ្រប់គ្រាន់ផងដែរ ។ ដើម្បីឆ្លើយតបទៅនឹងតំរូវការនេះ រដ្ឋអំណាចថ្នាក់ខេត្តបានបែងចែកនូវចំណែកថវិកាច្រើនជាងគេដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ (ជាពិសេសកែលំអផ្លូវថ្នល់) ទៅដល់ខេត្តសៀមរាបច្រើនជាងខេត្តដទៃទៀតនៅក្នុងប្រទេស ។ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដូចជាប្រព័ន្ធបង្ហូរទឹកភ្លៀង និងប្រព័ន្ធបង្ហូរសំណល់រាវក៏មិនទាន់មានដែរ ។ ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងក្រុងគឺជាការចាំបាច់ ហើយរដ្ឋអំណាចថ្នាក់ខេត្តត្រូវការនូវចំនួនធនធានហិរញ្ញវត្ថុឱ្យបានច្រើនជាង នេះ ។

តាមការពិត ការផ្តល់ជំនួយពីខាងក្រៅ (ធនធានដែលមិនមែនជារបស់រដ្ឋ) ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាហិរញ្ញវត្ថុ ជាពិសេសក្នុងការវិនិយោគក្នុងកិច្ចការសាធារណៈក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៀត នៅពេលបច្ចុប្បន្នអាជ្ញាធរខេត្តមានសិទ្ធិក្នុងការសំរេចឱ្យមាន ឬមិនឱ្យមានការវិនិយោគ ដែលមានទឹកប្រាក់តិចជាង២លានដុល្លារ ។ ដូច្នេះសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្រុងក្នុងខេត្តសៀមរាប ចាំបាច់ត្រូវយកចិត្តទុកដាក់លើជំនួយបរទេសជាដំបូង និងការវិនិយោគពីខាងក្រៅជាជាងការប្រើប្រាស់ធនធានមូលដ្ឋាន ។

នៅក្នុងរយៈពេលវែង ការពង្រឹងហិរញ្ញវត្ថុមូលដ្ឋានមានតួនាទីរឹតតែសំខាន់ ។ ពីព្រោះហេដ្ឋារចនាសម្ព័ន្ធក្រុងមានការប្រើប្រាស់ និងការថែទាំ ហើយរាល់ការចំណាយទាំងនេះគួរតែជាបន្ទុករបស់រដ្ឋាភិបាលមូលដ្ឋាន ។ លើសពីនេះទៀត គំរោងហេដ្ឋារចនាសម្ព័ន្ធក្រុងមួយចំនួនដូចជា ការកែលំអផ្លូវតូចៗ ដែលមានសារៈសំខាន់សំរាប់សហគមន៍មូលដ្ឋាន ប្រហែលជាមិនបានទទួលការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុពីប្រភពក្រៅទេ ។ នៅក្នុងបរិបទដូច្នេះ ចាំបាច់ណាស់ដែលរដ្ឋាភិបាលត្រូវផ្តល់ធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ សំរាប់ការចំណាយលើផ្នែកហេដ្ឋារចនាសម្ព័ន្ធក្រុងនៅខេត្តសៀមរាប ។

វិធានការដើម្បីបង្កើនធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរខេត្តរួមមានដូចខាងក្រោម :

- ពង្រឹងការប្រមូលពន្ធ
- ធ្វើការបែងចែកធនធានដែលមានស្រាប់ទៅឱ្យអាជ្ញាធរខេត្ត
- អនុវត្តនូវការប្រមូលពន្ធថ្មី/កំរៃ និងផ្លាស់ប្តូរអត្រាពន្ធ

វិធានការទីមួយៗត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោម :

### ១) ពង្រឹងការប្រមូលពន្ធ

វិធានការដែលត្រូវអនុម័តនៅថ្នាក់ខេត្តរួមមាន :

- បង្កើតមូលដ្ឋានទិន្នន័យរបស់អ្នកបង់ពន្ធ
- កត់សំគាល់អ្នកដែលនៅជំពាក់ប្រាក់ពន្ធ និងប្រាក់មិនមែនពន្ធ និងរៀបចំផែនការ ដើម្បីប្រមូលពន្ធ
- កំណត់វិធានការដើម្បីពង្រឹងការប្រមូលប្រាក់មិនមែនពន្ធ
- កែលំអការកំណត់ចំនួនប្រាក់សរុបដែលប្រមូលបាន ដោយវិធីសាស្ត្រចាំន់ស្មាន និងធ្វើការផ្ទៀងដោយប្រើវិធីសាស្ត្រពិត
- កែលំអសេវាកម្មសំរាប់អ្នកបង់ពន្ធ

- បង្កើនហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ ដូចជាកុំព្យូទ័រ
- ផ្តល់នូវការបណ្តុះបណ្តាលដល់មន្ត្រីការិយាល័យពន្ធដារ

## ២) ធ្វើការបែងចែកធនធានដែលមានស្រាប់ទៅឱ្យរដ្ឋអំណាចថ្នាក់ខេត្តវិញ

គេបាននិយាយថា មានប្រាក់ប្រហែលតែ៤% ប៉ុណ្ណោះ ដែលប្រមូលបានពីភ្ញៀវទស្សនារមណីយដ្ឋានអង្គរត្រូវបានយកមកប្រើប្រាស់សំរាប់ការអភិវឌ្ឍទីក្រុងសៀមរាប។ គេបានស្នើឱ្យគ្រោងទុកនូវចំនួនភាគរយពិតប្រាកដនៃប្រាក់ចំណូលដែលបានមកពីការចូលទស្សនាអង្គរវត្តសំរាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខេត្តសៀមរាប។ អាជ្ញាធរអប្សរាក៏អាចនឹងបាន-ផលប្រយោជន៍ពីការវិនិយោគនេះដែរ ពីព្រោះថាការវិនិយោគនេះអាចនឹងនាំឱ្យមានការកើនឡើងនូវចំនួនភ្ញៀវទេសចរ (ឬក៏រយៈពេលនៃការស្នាក់នៅរបស់ភ្ញៀវមានរយៈពេលច្រើនថ្ងៃជាង) ដែលអាចបង្កើនការប្រមូលប្រាក់ចូលទស្សនារមណីយដ្ឋានអង្គរ។ ប្រសិនបើប្រាក់១០%នៃប្រាក់ប្រមូលបានពីការចូលទស្សនានេះត្រូវបានបែងចែកទៅឱ្យអាជ្ញាធរខេត្ត កំណើនប្រាក់ចំណូលនឹងអាចមានប្រហែល១,៣ លានដុល្លារ ដែលមានចំនួនស្មើរតែប្រហាក់ប្រហែលនឹងប្រាក់ចំណូលប្រចាំឆ្នាំនៅឆ្នាំ២០០៤។

## ៣) អនុវត្តនូវការប្រមូលពន្ធ/កំរៃថ្មី និងផ្លាស់ប្តូរអត្រាពន្ធ

នៅពេលដែលការបែងចែកចំណែកដែលបានមកពីចំណូលទស្សនារមណីយដ្ឋានអង្គរគឺជាផ្នែកអាទិភាព ការអនុវត្តនីការប្រមូលពន្ធ/កំរៃថ្មី និងកំណែទំរង់អត្រាពន្ធក៏មានសារៈសំខាន់ក្នុងការបង្កើនប្រាក់ចំណូលរបស់អាជ្ញាធរខេត្តដែរ។ នៅពេលដែលធ្វើការរៀបចំពន្ធ/កំរៃថ្មី ចាំបាច់ត្រូវពិចារណាអត្រាថ្មីនេះដោយផ្អែកលើមូលដ្ឋាននៃការបង់ពន្ធ។ មានការស្នើថាប្រាក់ចំណូលដែលកើនជាដំបូង១នឹងត្រូវយកទៅប្រើប្រាស់សំរាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុង។ អ្នកដែលបានទទួលផល-ប្រយោជន៍ដោយផ្ទាល់នោះ គឺជាភ្ញៀវទេសចរ ដែលគួរជាអ្នកទទួលខុសត្រូវក្នុងការបង់ពន្ធថ្មីនេះ ពីព្រោះថាប្រាក់ដែលប្រមូលបានមកពីពន្ធថ្មីនេះនឹងត្រូវយកទៅប្រើប្រាស់សំរាប់អ្នកប្រើប្រាស់វិញ។ ការបង់ពន្ធថ្មី ៤ ប្រភេទខាងក្រោមនេះត្រូវបានស្នើឡើង។

- ប្រមូលពន្ធសំរាប់ការស្នាក់នៅ
- បង្កើនអត្រាពន្ធប៉ាតង់លើផ្នែកសេវាកម្ម
- ប្រមូលកំរៃលើការបូមទឹកពីក្នុងដី
- អនុវត្តពន្ធលើទ្រព្យសម្បត្តិ

តារាង២២គឺជាការសង្ខេបប្រាក់ចំណូលដែលគេរំពឹងទុក គុណសម្បត្តិ និងគុណវិបត្តិនៃជំរើសនីមួយ១ដែលគេបានលើកឡើងខាងលើ។

## (២) កែលំអផែនការថវិកា/ការប្រើប្រាស់ថវិកា និងធនធានមនុស្ស

ការចែករំលែកព័ត៌មាន និងសំរបសំរួលប្រកបដោយប្រសិទ្ធភាពនៅគ្រប់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធត្រូវតែធ្វើឡើង។ កម្មវិធីសិលាគឺជាការពិសោធដែលកំពុងអនុវត្ត ដើម្បីបង្កើតផែនការវិមជ្ឈការ និងការគ្រប់គ្រងថវិកា។ នៅពេលដែលលំហូរហិរញ្ញវត្ថុនៅក្នុងកម្មវិធីសិលាមានលក្ខណៈខុសប្លែកពីលំហូរប្រព័ន្ធថវិកាសាធារណៈ វិធីសាស្ត្រដែលគេអនុវត្ត

ក្នុងកម្មវិធីសិលាអាចជួយពង្រឹងទាំងការចែករំលែកព័ត៌មាន ក៏ដូចជាការសំរបសំរួលដែលមានប្រសិទ្ធភាពដោយអភិបាលខេត្តនៅក្នុងការបែងចែកធនធានទៅឱ្យមន្ទីរពាក់ព័ន្ធ ។ លទ្ធភាពនៃប្រព័ន្ធបែងចែកថវិកាបែបនេះគួរតែត្រូវធ្វើការស្វែងយល់ឱ្យបានស៊ីជំរៅថែមទៀត ។

*កម្មវិធីកំណែទំរង់នៃការគ្រប់គ្រងសាធារណៈ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០០៤)* ក៏បានបញ្ជាក់អំពីវិធានការចាំបាច់ដើម្បីកែលំអការធ្វើផែនការថវិកា និងការប្រើប្រាស់ថវិកា ។ វិធានការដែលត្រូវអនុម័តនៅថ្នាក់ខេត្តរួមមាន :

- ត្រួតពិនិត្យ និងអនុវត្តវិធានការដើម្បីពង្រឹងការប្រើប្រាស់ថវិកា ផែនការលំហូរថវិកា ការព្យាករណ៍ និងត្រួតពិនិត្យក្នុងគោលបំណងឱ្យមានការផ្តល់ថវិកាឱ្យបានទាន់ពេល ។
- ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងផែនការបញ្ចេញថវិកា នៅដើមឆ្នាំប្រកបដោយតម្លាភាពរួមបញ្ចូលទាំងវិធានការបំរុងផ្សេងៗ បើគ្មានសាច់ប្រាក់ទេ ។
- ផ្តល់ការបណ្តុះបណ្តាលស្តីអំពីការព្យាករណ៍ពីក្រោមទៅលើនូវតំរូវការសាច់ប្រាក់ ។
- ពង្រឹងនីតិវិធីលទ្ធកម្មតាមរយៈការសំរួលនីតិវិធី និងឯកសារនៅគ្រប់សេវាសាធារណៈទាំងអស់ ។
- រៀបចំផែនការ និងអនុវត្តនូវដំណើរការកសាងសមត្ថភាព ដើម្បីលើកកំពស់ការយល់ដឹង និងសមត្ថភាពនៃការប្រើប្រាស់កុំព្យូទ័រ និងសំភារៈផ្សេងៗទៀតក្នុងវិស័យហិរញ្ញវត្ថុ ។

**តារាង ២២ : ការប្រៀបធៀបជំរើសប្រភពប្រាក់ចំណូល**

| | ភាពខុសគ្នា | ចំនួនប៉ាន់ស្មាន | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|---|---|
| ១. | ការផ្ទេរប្រាក់មួយចំនួននៃចំណូលពីការចូលទស្សនាអង្គរ | ១.៣ លានដុល្លារ (២០០៤) ប្រសិន បើ ១០ % នៃថ្លៃចូលទស្សនា | • នេះអាចជាប្រភពចំណូលដ៏ច្រើនបំផុត<br>• ការអភិវឌ្ឍន៍ទេសចរចាំបាច់ត្រូវអភិឱ្យហេដ្ឋារចនាសម្ព័ន្ធក្រុងសៀមរាប ។ ដូច្នេះ នេះគឺភាពសមរម្យក្នុងការប្រាស់ប្រាក់ចំណូលពីការចំណាយរបស់អ្នកទេសចរ (ផ្នែកមួយនៃថ្លៃប្រើប្រាស់) ។ | • កិច្ចសន្យារវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុនសុខាអាចនឹងត្រូវកែប្រែ ។<br>• អាចជាជម្លោះនៃការប្រើប្រាស់ថវិការវាងក្រុមហ៊ុនសុខា អាជ្ញាធរអប្សរា និងសាលាខេត្ត ។ |
| ២. | ការអនុវត្តន៍ពន្ធស្នាក់នៅ (២%) នៃតំលៃស្នាក់នៅ | ០,២៧លានដុល្លារ (២០០៦) មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | • មានលក្ខណៈច្បាស់លាស់នៃថ្លៃរបស់អ្នកប្រើប្រាស់<br>• ច្បាប់ត្រូវបានអនុម័ត និងប្រកាសបានផ្សព្វផ្សាយ<br>• ពន្ធត្រូវប្រមូលសំរាប់ខេត្ត | • ការអនុវត្តន៍ត្រូវបានផ្អាកដោយមានការជំទាស់ប្រឆាំង ។ |
| ៣. | បង្កើនអត្រាការយកពន្ធពិតង់លើសេវាកម្មផ្សេងៗ | ០,០៧ លានដុល្លារ (២០០៤) | • មូលដ្ឋានពន្ធទូលំទូលាយជាងកន្លែងស្នាក់នៅ (លេខ.២) រួមបញ្ចូលទាំងភោជនីយដ្ឋាន និងភ្នាក់ងារទេសចរផងដែរ ។<br>• មានលក្ខណៈច្បាស់លាស់នៃថ្លៃរបស់អ្នកប្រើប្រាស់ | • ចំណូលដែលបានរំពឹងទុកតិចតួច ។ |
| ៤. | យកថ្លៃប្រើប្រាស់ទឹកក្រោមដី ។ | ០,០៨លានដុល្លារ (២០០៤) ប្រសិនបើអត្រាគ្នាដូចនឹងថ្លៃប្រើប្រាស់សព្វថ្ងៃ ។ | • វាក៏ល្អផងដែរសំរាប់បរិស្ថាន ។<br>• ប្រភពចំណូលសំខាន់គឺពីសណ្ឋាគារ និងការបង់ប្រាក់ត្រូវអនុវត្តន៍លើអ្នកទេសចរ ។ ដូច្នេះនេះ ជាថ្លៃនៃអ្នកប្រើប្រាស់ ។<br>• ប្រសិនបើមានការបង្កើតឱ្យមានការបង់ប្រាក់ ការឯកភាពពីរដ្ឋសភាមិនសំខាន់ទេ ។ | • វាសំខាន់ណាស់ដែលត្រូវមានក្រុមហ៊ុនដំឡើងឧបករណ៍ស្ទង់ ហើយធ្វើរបាយការណ៍ទៅភ្នាក់ងារត្រួតពិនិត្យ ។<br>• វាពិបាកក្នុងការណែនាំព្រោះពេល នេះអ្នកប្រើប្រាស់ទឹកក្រោមដីមិន |

| | | | | |
|---|---|---|---|---|
| | | | | មានប្រភពទឹកច្បាស់លាស់ (ឥទ្ធិពលនៃការសន្សំថៃទឹកបានច្រើនត្រូវបានគេរំពឹងទុក) ។<br>• ចំណូលដែលបានរំពឹងទុកតិចតួច ។ |
| ៥. | យកពន្ធអចលនទ្រព្យ | មិនដឹង ប៉ុន្តែអាចមានចំនួនច្រើន | • តំលៃដីកំពុងឡើងខ្ពស់យ៉ាងលឿននៅសៀមរាប និងរដ្ឋាភិបាលគួរទទួលចំណែកមួយពីកំណើននេះ<br>• ពន្ធអចលនទ្រព្យមានចំនួនច្រើននៅក្នុងខេត្ត | • អាចមានការលំបាកដោយសារហេតុផលនយោបាយ<br>• អាចលំបាកក្នុងការវាយតំលៃដី<br>• អាចចាប់ផ្តើមនៅមុនមានប្រព័ន្ធកាន់កាប់ដីធ្លីសមស្រប |

## ៣. ពង្រឹងតម្លាភាពដែលទាក់ទងទៅនឹងហិរញ្ញវត្ថុរដ្ឋ

ការមានតម្លាភាពរបស់រដ្ឋាភិបាលលើបញ្ហាហិរញ្ញវត្ថុគឺជាការចាំបាច់ ។ មានការព្រួយបារម្ភពីប្រជាជនមូលដ្ឋាន និងសហគមន៍ផ្តល់ជំនួយស្តីពីកង្វះខាតតម្លាភាពលើការផ្តល់ហិរញ្ញវត្ថុពីរដ្ឋ ។ អ្នកបង់ពន្ធហាក់ដូចជាមិនចង់បង់ពន្ធទេ នៅពេលដែលចំនួនប្រាក់ពន្ធដែលគេប្រមូលបាន និងការប្រើប្រាស់ប្រាក់នេះមិនច្បាស់លាស់ និងនៅពេលដែលពួកគេគិតថាផលប្រយោជន៍ ដែលពួកគេទទួលបានពីសេវាកម្មរដ្ឋមិនគ្រប់គ្រាន់ បើប្រៀបធៀបទៅនឹងប្រើប្រាស់ប្រាក់ពន្ធដែលប្រមូលបាន ។

អាជ្ញាធរអប្សរាមិនមែនជាករណីលើកលែងនោះទេ ។ មានការស្នើថា អាជ្ញាធរអប្សរាត្រូវផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុទៅដល់សាធារណៈជនទូទៅ ។ បើពុំមានតម្លាភាពទេ គណនេយ្យភាពក៏មិនអាចកើតមានដែរ ។ ដើម្បីធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុផ្សព្វផ្សាយដល់មនុស្សគ្រប់គ្នានោះ អាជ្ញាធរអប្សរាអាចពិចារណាបោះពុម្ពរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងគេហទំព័រដោយមានការបំបែកទៅតាមផ្នែកនីមួយៗឱ្យបានត្រឹមត្រូវ ។

លើសពីនេះទៀត វិធានការពីរខាងក្រោមត្រូវបានគេស្នើឡើងដើម្បីលើកកំពស់តម្លាភាព ។

### ១) បង្កើតមូលនិធិអភិវឌ្ឍន៍ខេត្តសៀមរាប

មានការស្នើឱ្យបង្កើតមូលនិធិនៅក្នុងអាជ្ញាធរខេត្តសៀមរាប (រតនាគារ) និងមូលនិធិនេះត្រូវប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តសៀមរាប ។ ប្រភពនៃមូលនិធិនេះនឹងត្រូវប្រមូលបានមកពីជំរើសពីទីមួយដល់ទីបួនដែលបានលើកឡើងនៅក្នុងតារាង២២ [7] ។

មានហេតុផល២ យ៉ាងដើម្បីបង្កើតមូលនិធិអភិវឌ្ឍន៍ខេត្តសៀមរាប បន្ថែមទៅនឹងថវិកាទូទៅ ។ ហេតុផលទី១ គឺដើម្បីពង្រឹងតម្លាភាព ។ ជាមួយនឹងមូលនិធិនេះ ការប្រើប្រាស់ថវិកានឹងមានលក្ខណៈងាយស្រួលក្នុងការតាមដាន និងការទទួលខុសត្រូវ ។ គេរំពឹងថា ភ្ញៀវទេសចរនឹងស្ម័គ្រចិត្តបង់ពន្ធបែបនេះ ។ ហេតុផលទី២ គឺការអនុវត្តន៍ដោយរលូននូវគំរោងនានា ។ ការអនុវត្តន៍គំរោងតែងតែមានការយឺតយ៉ាវដោយសារកង្វះថវិកា និងរតនាគារថ្នាក់ខេត្តពុំមានសិទ្ធិអំណាចក្នុងការបែងចែកថវិកា ។ ដោយបង្កើតមូលនិធិបែបនេះ ប្រាក់ដែលមានសំរាប់ការងារមានច្បាស់លាស់ ហើយគេរំពឹងថាការបែងចែកថវិកាសំរាប់អនុវត្តការងារអាចបែងចែកបានទាន់ពេលវេលាជាងមុន ។

[7] ប្រាក់ចំណូលដែលបានមកពីពន្ធលើទ្រព្យសម្បត្តិគួរតែប្រើប្រាស់សំរាប់គោលបំណងទូទៅពីព្រោះថា វាមិនមែនជាប្រាក់ដែលប្រមូលពីអ្នកប្រើប្រាស់សំរាប់អ្នកប្រើប្រាស់ទេ

មានការស្នើថា ការប្រើប្រាស់មូលនិធិនឹងត្រូវកំណត់សំរាប់តែគោលបំណងដូចខាងក្រោម :

- កែលំអ និងថែទាំផ្លូវថ្នល់
- ប្រើប្រាស់ និងថែទាំប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ
- ការគ្រប់គ្រងសំណល់រឹងនៅក្នុងទីសាធារណៈ

ផ្នែកទាំង ៣ នេះត្រូវបានគេជ្រើសរើសមកអនុវត្តដោយប្រើប្រាស់មូលនិធិនេះ ពីព្រោះថាប្រព័ន្ធប្រមូលប្រាក់ដើម្បីបំរើផលប្រយោជន៍អ្នកប្រើប្រាស់វិញពុំមានដំណើរការបានល្អប្រសើរឡើយ ។ ម្យ៉ាងវិញទៀត គេទទួលស្គាល់ថាតំលៃនៃការប្រើប្រាស់ និងថែទាំសំរាប់ការផ្គត់ផ្គង់ទឹក អគ្គិសនី និងការគ្រប់គ្រងកាកសំណល់រឹងនៅទីសាធារណៈនឹងត្រូវបង់ដោយប្រាក់ដែលប្រមូលបានពីអ្នកប្រើប្រាស់ទាំងនោះ ។ ការប្រមូលប្រាក់សំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះអាចជួបប្រទះនឹងការលំបាក ។ ភាគច្រើននៃហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវសាងសង់ដោយប្រើថវិកាពីខាងក្រៅ ដូចជាជំនួយបរទេសជាដើម ។

តំបន់ភូមិសាស្ត្រនៃការប្រើប្រាស់មូលនិធិនេះគឺត្រូវកំណត់តែនៅក្នុងតំបន់ក្រុងសៀមរាប និងតំបន់ជិតខាងប៉ុណ្ណោះដើម្បីធានាថា ថវិកាទាំងអស់នេះត្រូវបានប្រើសំរាប់បំរើផលប្រយោជន៍របស់ភ្ញៀវទេសចរ ។ និយាយឱ្យច្បាស់ជាងនេះ មានការស្នើថា ថវិកាទាំងអស់នេះត្រូវប្រើប្រាស់សំរាប់តែការអភិវឌ្ឍន៍នៅក្នុងស្រុកសៀមរាបតែប៉ុណ្ណោះ ។

ថវិកានេះនឹងត្រូវគ្រប់គ្រងដោយគណៈកម្មាការអភិវឌ្ឍន៍ ដូចបានលើកឡើងក្នុងផ្នែកខាងដើម ។ ជាការសំខាន់ណាស់ដែលថា ការបែងចែកថវិកានេះគួរតែពិភាក្សាជាមួយនឹងក្រសួង/មន្ទីរពាក់ព័ន្ធដោយមានការសំរបសំរួលប្រកបដោយប្រសិទ្ធភាពពីអភិបាលខេត្ត ។ ថវិកានេះគួរតែបានបែងចែកឱ្យដាច់ស្រឡះពីថវិកាទូទៅរបស់ខេត្តដែលមាននៅក្នុងរតនាគារដើម្បីធានាឱ្យមានការផ្តល់ជាសាច់ប្រាក់បានទាន់ពេលវេលា និងរលូន ។

បើតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គំរោងមូលនិធិបែបនេះមិនទាន់មាននៅកម្ពុជានៅឡើយ ប៉ុន្តែគេអាចនឹងបង្កើតដោយមានការយល់ព្រមពីសភាជាតិ ។

**២) បង្កើតវេទិកាដើម្បីលើកកំពស់តម្លាភាពហិរញ្ញវត្ថុ**

ជាការសំខាន់ណាស់ដែលស្ថាប័នរដ្ឋ (រដ្ឋអំណាចថ្នាក់ខេត្ត និងមន្ទីរពាក់ព័ន្ធ អាជ្ញាធរអប្សរា និងរដ្ឋអំណាចផ្សេងៗទៀត) ផ្សព្វផ្សាយប្រាក់ចំណូល និងចំណាយឱ្យបានលំអិតដល់សាធារណៈជនទូទៅ ។ រាល់ការផ្ទេរ ឬបើកប្រាក់ត្រូវធ្វើឡើងប្រកបដោយតម្លាភាព ។ ខេត្តសៀមរាបថ្មីៗនេះបានបង្កើតសេវាកម្មច្រកចេញចូលតែមួយ ។ កាលពីមុន មានការលើកឡើងថា នៅពេលដែលនរណាម្នាក់ចង់ចាប់ផ្តើមមុខជំនួញ មនុស្សនោះត្រូវសុំច្បាប់អនុញ្ញាតពីការិយាល័យ/មនុស្សជាច្រើនដោយមានការបង់ប្រាក់ក្រោមតុ ។ ជាមួយនឹងសេវាកម្មច្រកចេញចូលតែមួយ ការបង់ប្រាក់ត្រូវមានចែងយ៉ាងច្បាស់នៅលើជញ្ជាំងការិយាល័យ និងរាល់ការបង់ ឬផ្ទេរប្រាក់ត្រូវធ្វើឡើងនៅការិយាល័យតែមួយឱ្យបានលឿន ។ ជាមួយនឹងសេវាកម្មតែមួយកន្លែងដូចនេះ តម្លាភាពត្រូវបានពង្រឹង ហើយប្រជាជនមានការពេញចិត្តយ៉ាងខ្លាំង ។

## ៧.៣ សកម្មភាពដែលត្រូវតែអនុវត្តជាបន្ទាន់

ការរៀបចំហិរញ្ញវត្ថុ និងស្ថាប័នគឺជាដំណើរការបន្តលើការអភិវឌ្ឍន៍។ ដើម្បីឱ្យសៀមរាបអាចចាប់ផ្ដើមដំណើរការបន្តនេះបាន ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួន បន្ទាប់ពីបញ្ចប់ការសិក្សានៃផែនការមេនេះ។ សកម្មភាពទាំងនោះរួមមាន :

១. អនុវត្តតាមផែនការមេ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើគំរោងជាអាទិភាព។ ដើម្បីសំរួលដល់ការងារ អាជ្ញាធរខេត្តគួរមានទីប្រឹក្សា ដែលអាចរៀបចំឯកសារបច្ចេកទេសដែលចាំបាច់សំរាប់សំរួលដល់ការអនុវត្តន៍នៃគំរោងអាទិភាពទាំងនោះ។ មានការរំពឹងថា ទីប្រឹក្សានោះនឹងជួយពង្រឹងសមត្ថភាពបច្ចេកទេសនៃមន្ទីរជំនាញពាក់ព័ន្ធនៅក្នុងខេត្ត

២. អនុវត្តតាមផែនការមេ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើការធ្វើផែនការ និងគំរោងសំរាប់តំបន់ក្រុង។ ដើម្បីសំរួលដល់ការងារ អាជ្ញាធរខេត្តគួរមានទីប្រឹក្សាម្នាក់ដែលអាចបកស្រាយ និងកែសំរួលផែនការប្រើប្រាស់ដីក្រុង និងគំរោងក្នុងក្រុងតាមរយៈការសំរបសំរួលយ៉ាងល្អពីអាជ្ញាធរអប្សរា និងស្រុកសៀមរាប

៣. ពង្រឹងសមត្ថភាពគ្រប់គ្រង និងបច្ចេកទេសរបស់មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្ករ ដែលបានរៀបចំឡើងសំរាប់គំរោងសាកល្បងក្នុងអំឡុងពេលនៃការសិក្សានេះ។ ការបញ្ជូនបុគ្គលិកសំខាន់ៗរបស់មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្ករទៅកាន់ប្រទេស/ទីផ្សារពាក់ព័ន្ធដើម្បីផ្លាស់ប្ដូរព័ត៌មាន និងគំនិតអំពីការលើកកំពស់ផលិតផលក្នុងស្រុកគឺជាការចាំបាច់

៤. រៀបចំការសិក្សាជាយុទ្ធសាស្ត្រស្ដីពីផែនការមេរួមទាក់ទងនឹងធនធានទឹក។ ដូចមានការពិភាក្សាច្រើនដងរួចមកហើយ ទឹកគឺជាផ្នែកដ៏សំខាន់បំផុតសំរាប់ការអភិវឌ្ឍន៍នៅសៀមរាប។ ដោយសារកំណើនយ៉ាងលឿនលើការប្រើប្រាស់ទឹកក្រោមដី ការសិក្សាអំពីធនធានទឹកនោះគួរតែចាប់ផ្ដើមអនុវត្តឱ្យបានលឿនបំផុត។ ជាមួយគ្នានេះ ការគ្រប់គ្រងទឹកគឺជាការងារចំបងដែលតំរូវឱ្យមានការសំរបសំរួលអន្តរមន្ទីរនៅថ្នាក់ខេត្ត។

៥. បង្កើតគណៈកម្មការអភិវឌ្ឍន៍ខេត្តដើម្បីតាមដានត្រួតពិនិត្យផែនការមេនេះតាមពេលវេលាជាក់លាក់។ គណៈកម្មការនេះមិនចាំបាច់ជាគណៈកម្មការផ្លូវការឡើយ ប៉ុន្តែអាចប្រែប្រួលទៅតាមកាលៈទេសៈ។ ដៃគូអភិវឌ្ឍន៍អន្តរជាតិ ដូចជាJICA អាចស្នើឱ្យចូលរួមធ្វើជាទីប្រឹក្សា ឬអ្នកសង្កេតការក្នុងគណៈកម្មការ។

៦. ពិនិត្យឡើងវិញ និងកំណត់មុខងាររបស់អាជ្ញាធរពាក់ព័ន្ធ ដូចជាអភិបាលខេត្ត ក្នុងការគ្រប់គ្រងសកម្មភាពសាងសង់ ការប្រែប្រួលលើការប្រើប្រាស់ដីធ្លី និងការប្រើប្រាស់ទឹកក្រោមដីសំរាប់បំរើផលប្រយោជន៍ពាណិជ្ជកម្ម។

៧. ធ្វើឱ្យសំរេចលើការប្រមូលពន្ធស្នាក់នៅ ។ បើទោះបីសភាជាតិបានអនុម័តច្បាប់លើពន្ធលើការស្នាក់នៅរួចហើយក្ដី ការអនុវត្តន៍ច្បាប់នោះត្រូវបានពន្យា ។ ភាពជោគជ័យលើការប្រមូលពន្ធស្នាក់នៅនឹងជួយពង្រឹងមូលដ្ឋានសេដ្ឋកិច្ចរបស់អាជ្ញាធរខេត្ត។

# ៨. ការគិតគូរពីសង្គម និងបរិស្ថាន

ជំពូកនេះពិពណ៌នាអំពីលទ្ធផលនៃការត្រួតពិនិត្យដំបូងនៃផលប៉ះពាល់លើវិស័យសង្គម និងបរិស្ថាន (Initial Examination of Environmental and Social Impact (IEE)) របស់ផែនការមេ ដោយយោងតាម "ការណែនាំសំរាប់ការត្រួតពិនិត្យដំបូងសំរាប់ការពិចារណាទៅលើសង្គម និងបរិស្ថានរបស់ JICA (២០០៤)" និងក្របខ័ណ្ឌច្បាប់កម្ពុជា ។

ទី១ : ការវិភាគជំរើសដែលជាផ្នែកមួយនៃការត្រួតពិនិត្យដំបូងនៃផលប៉ះពាល់លើវិស័យសង្គម និងបរិស្ថានត្រូវបានធ្វើឡើងដោយមិនរាប់បញ្ចូលស្ថានភាពគំរោងនៅកំរិតសេណារីយូ និងកំរិតសមាសភាពគំរោងឡើយ ។ ផែនការដែលឈរលើមូលដ្ឋានសេណារីយូ ដែលគាំទ្រដល់និរន្តរភាពដូចមានលើកឡើងក្នុងផែនការមេគឺមានលក្ខណៈសមស្របបំផុតខាងនិរន្តរភាពយូរអង្វែងនៃបរិស្ថាន និងសេដ្ឋកិច្ច-សង្គម ។

*ការវិភាគកំរិតសមាសភាពគំរោងត្រូវបានធ្វើឡើងសំរាប់គំរោងក្នុងវិស័យធនធានទឹក និងការផ្គត់ផ្គង់ទឹកប្រពន្ធ័បង្ហូរទឹកភ្លៀង និងប្រពន្ធ័បង្ហូរសំណល់រាវ និងថាមពល* ពីព្រោះគំរោងទាំងអស់នេះអាចមានឥទ្ធិពលធំធេង ។ សមាសភាពគំរោងដែលបានស្នើឡើងមានភាពសមស្រប បើពិនិត្យទៅលើផលប៉ះពាល់ដល់បរិស្ថាន និងសង្គម មូលដ្ឋានធនធាន ការធ្វើឱ្យសំរេចជោគជ័យ និងការចំណាយ ។

ទី២ : មានការកំណត់វិសាលភាពនៃផលប៉ះពាល់លើសង្គម និងបរិស្ថានដែលបានស្មានក្នុងផែនការមេ ។ ដូចនេះផលប៉ះពាល់ទាំងនេះត្រូវបានត្រួតពិនិត្យដោយស្នើឱ្យមានវិធានការកាត់បន្ថយផលប៉ះពាល់ ផែនការត្រួតពិនិត្យ និងសមត្ថភាពស្ថាប័នសំរាប់ការងារ EIA នេះ ។

នៅក្នុងដំណើរការរៀបចំផែនការមេ ក្រុមសិក្សា JICA និងក្រុមការងារសមភាគីបានរៀបចំកិច្ចប្រជុំមួយចំនួនជាបន្តបន្ទាប់ជាមួយភាគីពាក់ព័ន្ធដើម្បី (១) បញ្ជូនគំនិត និងយោបល់របស់គេទៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត (២) មតិឯកភាពគ្នាលើផែនការមេ និង (៣) ផ្សព្វផ្សាយព័ត៌មាននៃលទ្ធផលការសិក្សាទៅដល់សាធារណជន ។

*ផ្នែកនានាខាងក្រោមរាយការណ៍ពីភាពចាំបាច់នៃIEE ដែលជាផលប៉ះពាល់ដែលបានព្យាករណ៍ទុករបស់ផែនការមេ* ទៅលើបរិស្ថាន និងសង្គម និងផែនការដែលបានស្នើឡើងសំរាប់កាត់បន្ថយផលប៉ះពាល់ទាំងនោះ ។

## ៨.១ ភាពចាំបាច់នៃលក្ខខណ្ឌបរិស្ថាន និងសង្គម

អនុក្រឹត្យស្តីពីដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថានតំរូវការការវាយតំលៃផលប៉ះពាល់បរិស្ថានដំបូង (IEIA) ឬការវាយតំលៃផលប៉ះពាល់បរិស្ថានសំរាប់គំរោង (EIA) ។ រាល់គំរោង និងសកម្មភាពនានាដែលបានរាយក្នុងបញ្ជីតំរូវឱ្យមានការធ្វើ IEIA/EIA បើទោះបីគំរោង ឬសកម្មភាពទាំងនោះជារបស់សាធារណៈ ឬក៏ឯកជនក៏ដោយ ។

តាមរយៈការត្រួតពិនិត្យរបាយការណ៍ EIA ក្រសួងបរិស្ថានត្រូវវិនិច្ឆ័យថាតើការធ្វើ EIA គឺជាការចាំបាច់ ឬយ៉ាងណា ។ ម្ចាស់គំរោង ឬសកម្មភាពត្រូវទទួលបន្ទុកថ្លៃសំរាប់ការធ្វើ IEIA/ EIA ។ ការចូលរួមពីសាធារណជន ការវាយតំលៃជំរើសផ្សេងៗ និងវិធានការកាត់បន្ថយផលប៉ះពាល់ ការពិពណ៌នាគំរោងលំអិត គុណភាពបរិស្ថានបច្ចុប្បន្ន និងលទ្ធផលនៃការវាយតំលៃបរិស្ថាន និងសង្គមគួរដាក់បញ្ចូលទៅក្នុងរបាយការណ៍ IEIA/EIA ។

យោងតាមការវាយតំលៃដែលធ្វើឡើងដោយការិយាល័យត្រួតពិនិត្យគំរោងរបស់នាយកដ្ឋានវាយតំលៃផលប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ការសិក្សាផែនការមេនេះមិនតំរូវឱ្យធ្វើ EIA ទេ។ EIA អាចត្រូវត្រូវធ្វើ នៅពេលគំរោងនីមួយៗនៃគំរោងដែលបានស្នើឡើងស្ថិតក្នុងដំណាក់កាលអនុវត្ត។ ការត្រួតពិនិត្យដំបូងនៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃផែនការមេត្រូវបានធ្វើឡើងស្របទៅតាម "គោលការណ៍ណែនាំសំរាប់ការពិចារណាបរិស្ថាន និងសង្គមរបស់ JICA ។

## ៨.២ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមដែលបានព្យាករណ៍

*មានការកំណត់វិសាលភាពនៃផលប៉ះពាល់លើបរិស្ថាន និងសង្គមដែលបានព្យាករណ៍ជាមុនក្នុងការសិក្សានៅ*ដំណាក់កាលនេះ។ សេចក្តីសង្ខេបនៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានព្យាករណ៍ជាមុន ដែលជាផ្នែកមួយនៃលទ្ធផលនៃការកំណត់វិសាលភាព និងវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នានជាមុន គឺជាការត្រួតពិនិត្យដំបូងលើផលប៉ះពាល់បរិស្ថាននៃការសិក្សានៅក្នុងដំណាក់កាលនេះមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ២៣ : សេចក្តីសង្ខេបនៃផលប៉ះពាល់នៃគំរោងគំរោងទាំងអស់**

| ឈ្មោះគំរោងសហប្រតិបត្តិការ | | ការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសៀមរាប/ ក្រុងអង្គរក្នុងព្រះរាជាណាចក្រកម្ពុជា | | |
|---|---|---|---|---|
| ផលប៉ះពាល់ដែលអាចកើតមាន | ការវាយតម្លៃ | ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ (ឧទាៈ ទំហំ វិសាលភាពតំបន់ រយៈពេល ភាពញឹកញាប់ ការត្រឡប់ទៅភាពដើម និងការបំភ្លឺមជីវិតនៃការកើតឡើង | វិធីសាស្ត្រប្រើប្រាស់ដើម្បីព្យាករណ៍ | វិធានការកាត់បន្ថយផលប៉ះពាល់ដែលសន្មត់ |
| ដំណើរការបំលាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត | គ | ការសាងផ្លូវថ្នល់ រោងចក្រធ្វើប្រព្រឹត្តិកម្មទឹក ឬ សំណល់រាវ កន្លែងចាក់សំរាមត្រូវការទិញដី (សូមមើលរូបថតខាងក្រោម)។ ការធ្វើប្រព្រឹត្តិកម្មទឹក ឬ សំណល់រាវ និងកន្លែងចាក់សំរាមនឹងត្រូវធ្វើឡើងក្នុងតំបន់ដាច់ផុះ។ ហេតុដូច្នេះ គេរំពឹងថា ការមាននៃដំណើរការបំលាស់ទីលំនៅនៅមានកំរិតទាប។ | • ការត្រួតពិនិត្យផែនទីសំរាប់ទីតាំងគំរោង<br>• ការអង្កេតដល់កន្លែងផ្ទាល់ | • ការជ្រើសរើស ឬកំណត់ទីតាំងដោយប្រយ័ត្នប្រយែង សំរាប់គំរោងពាក់ព័ន្ធដើម្បីបង្ការកុំឱ្យមានការបំលាស់លំនៅឱ្យបានច្រើនទៅតាមលទ្ធភាព<br>• ប្រសិនបើការតាំងទីលំនៅជាថ្មីចៀសមិនរួច ផែនការតាំងទីលំនៅជាថ្មីដោយមានកិច្ចព្រមព្រៀងពីអ្នកពាក់ព័ន្ធចាំបាច់ត្រូវកំណត់ដើម្បីបញ្ចៀស ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ |
| សេដ្ឋកិច្ចមូលដ្ឋាន | ខ | • ដីកសិដ្ឋាននៅតាមព្រំប្រទល់រវាងឃុំជ្រាវ និងឃុំសៀមរាបគឺជាកន្លែងត្រូវស្នើសុំសំរាប់រោងចក្រធ្វើប្រព្រឹត្តិកម្មសំណល់រាវមានទំហំ ១៥ហត បើទោះបីជាទីតាំងពិតប្រាកដមួយមិនត្រូវបានកំណត់ក៏ដោយ។ | • ការអង្កេតពីប្រាក់ចំណូលរបស់ប្រជាកសិករ និងភាពជាម្ចាស់ដីនៅតំបន់ស្នើសុំ | • ការពិចារណាដោយប្រយ័ត្នប្រយែងសំរាប់ការកំណត់ទីកន្លែងដើម្បីធ្វើឱ្យមានផលប៉ះពាល់តិច។<br>• ការពិចារណា និងការអនុវត្តន៍នៃការទូទាត់ដែលសមរម្យ និងការធានាការងារសំរាប់អ្នកស្រុកដែលពាក់ព័ន្ធ។ |
| បេតិកភណ្ឌវប្បធម៌ | ខ | • លទ្ធភាពនៃការបង្កផលប៉ះពាល់មានកំរិតទាប ប៉ុន្តែសកម្មភាពសាងសង់សំរាប់គំរោង | • ការអង្កេតដល់កន្លែង | • ធ្វើការអង្កេតផ្នែកបុរាណវត្ថុ មុនពេលចាប់ផ្តើមការសាងសង់។ (សូមមើលរូប |

| | | | | |
|---|---|---|---|---|
| | | ដែលបានស្នើសុំអាចជះឥទ្ធិពលលើបេតិកភណ្ឌវប្បធម៌នៅ ក្រោមដី ។ | • ការអង្កេតផ្តែតបុរាណវត្ថុ | ខាងក្រោមសំរាប់ការចែកតំបន់› |
| ជម្លោះផលប្រយោជន៍មូលដ្ឋាន | ខ | • ជម្លោះផលប្រយោជន៍ លើភាពជាម្ចាស់ដីត្រូវគេរំពឹងថាកើតមាននៅក្នុងតំបន់ទាក់ទងនឹងផែនការប្រើប្រាស់ដីថ្មីដែលបានស្នើឡើង ។ | • ប្រជុំជាមួយអ្នកពាក់ព័ន្ធ | • ការប្រជុំ និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធឱ្យបាន គ្រប់គ្រាន់គួរធ្វើឡើង មុនពេលផែនការមេត្រូវបញ្ចប់ ។ |
| ការប្រើប្រាស់ទឹក ឬសិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ | ខ | • ប្រសិនបើការសំរបសំរួលមិនត្រូវបានធ្វើក្នុងចំណោមការិយាល័យរដ្ឋបាល ផលប៉ះពាល់នឹងធ្ងន់ធ្ងរ ហើយលំបាកស្តារឡើងវិញ ។ | • ប្រជុំជាមួយអ្នកពាក់ព័ន្ធ | • ការសំរបសំរួលដោយប្រយ័ត្នប្រយែងចាំបាច់ត្រូវធ្វើឱ្យសំរេចរាប់បញ្ចូលទាំងគំរោងសំរាប់ការអភិវឌ្ឍន៍ធនធានទឹកនៅក្នុងផែនការមេ ។ |
| ទឹកក្រោមដី | ខ | • ទឹកក្រោមដីអាចធ្វើអោយកខ្វក់ដោយទឹកសំណល់នៅដំណាក់កាលសាងសង់នៃគំរោងដែលបានស្នើឡើង ។ សំណល់រាវហូរពីកន្លែងចាក់សំរាម ដែលបានស្នើឡើងអាចហូរចូលទៅក្នុងទឹកក្រោមដី ។ | • ការអង្កេតភូគព្ភសាស្ត្រ ជលសាស្ត្រ និងការធ្វើតេស្តិ៍បូមទឹក | • វិធានការសមរម្យដើម្បីការពារការធ្វើឱ្យបំពុលទឹកក្រោមដីនៅដំណាក់កាលសាងសង់ |
| ស្ថានភាពជលសាស្ត្រ | ខ | • ស្តារដី ឬការដាក់ទ្វារទឹកនឹងជះឥទ្ធិពលដល់ជលសាស្ត្របឹងសៀមរាប ។ | • ការអង្កេត និងការស្វែងយល់ជលសាស្ត្រ | • វិធានការនានាចាំបាច់ត្រូវពិចារណាដើម្បីធ្វើឱ្យផលប៉ះពាល់តិចតួចលើស្ថានភាពជលសាស្ត្រនៃស្ទឹងសៀមរាប ។ |
| រុក្ខជាតិ សត្វ និងជីវចំរុះ | ខ | • គ្មានពពួកសត្វដែលរងគ្រោះថ្នាក់ត្រូវបានគេរាយការណ៍ទេនៅក្នុងតំបន់សិក្សា ( មិនរាប់បញ្ចូលបឹងទន្លេសាប) ។ បន្ថែមពីលើនេះ ទីតាំងគំរោងដែលបានស្នើនឹងស្ថិតនៅលើដីជាដុះ ។ ហេតុដូច្នេះ ផលប៉ះពាល់មានកំរិត ។ | • ការប្រមូលព័ត៌មាន<br>• ការអង្កេតស៊ីជំរៅដល់កន្លែង | • ប្រសិនបើគំរោងស្នើសុំត្រូវបានរកឃើញថាមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើរុក្ខជាតិ សត្វ និងជីវចំរុះ គំរោងគួរត្រូវបញ្ឈប់ និងពិចារណាឡើងវិញ ។ ការពិចារណាដោយប្រុងប្រយ័ត្នគួរត្រូវធ្វើឡើងសំរាប់ផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ។ |
| កំដៅពិភពលោក | ខ | • ផលប៉ះពាល់មានកំរិតដោយធ្វើការវិនិច្ឆ័យពីវិសាលភាពនៃគំរោង ។ គំរោងខ្លះនឹងជួយកែលំអប្រសិទ្ធភាពនៃថាមពលនៅក្នុងតំបន់សិក្សា ។ | • ការប៉ាន់ស្មានទៅលើទំហំនៃការភាយចេញឧស្ម័នផ្ទះកញ្ចក់ | • វិធានការសមរម្យគួរពិចារណាសំរាប់គំរោងផ្គត់ផ្គង់ថាមពលក្នុងផែនការមេដើម្បីកាត់បន្ថយការ ភាយចេញឧស្ម័នផ្ទះកញ្ចក់ឱ្យដល់កំរិតអប្បបរមា<br>• ប្រសិទ្ធភាព និងការប្រើប្រាស់ថាមពលនៃថាមពលធម្មជាតិគួរពិចារណាសំរាប់គំរោងផ្គត់ផ្គង់ថាមពល |
| ការបំពុលបរិយាកាស | ខ | • ផលប៉ះពាល់មានកំរិតដោយធ្វើការវិនិច្ឆ័យពីគុណភាពបរិយាកាសបច្ចុប្បន្ន និងការកើនឡើងទំហំនៃការភាយចេញនៃសារធាតុបំពុលបរិយាកាសត្រូវបានព្យាករណ៍ ។ | • ការប៉ាន់ស្មាននៃអាំងតង់ស៊ីតេការបំពុល | • យកដីគ្របកន្លែងចាក់សំរាមប្រចាំថ្ងៃដើម្បីបង្ការអគ្គីភ័យ<br>• គ្របសំភារៈសំណង់អោយបានសមរម្យ និងការបាញ់ទឹកផ្លូវថ្នល់នៅដំណាក់កាលសាងសង់នៃគំរោងដែលបានស្នើឡើង ។ |

| | | | | |
|---|---|---|---|---|
| | | | | • ការថែរក្សាអោយបានសមរម្យនៃសំភារៈសំណង់ និងយានយន្ត និងការសាងសង់ដែលត្រូវបានកំណត់ពេលជាយថាហេតុ ។ |
| ការបំពុលទឹក | ខ | • គំរោងធ្វើប្រព្រឹត្តិកម្មសំណល់រាវអាចធ្វើឱ្យធ្លាក់ចុះគុណភាពទឹកស្ទឹងសៀមរាបនៅពេលបញ្ហាប្រតិបត្តិ ។ ទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាមអាចធ្វើឱ្យកខ្វក់បឹងឬទន្លេនៅក្បែរនោះ ប្រសិនបើវាមិនត្រូវបានធ្វើប្រព្រឹត្តិកម្មសមរម្យ ។ | • ការអង្កេតដល់ទីកន្លែង ( រាប់បញ្ចូលការអង្កេតរោង-លេខាសាស្ត្រ) | • ការគ្រប់គ្រងអោយបានសមរម្យនៃទឹកសំណល់ហូរចេញអំឡុងពេលសាងសង់ ។<br>• ការធ្វើប្រព្រឹត្តិកម្មនៃទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាម ។<br>• ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចតាមពេលកំណត់នៃសំភារៈធ្វើប្រព្រឹត្តិកម្មទឹក ។ |
| ការធ្វើឱ្យដីកខ្វក់ | ខ | • ដីស្រទាប់លើអាចធ្វើអោយគ្រខ្វក់ដោយសំភារៈសំណង់ និងសំណល់សំណង់<br>• ទឹកសំណល់ហូរពីកន្លែងចាក់សំរាមដែលបានស្ទើឡើងអាចជ្រាបចូលទៅក្នុងដី ឬធ្វើអោយកខ្វក់ដីស្រទាប់លើនៅដំណាក់កាលប្រតិបត្តិ | • ការអង្កេតភូគព្ភសាស្ត្រ | • ការធ្វើអធិការកិច្ចសំភារៈសំណង់ជាមុន<br>• ការធ្វើប្រព្រឹត្តិកម្មទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាម និងការកសាងប្រព័ន្ធធ្វើប្រព្រឹត្តិកម្មដាច់ដោយឡែកសំរាប់សំណល់ដែលបង្កគ្រោះថ្នាក់ និងជំងឺ |
| សំណល់ | ខ | • នឹងមានសំណល់មួយចំនួន នៅពេលមានការអនុវត្តន៍គំរោងដែលបានស្នើឡើង<br>• កន្លែងធ្វើប្រត្តិកម្មសំណល់រាវដែលបានស្នើឡើងនឹងបញ្ចេញទឹកសំណល់ដែលបានធ្វើប្រត្តិកម្ម និងសំណល់ភក់ | • ការពិនិត្យឡើងវិញនៃសមត្ថភាពនៃកន្លែងចាក់សំរាមដែលមានស្រាប់និងប្រព័ន្ធប្រមូលសំណល់ | • ការបង្កើតប្រព័ន្ធប្រមូលសំណល់សំណង់សមរម្យ<br>• ការធានាកន្លែងចាក់សំណល់សមរម្យ |
| សំលេង និង ភាពញ័រ | ខ | • កំរិតនៃសំលេងនិងភាពញ័រនឹងកើនឡើងក្នុងកំរិតមួយធំក្នុងកន្លែងខ្លះនៃតំបន់សិក្សា ប្រសិនបើមានការអនុវត្តគំរោង ដូចជាការដឹកជញ្ជូន និងសំភារៈសំណង់ ។ | • ការអង្កេតលើទីតាំងគំរោង | • ធានាថា សំភារៈសំណង់មានសភាពល្អ ដើម្បីធ្វើអោយសំលេង និងភាពញ័រតូច<br>• ការកំនត់ពេល/ការធ្វើផែនការ/ការគ្រប់គ្រងការសាងសង់អោយបានសមរម្យ |
| ការស្រុតដី | គ | • ផលប៉ះពាល់ទៅលើការស្រុតដីមិនទាន់មានភាពច្បាស់នៅឡើយនៅដំណាក់កាលនេះ ។<br>• នៅពេលចាប់ផ្តើមអនុវត្តការអភិវឌ្ឍន៍ទឹកក្រោមដី ពេលនោះលទ្ធភាពនៃការត្រឡប់វិញនៃផលប៉ះពាល់ អវិជ្ជមានមានកំរិតទាប ។ | • ការអង្កេតភូគព្ភសាស្ត្រ ជលសាស្ត្រ<br>• ការស្វែងយល់ពីការធ្លាក់ចុះទឹកក្រោមដី<br>• តេស្តិ៍បូមទឹក | • ប្រសិនបើផលប៉ះពាល់អវិជ្ជមានត្រូវគេប្រមើលមើលឃើញ គំរោងគួរត្រូវបញ្ឈប់ និងពិចារណាឡើងវិញ |
| ក្លិនស្អុយ | ខ | • ក្លិនស្អុយអាចកើតមានឡើងពីសំណល់សរីរាង្គដែលបំបែកធាតុនៅកន្លែងចាក់សំរាម<br>• ក្លិនស្អុយដែលអាចកើតពីសំណល់រាវ បន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្ម និងសំណល់ភក់ពីកន្លែង | • ការអង្កេតលើទីតាំងគំរោង | • ទីតាំងនៃកន្លែងចាក់សំរាម ឬសំភារៈធ្វើប្រព្រឹត្តិកម្មសំណល់រាវគួរពិចារណាដោយប្រុងប្រយ័ត្ន ។<br>• ការគ្របដីគួរធ្វើនៅកន្លែងចាក់សំរាម |

| | | | |
|---|---|---|---|
| | | ធ្វើប្រព្រឹត្តិកម្មដែលបានស្នើឡើង ប្រសិនបើមិនបានថែទាំងឱ្យបានសមស្រប ។ | ប្រចាំថ្ងៃ ។<br>• ការថែទាំតាមកាលកំណត់នៃការធ្វើប្រព្រឹត្តិកម្មសំណល់រាវ |

**កំណត់ចំណាំ :** លក្ខណវិនិច្ឆ័យនៃការកំណត់កំរិតបំពុល

ក : *អាចមានផលប៉ះពាល់ធ្ងន់ធ្ងរ*

ខ : អាចមានផលប៉ះពាល់មួយចំនួន

គ : មិនដឹងពីកំរិតនៃផលប៉ះពាល់ ( តំរូវការឱ្យមានការត្រួតពិនិត្យ ។ ផលប៉ះពាល់អាចមានភាពច្បាស់លាស់ នៅពេលមានការសិក្សា)

## ៨.៣ ផែនការកាត់បន្ថយផលប៉ះពាល់ពីផែនការមេដែលបានព្យាករណ៍

ផែនការកាត់បន្ថយផលប៉ះពាល់មួយចាំបាច់ត្រូវកសាងឡើងវិញដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមដែលបណ្តាលមកពីការអនុវត្តន៍គំរោងដែលបានស្នើឡើង ។ ផែនការនេះបង្កើតឡើងដើម្បីផ្តល់ការអធិការកិច្ច និងការត្រួតពិនិត្យលើលក្ខខណ្ឌបរិស្ថាន ឬសង្គម និងវិធានការកាត់បន្ថយផលប៉ះពាល់ក្នុងអំឡុងពេលមុនការសាងសង់ ក្នុងពេលសាងសង់ និងក្នុងពេលពេលប្រតិបត្តិ ។

EIA/IEIA លើគំរោងនីមួយៗនៃគំរោងដែលបានស្នើឡើងនៅក្នុងផែនការមេនេះត្រូវធ្វើឡើងក្នុងអំឡុងពេលសិក្សាលទ្ធភាពអនុវត្តគំរោង និងគំរោងលំអិត ប្រសិនជាតំរូវការរបស់ក្របខ័ណ្ឌស្របច្បាប់លើលក្ខ័ណ្ឌបរិស្ថាន និងសង្គមក្នុងប្រទេសកម្ពុជា ។

### ៨.៣.១ វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន

### ១. អំឡុងពេលមុនការសាងសង់

### ១)ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ដើម្បីជៀសវាងជំលោះផលប្រយោជន៍នៅមូលដ្ឋានចាប់ពីដំណាក់កាលដំបូង ការពិគ្រោះយោបល់នានាជាមួយអ្នកពាក់ព័ន្ធរួមទាំងម្ចាស់ដីដែលមានទំហំដីតូច នឹងត្រូវបានរៀបចំឡើង ដើម្បីធានាថា ភាគីពាក់ព័ន្ធទាំងអស់យល់ព្រមចំពោះផែនការប្រើប្រាស់ដីដែលបានស្នើឡើងក្នុងផែនការមេ ។

### ២)ការជ្រើសរើសទីកន្លែងដោយប្រុងប្រយ័ត្នសំរាប់គំរោងនីមួយៗ

ទីកន្លែងសំរាប់គំរោងនីមួយនៃគំរោងដែលបានស្នើឡើងគួរត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយការផ្លាស់ប្តូរទីកន្លែងឱ្យនៅកំរិតអប្បបរមា និងបញ្ចៀសការតាំងទីលំនៅជាថ្មីដោយគ្មានការស្ម័គ្រចិត្ត ជាពិសេស ក្នុងករណីនៃគំរោងដែលត្រូវការទំហំដីធំទូលាយដូចជា កន្លែងធ្វើប្រព្រឹត្តិកម្មសំណល់រាវ កន្លែងធ្វើប្រព្រឹត្តិកម្មទឹក និងការសាងសង់ផ្លូវ ។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានភាពចាំបាច់សំរាប់ដំណើរការជ្រើសរើសទីកន្លែង ។ ប្រសិនបើការតាំងទីលំនៅឡើងវិញមិនអាចជៀសផុត នោះចាំបាច់បង្កើតផែនការតាំងទីលំនៅ និងបង់តំលៃសងសមរម្យដោយមានកិច្ចព្រមព្រៀងពីភាគីពាក់ព័ន្ធ ។



ទីតាំងដែលបានស្នើសំរាប់កន្លែងធ្វើប្រព្រឹត្តិកម្មសំណល់រាវ



ការកាន់កាប់ខុសច្បាប់នៅក្បែរស្ទឹងសៀមរាបខាងត្បូងមណ្ឌលក្រុង

## ៣) ការអង្កេតបុរាណវិទ្យា

តំបន់សិក្សាគ្របដណ្តប់តំបន់ការពារវប្បធម៌ដែលបានកំណត់ដោយព្រះរាជក្រឹត្យ និងការវាយតំលៃលើផលប៉ះពាល់លើវត្ថុបុរាណត្រូវធ្វើឡើងជាចាំបាច់សំរាប់គំរោងដែលស្នើក្នុងតំបន់ការពារមុនការអនុវត្តន៍គំរោង។ ដូច្នេះការ អង្កេតបុរាណវិទ្យាចាំបាច់ត្រូវធ្វើឡើង ក្នុងអំឡុងពេលមុនការសាងសង់។ នៅពេលមានរបាយការណ៍ពីការរកឃើញពីសារៈសំខាន់ខាងបុរាណវិទ្យានោះ វិធានការសមស្របចាំបាច់ត្រូវតែអនុវត្ត។




ប្រភព : គេហទំព័រអប្សរា (http://www.autoriteapsara.org/images/apsara/about_apsara/zoning/ zoning_map.jpg)

រូបទី ៦៨ : តំបន់ការពារវប្បធម៌ក្នុងតំបន់សៀមរាបអង្គរ

**៤)ការធានាជំរើសការងារសំរាប់ម្ចាស់ដីក្នុងតំបន់គំរោង**

ត្រូវធានាឱ្យមានជំរើសការងារផ្សេងៗ មានន័យថាតើបើម្ចាស់ដីក្នុងទីតាំងគំរោងត្រូវទទួលបានប្រាក់ចំណូលដោយផ្ទាល់ពីសកម្មភាពនៅលើដីនោះឬទេ។ វិធានការនេះគួរអនុវត្ត ប្រសិនបើមានការទិញដូរដីនោះដោយផ្អែកលើកិច្ចព្រមព្រៀងដើម្បីជួយដល់គ្រួសារក្រីក្រ។

**៥)ការធ្វើពិសោធន៍សាកល្បងនូវគុណភាពទឹកក្រោមដី**

ភាពសមរម្យនៃទឹកក្រោមដីក្បែរបឹងទន្លេសាបសំរាប់ផឹក ត្រូវតែធ្វើពិសោធន៍សាកល្បងដោយការជីកអណ្តូងមួយចំនួនសំរាប់ធ្វើពិសោធន៍សាកល្បង។ មានការធ្វើពិសោធន៍សាកល្បងគុណភាពទឹកក្រោមដីនៅឃុំចុងឃ្នៀសក្បែរបឹងទន្លេសាប ក្នុងឆ្នាំ២០០០ ហើយលទ្ធផលបានបង្ហាញថា គុណភាពទឹកឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់អង្គការសុខភាពពិភពលោក ក៏ប៉ុន្តែគួរមានការស្រាវជ្រាវម្តងទៀត ដោយរួមបញ្ចូលទាំងការធ្វើពិសោធន៍សាកល្បងលើអាសេនិកផង។

**៦)ការអង្កេតភូគព្ភសាស្ត្រជលសាស្ត្រ**

ការសិក្សាភូគព្ភសាស្ត្រជលសាស្ត្រដោយរួមបញ្ចូលការធ្វើពិសោធន៍សាកល្បងបូមទឹក ចាំបាច់ត្រូវធ្វើឡើងដើម្បីវាយតំលៃឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រុងប្រយ័ត្នអំពីផលប៉ះពាល់ដល់ស្រទាប់ទឹកក្រោមដី និងការស្រុតចុះដីមុននឹងអនុវត្តគំរោងអភិវឌ្ឍន៍ធនធានទឹក។ ការសិក្សាពីជលសាស្ត្រចាំបាច់ត្រូវធ្វើឡើងសំរាប់គំរោងនានាដោយមានការប៉ាន់ស្មានផលប៉ះពាល់អវិជ្ជមាននៅតាមស្ទឹង និងអាងផ្ទុកទឹក។

**៧)ការសំរបសំរួលអន្តរក្រសួងលើការប្រើប្រាស់ទឹក**

ប្រទេសកម្ពុជាពុំមានបង្កើតច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗសំរាប់បែងចែកទឹកតាមវិស័យឡើយ។ ដូច្នេះ ចាំបាច់ត្រូវធានាឱ្យមានការសំរបសំរួលអន្តរក្រសួងដើម្បីបញ្ចៀសជំលោះ និងបន្តអនុវត្តឱ្យបានរលូនដោយរាប់បញ្ចូលទាំងគំរោងអភិវឌ្ឍន៍ធនធានទឹក។

**៨)ការអង្កេតភូគព្ភសាស្ត្រនៅលើដី**

ចាំបាច់ត្រូវធ្វើការអង្កេតភូគព្ភសាស្ត្រលើដីនៃទឹកខ្វែងចោលសំណល់ ដើម្បីត្រួតពិនិត្យកំរិតនៃការជ្រាបទឹក។ គួរយកលទ្ធផលនៃការអង្កេតសំរាប់ការពិចារណាលើវិធានការធ្វើប្រព្រឹត្តិកម្មទឹកសំណល់ដែលហូរចេញពីកន្លែងកប់សំរាមដែលមានអនាម័យដែលបានស្នើឡើង។

**៩)ការអង្កេតបរិយាកាស**

គួរធ្វើការសិក្សាអំពីទិសខ្យល់ ល្បឿនខ្យល់ និងស្ថិរភាពបរិយាកាស ហើយគួរតែបំបែកបរិយាកាសនៃសារធាតុពុល ដើម្បីវាយតំលៃផលប៉ះពាល់ឱ្យបានត្រឹមត្រូវនូវការភាយចេញនៃ $SO_x$ និង $NO_x$ ពីគំរោងដែលបានស្នើសុំដើម្បីពង្រីកការផ្គត់ផ្គង់ថាមពល។

## ២. អំឡុងពេលនៃការសាងសង់

**១) វិធានការកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពសាងសង់**

ចាំបាច់ចាត់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានអវិជ្ជមានទូទៅ ក្នុងអំឡុងពេលនៃការសាងសង់ដូចមានពិពណ៌-

នាខាងក្រោម :

**ការគ្រប់គ្រងសម្ភារៈសំណង់ឱ្យបានសមរម្យ**

គួរត្រួតពិនិត្យការបំពុលបណ្ដាលមកពីសម្ភារៈសាងសង់ក្នុងការរៀបចំកន្លែងសាងសង់ និងការសាងសង់ផ្លូវ មុនពេលប្រើប្រាស់សម្ភារៈទាំងនោះដើម្បីបញ្ចៀសការបំពុលដី។ លើសនេះទៀត គួរគ្របសម្ភារៈទាំងនោះឱ្យបានសមរម្យ ដើម្បីកាត់បន្ថយការហុយធូលី និងកំទេចផ្សេងៗឱ្យនៅកំរិតអប្បបរមា។ គួរធ្វើការគ្រប់គ្រងសារធាតុពុល ឬគ្រោះថ្នាក់ផ្សេងៗដោយប្រុងប្រយ័ត្នដើម្បីទប់ស្កាត់ការលាយបញ្ចូលគ្នានៃសារធាតុទាំងនោះ និងហូរតាមទឹកភ្លៀង។

**ការបាញ់ទឹកលើផ្លូវថ្នល់**

ធូលីពីសកម្មភាពសាងសង់ត្រូវកាត់បន្ថយជាចាំបាច់ដោយបាញ់ទឹកលើផ្លូវនៃកន្លែងសាងសង់ ជាពិសេសនៅក្នុងរដូវប្រាំង។

**ការដឹកទាំសម្ភារៈសំណង់ និងយានយន្តឱ្យបានសមរម្យ**

គួរធ្វើការកាត់បន្ថយដល់កំរិតអប្បបរមានូវសំលេង ការបំភាយឧស្ម័ន និងក្លិនពីសកម្មភាពសាងសង់នានាតាមរយៈការដឹកទាំសម្ភារៈសំណង់ និងយានយន្តឱ្យបានសមស្រប។

**ការគ្រប់គ្រងទឹកពីការដ្ឋានសំណង់**

ចាំបាច់ត្រូវមានវិធានការសមស្របដើម្បីគ្រប់គ្រងទឹកពីការដ្ឋានសំណង់ដើម្បីបញ្ចៀសការបំពុលផ្លូវទឹកនៅក្បែរការដ្ឋាននោះ។

**ការបង្កើតប្រព័ន្ធប្រមូលសំណល់សំណង់ (រួមបញ្ចូលការធានាដល់ទីកន្លែងបោះចោលសមរម្យ)**

បើទោះបីបរិមាណសំណល់មិនអាចប៉ាន់ស្មាននៅដំណាក់កាលនេះក៏ដោយ គំរោងដែលបានស្នើឡើងនឹងមានបញ្ចេញបរិមាណសំណល់យ៉ាងច្រើន។ ដើម្បីទប់ស្កាត់ការបោះចោលសំណល់សំណង់ខុសច្បាប់ និងសំរួលដល់ការគ្រប់គ្រងសំណល់ឱ្យបានសមរម្យចាំបាច់ត្រូវបង្កើតប្រព័ន្ធប្រមូលសំណល់ និងកន្លែងចោលសំណល់សមរម្យ។

**ការកំណត់ពេល/ការធ្វើផែនការ/ការគ្រប់គ្រងការសាងសង់ឱ្យបានសមរម្យ**

ដើម្បីរក្សាលំហូរចរាចរណ៍នៅក្បែរការដ្ឋានសាងសង់ឱ្យដំណើរការធម្មតា ចាំបាច់កំណត់ពេលវេលា និងការធ្វើផែនការសាងសង់ដោយប្រុងប្រយ័ត្ន ដោយមានដាក់អ្នកត្រួតចរាចរណ៍នៅកន្លែងសមរម្យ។ ការធានានូវផ្លូវជំរើសផ្សេងដោយ មានការគ្រប់គ្រងចរាចរឱ្យបានសមរម្យក្នុងអំឡុងពេលខ្លះក្នុងដំណាក់កាលសាងសង់ត្រូវពិចារណា ប្រសិនបើមានភាពចាំបាច់។ វិធានការនេះនឹងរួមចំណែកដល់ការកាត់បន្ថយផលប៉ះពាល់នៃសំលេង និងភាពញ័របណ្ដាលមកពីសកម្មភាពសាងសង់ និងដើម្បីបន្ថយការភាយចេញនៃឧស្ម័នផ្ទះកញ្ចក់។

**ការបំពាក់ជញ្ជាំងខ្ទប់សំលេង ឬតំបន់ទ្រនាប់**

គួរពិចារណាកាត់បន្ថយសំលេង ឬភាពញ័រដោយសកម្មភាពសាងសង់ដោយការបំពាក់ជញ្ជាំងខ្ទប់សំលេង ឬបង្កើតតំបន់ទ្រនាប់ប្រសិនបើកន្លែងផ្ដល់សេវាកម្មសង្គមស្ថិតនៅក្បែរការដ្ឋានសាងសង់។

### ២) នីតិវិធីសមរម្យសំរាប់ស្រាវជ្រាវវត្ថុបុរាណ

អ្នកម៉ៅការសំណង់ចាំបាច់ត្រូវបញ្ឈប់សកម្មភាពសាងសង់ភ្លាម ប្រសិនបើមានការរាយការណ៍ពីការរកឃើញបុរាណវត្ថុ។ ចាំបាច់ត្រូវការអង្កេតពីការរកឃើញនោះដោយអ្នកបុរាណវិទ្យាប្រសិនបើចាំបាច់ ហើយចាត់វិធានការស្រោចស្រង់វត្ថុបុរាណនោះ។

### ៣) ការកែប្រែតំបន់រងការប៉ះពាល់ដោយការសាងសង់ទៅភាពភូខណ្ឌដើមវិញ

ចាំបាច់ត្រូវស្រោចស្រង់តំបន់ទាំងអស់ដែលរងផលប៉ះពាល់ពីការអនុវត្តគំរោងឱ្យដូចលក្ខខណ្ឌដើមវិញ បន្ទាប់ពីសកម្មភាពសាងសង់ត្រូវបានបញ្ចប់រួចរាល់។ ត្រូវការយកចេញ ឬយកទៅចោលឱ្យបានសមរម្យនូវសម្ភារៈសាងសង់ គ្រឿងចក្រ និងយានយន្តទាំងអស់។

## ៣. អំឡុងពេលប្រតិបត្តិ

ចាំបាច់ត្រូវពិចារណា និងអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នានាក្នុងអំឡុងពេលនៃការអនុវត្តន៍គំរោងនីមួយៗ។ វិធានការទាំងនោះត្រូវពិចារណា និងបង្កើតនៅកំរិតផែនការមេ ឬកំរិតសិក្សាលទ្ធភាពអនុវត្តគំរោងដោយសារសេចក្តីលំអិតនៃគំរោងនីមួយៗមិនត្រូវបានបញ្ជាក់ច្បាស់លាស់នៅដំណាក់កាលនេះទេ ។ វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានពិចារណានៅដំណាក់កាលនេះសំរាប់គំរោងមួយចំនួន ត្រូវបានពិពណ៌នាដូចខាងក្រោម :

- ឧស្ម័នកន្លែងកប់សំណល់ដែលមានឧស្ម័នមេតាន និងឧស្ម័នកាបូនិច $CO_2$ អាចត្រូវប្រមូលបានពីកន្លែងកប់សំណល់ដែលបានស្នើឡើង ដោយសារការបំបែកធាតុជីវសាស្ត្រ។ ដូច្នេះ ត្រូវបំពាក់ឧបករណ៍សំរាប់ប្រមូលឧស្ម័នពីកន្លែងកប់សំណល់ទាំងនោះ។
- កន្លែងកប់សំណល់ដែលស្នើសុំអាចមានអគ្គីភ័យកើតឡើងដោយចៃដន្យ ហើយអគ្គីភ័យបង្កើតផ្សែង និងឧស្ម័នគ្រោះថ្នាក់យ៉ាងច្រើន។ លើសពីនេះ ក្លិនស្អុយអាចសាយចេញពីកន្លែងកប់សំណល់នោះ ដោយសារការបំបែកធាតុនៃសំណល់សរីរាង្គ។ ដូច្នេះ គួរចាក់ដីគ្របជារៀងរាល់ថ្ងៃដើម្បីកាត់បន្ថយឧប្បត្តិហេតុនៃការកើតមានអគ្គីភ័យ។
- ចាំបាច់ត្រូវរៀបចំស្រះសំរាប់ធ្វើប្រព្រឹត្តិកម្មទឹកសំរាប់ធ្វើប្រព្រឹត្តិកម្មសំណល់រាវហៀរចេញពីកន្លែងកប់សំណល់ដែលបានស្នើឡើង។
- អាចតំរូវឱ្យមានការការបំពាក់សម្ភារៈសំរាប់កាត់បន្ថយការសាយចេញនៃសារធាតុពុលពីម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូត។
- ចាំបាច់ធ្វើការអង្កេតម្តងម្កាលលើការស្រុតបាក់ដីដោយការបង្កើតកន្លែង និងបំពាក់សម្ភារៈអង្កេតក្នុងអំឡុងពេល និងក្រោយពេលប្រតិបត្តិគំរោង។

### ៨.៣.២ ផែនការត្រួតពិនិត្យបរិស្ថានសំរាប់ការអនុវត្តន៍គំរោង

ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរអាចកើតឡើង បើសកម្មភាពសាងសង់ និងអនុវត្តគំរោង ដែលបានស្នើសុំនៅក្នុងផែនការមេពុំមានលក្ខណៈសមស្រប ទោះបីមានការធ្វើផែនការ និងការរៀបចំបានយ៉ាងល្អក៏ដោយ។ ដូចនេះ តំរូវការឱ្យមានការត្រួតពិនិត្យបរិស្ថានម្តងម្កាល ក្នុងអំឡុងពេលមុនសាងសង់ និងអំឡុងពេលអនុវត្តគំរោង។

ភាគីទទួលខុសត្រូវសំរាប់ការត្រួតពិនិត្យតាមដានបរិស្ថានត្រូវផ្លាស់ប្តូរនៅតាមដំណាក់កាលផ្សេងៗនៃការអនុវត្តនីតិរោង ។ ភាគីទទួលខុសត្រូវសំរាប់ដំណាក់កាលអនុវត្តន៍នីមួយៗ រួមមានដូចខាងក្រោម :

១. រយៈពេលមុនសាងសង់ : វិស្វករគូរប្លង់ និងសំណង់ ( ជួយដោយមន្ទីរបរិស្ថានខេត្ត និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ) ។

២. រយៈពេលសាងសង់ : អ្នកម៉ៅការសាងសង់ ( ជួយដោយមន្ទីរបរិស្ថានខេត្ត និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត) ។

៣. រយៈពេលប្រតិបត្តិ : មន្ទីរបរិស្ថានខេត្ត និងគណៈកម្មការអភិវឌ្ឍន៍ ( បានស្នើសុំហើយ)

គណៈកម្មការអភិវឌ្ឍន៍ដែលបានស្នើសុំគឺជាអង្គការចាត់តាំងមួយឯករាជ្យ ដើម្បីវាយតំលៃ និងអនុម័តលើគំរោងនានាដែលបានស្នើឡើងនៅក្នុងផែនការមេ និងត្រួតពិនិត្យគំរោងអភិវឌ្ឍន៍។ គណៈកម្មការនេះមានសមាជិកមកពីអាជ្ញាធរខេត្ត អាជ្ញាធរអប្សរា និងមន្ទីរពាក់ព័ន្ធក្នុងខេត្តទាំងអស់ ។ មានសមាជិកផ្តល់យោបល់មកពីស្ថាប័នផ្តល់ជំនួយអន្តរជាតិ អ្នកជំនាញផ្សេងៗ និងផ្នែកឯកជន ។

អ្នកម៉ៅការសំណង់គួរបង្កើតការិយាល័យគ្រប់គ្រងបរិស្ថានមួយមានការទទួលខុសត្រូវសំរាប់អនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ និងសំរាប់ធ្វើអធិការកិច្ច និងត្រួតពិនិត្យស្ថានភាពបរិស្ថាន ឬសង្គមនៅក្នុងតំបន់រងផលប៉ះពាល់ពីគំរោង ។

សម្ភារៈសំរាប់ត្រួតពិនិត្យ ប៉ារ៉ាម៉ែត្រផ្សេងៗ ទីតាំង និងភាពញឹកញាប់នៃការត្រួតពិនិត្យនៅដំណាក់កាលមុនសាងសង់ និងដំណាក់កាលសាងសង់មានបង្ហាញក្នុងតារាង២៤ ។ ផែនការត្រួតពិនិត្យសំរាប់គំរោងមួយនៃគំរោងដែលបានស្នើសុំក្នុងអំឡុងពេលប្រតិបត្តិចាំបាច់ត្រូវពិចារណានៅកំរិតនៃការរៀបចំផែនការមេ ឬនៅកំរិតសិក្សាសមិទ្ធលទ្ធភាពអនុវត្តគំរោង ។ ការប៉ាន់ស្មានពីតំលៃសំរាប់ត្រួតពិនិត្យនៅដំណាក់កាលនេះមានការលំបាក ដោយសារតែព័ត៌មានលំអិតនៃគំរោងនីមួយៗមិនទាន់មានការសំរេចនៅឡើយ ។ ដូចនេះ ការប៉ាន់ស្មានពីតំលៃសំរាប់ការត្រួតពិនិត្យសំរាប់គំរោងនីមួយៗចាំបាច់ត្រូវធ្វើនៅដំណាក់កាលនៃផែនការមេ ឬដំណាក់ការលនៃការសិក្សាសមិទ្ធលទ្ធភាពអនុវត្តគំរោងនៅតាមវិស័យនីមួយៗ ។

## តារាង ២៤ : ផែនការត្រួតពិនិត្យក្នុងមុនពេលសាងសង់ និងកំពុងសាងសង់

ដំណាក់កាលមុនការសាងសង់

| សកម្មភាពដែលត្រូវត្រួតពិនិត្យ | ប៉ារ៉ាម៉ែត្រ | ទីតាំង | ភាពញឹកញាប់ | កំណត់សំគាល់ |
|---|---|---|---|---|
| ការអង្កេតផ្នែកបុរាណវិទ្យា | ការប្រព្រឹត្តទៅតាមច្បាប់ និងបទបញ្ញាផ្សេងៗ ដែលទាក់ទងនឹងទ្រព្យសម្បត្តិវប្បធម៌ជាតិ | កន្លែងគំរោង | មួយដង | គ្រប់គំរោងទាំងអស់ |
| ការធ្វើតេស្តទឹកក្រោមដី | ហ្វ្លុយអ៊័រ ម៉ង់ហ្គាណែស នីត្រាត អេកូលី ក្លរីនសំណល់ សេដាក់/ក្លិន លោហៈ សំណល់រឹងរលាយសរុប អាសេនិក | អណ្តូងលូសំរាប់ធ្វើតេស្ត | មួយដងក្នុងមួយអណ្តូង | គំរោងអភិវឌ្ឍន៍ធនធានទឹក |

ដំណាក់កាលសាងសង់

| សកម្មភាពដែលត្រូវត្រួតពិនិត្យ | ប៉ារ៉ាម៉ែត្រ | ទីតាំង | ភាពញឹកញាប់ | កំណត់សំគាល់ |
|---|---|---|---|---|
| សកម្មភាពសាងសង់ | ធូលី សំលេង ក្លិនស្អុយ ធ្វើអធិការកិច្ចសំណល់រឹង | ទីកន្លែងសាងសង់ | | គ្រប់គំរោងទាំងអស់ |
| ការដឹកជញ្ជូនសំភារៈសំណង់ | ផលប៉ះពាល់នៅក្នុងតំបន់ដែលត្រូវបំពុលនៅតាមបណ្តោយផ្លូវដឹកជញ្ជូន( សំលេង ការបំពុលបរិយាកាស ការប្រើប្រាស់ដី ការកំណត់ពេលវេលា) | នៅតាមបណ្តោយផ្លូវដឹកជញ្ជូន | ពីរដងក្នុងមួយសប្តាហ៍ | គ្រប់គំរោងទាំងអស់ |
| ការគ្រប់គ្រងការដឹកជញ្ជូន | ផ្លាកសញ្ញាចរាចរ ការបង្ហាញព័ត៌មាន ឱ្យប្រុងប្រយ័ត្ន ការកំនត់ពេលវេលា | កន្លែងដែលទាក់ទងនឹងការសាងសង់ | ប្រចាំថ្ងៃ | គ្រប់គំរោងទាំងអស់ |
| ទឹកក្រោមដី | ភាពអាចចំលងក់ដៅបាន វង្វាស់សំរាប់វាស់សារធាតុគីមី និងកូរ | អណ្តូងត្រួតពិនិត្យ | ប្រចាំថ្ងៃ | គំរោងអភិវឌ្ឍធនធានទឹក គំរោងប្រព័ន្ធបង្ហូរទឹកកខ្វក់ និងសំណល់រាវ |
| គុណភាពទឹកលើដី | DO, SS, COD, Total-N, Total-P ភាពដែលអាចំលងក់ដៅបាន TDS NH3 កូលីហ្វម | ទីតាំងរងឥទ្ធិពលដោយសកម្មភាពសាងសង់ | ប្រចាំសប្តាហ៍ | គ្រប់គំរោងទាំងអស់ |
| ការបោះចោលសំភារៈប្រើប្រាស់ | ស្របតាមផែនការបោះចោល កករសំណល់ | ទីកន្លែងបោះចោលសំណល់ | ប្រចាំសប្តាហ៍អំឡុងពេលចោល | គំរោងទាក់ទងនឹងការបោះចោល |
| គំរូអភិរក្សរកឃើញបុរាណវត្ថុ | ការរកឃើញផ្នែកបុរាណវិទ្យា | កន្លែងរកឃើញបុរាណវត្ថុ | ប្រចាំថ្ងៃអំឡុងពេលធ្វើស. ក | គំរោងទាក់ទងការរកឃើញបុរាណវត្ថុ |
| ស្តារទីកន្លែងសំណង់ឱ្យដូចដើមវិញ | ការយកចេញនៃសំណល់ និងសំភារៈសំណង់ | ទីកន្លែងសាងសង់ | ក្រោយពេលបញ្ចប់ការសាងសង់ | គ្រប់គំរោងទាំងអស់ |

ប្រភព : ក្រុមសិក្សា JICA

ភាគីទទួលខុសត្រូវលើផែនការត្រួតពិនិត្យ

| ដំណាក់កាលរបស់គំរោង | ភាគីទទួលខុសត្រូវ | ភាគីជួយគាំទ្រ |
|---|---|---|
| ដំណាក់កាលមុនសាងសង់ | វិស្វករគូប្លង់ និងសំណង់ | មន្ទីរបរិស្ថានខេត្ត<br>មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |
| ដំណាក់កាលមុនសាងសង់ | អ្នកម៉ៅការសំណង់ | មន្ទីរបរិស្ថានខេត្ត<br>មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |

ប្រភព : ក្រុមសិក្សា JICA

### ៨.៣.៣ ការកសាងសមត្ថភាពស្ថាប័ន

ការកសាងសមត្ថភាពនឹងត្រូវការចាំបាច់ សំរាប់ការិយាល័យវាយតំលៃផលប៉ះពាល់បរិស្ថាននៅក្នុងមន្ទីរបរិស្ថានខេត្តដើម្បីពង្រឹងសមត្ថភាពអនុវត្ត EIA ឬ IEIA នៅថ្នាក់ខេត្ត។ ការបណ្តុះបណ្តាលដោយអ្នកឯកទេស EIA អន្តរជាតិម្នាក់គួររៀបចំឡើងសំរាប់បុគ្គលិកការិយាល័យ ប្រសិនបើគំរោងខ្លះនៃគំរោងដែលបានស្នើសុំនៅក្នុងផែនការមេនឹងត្រូវអនុវត្តនៅដំណាក់កាលបន្ទាប់។

មានការស្នើឡើងថា ការបណ្តុះបណ្តាលសំរាប់បុគ្គលិកនៃមន្ទីរបរិស្ថាន និងមន្ទីរសាធារណការ និងដឹកជញ្ជូនគួរយក

ចិត្តទុកដាក់លើផែនការគ្រប់គ្រងបរិស្ថានដែលបានលើកឡើងខាងលើ។ ការបណ្តុះបណ្តាលគួរធ្វើឡើងដោយអ្នកឯកទេសបរិស្ថានក្នុងស្រុក និងអន្តរជាតិជាមួយដែលមានជំនាញ និងចំណេះដឹងលើការគ្រប់គ្រង។ បន្ថែមពីលើនេះ សម្ភារៈសំរាប់គ្រប់គ្រងបរិស្ថានក្នុងអំឡុងពេលនៃការសាងសង់ និងប្រតិបត្តិចាំបាច់ត្រូវផ្តល់ទៅឱ្យមន្ទីរបរិស្ថាន។

ការកសាងសមត្ថភាពសំរាប់ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគំរោងនីមួយៗនៃគំរោងដែលបានស្នើឡើងឱ្យបានសមរម្យចាំបាច់ត្រូវពិចារណានៅផ្នែកផែនការមេ ឬនៅកំរិតនៃសិក្សាលទ្ធភាពអនុវត្តគំរោង។

## ៩. គំរោងសាកល្បង

ជាផ្នែកមួយនៃការសិក្សាបច្ចុប្បន្ន គំរោងសាកល្បងពីរត្រូវបានរៀបចំឡើងរួមគ្នារវាងក្រុមសិក្សា និងសមភាគីការងារក្នុងគោលដៅលើកកំពស់ការយល់ដឹង និងសមត្ថភាពក្នុងការធ្វើផែនការ។ ដោយសារ ពេលវេលា និងធនធានមានកំរិតគំរោងសាកល្បងទាំងពីរមានទំហំតូច និងសាមញ្ញសំរាប់ភាពងាយស្រួលដល់ការអនុវត្តន៍ និងមានប្រសិទ្ធភាពខ្ពស់តែក្នុងរយៈពីរ ឬបីខែប៉ុណ្ណោះ។

គោលបំណងនៃការអនុវត្តន៍គំរោងសាកល្បងទាំងពីរដែលជាផ្នែកមួយនៃការសិក្សានោះមានដូចខាងក្រោម ៖

- ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃវិធីសាស្ត្រធ្វើផែនការរួមគ្នា
- ដើម្បីអនុវត្តសកម្មភាពជាក់ស្តែងសំរាប់កសាងសមត្ថភាពក្នុងការធ្វើផែនការ និងអនុវត្តន៍គំរោង
- ដើម្បីអនុវត្តសកម្មភាពជាក់ស្តែងរបស់ភាគីពាក់ព័ន្ធផ្សេងៗ ដូចជា អាជ្ញាធរខេត្ត អាជ្ញាធរអប្សរា ប្រជាជនទៅមូលដ្ឋាន និងក្រុមអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីសហការ និងធ្វើការរួមគ្នាសំរាប់ជាប្រយោជន៍រួមរបស់ពួកគេ
- ដើម្បីបញ្ចូលមេរៀន និងលទ្ធផលរកឃើញផ្សេងៗតាមរយៈការអនុវត្តន៍ជាក់ស្តែងក្នុងគំរោងសាកល្បងទៅក្នុងផែនការមេ។

### ៩.១ គំរោងសាកល្បង ៖ ការធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង

#### ៩.១.១ ខ្លឹមសាររួមរបស់គំរោង

**១. ប្រវត្តិដើមរបស់គំរោងសាកល្បង**

នៅក្នុងការប្រជុំសំរាប់របាយការណ៍រីកចំរើនទី១ ដែលធ្វើឡើងនៅខែមករា ឆ្នាំ២០០៥ អ្នកចូលរួមជាច្រើននាក់បានស្នើយ៉ាងទទូចឱ្យមានគំរោងសាកល្បងមួយ ដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាជនលើការការពារបរិស្ថាន។ អាស្រ័យហេតុនេះក្រុមសិក្សា JICA បានសំរេចរៀបចំគំរោងសាកល្បងដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាជនទៅលើបរិស្ថានដោយយកចិត្តទុកដាក់ទៅលើបញ្ហាសំណល់រឹង ដែលជាប្រធានបទមួយមានការយកចិត្តទុកដាក់បំផុតពីសំណាក់ប្រជាជន។

**២. គោលដៅ**

គោលដៅរបស់គំរោងសាកល្បងនេះគឺដើម្បីធ្វើឱ្យក្រុងសៀមរាបកាន់តែមានភាពស្រស់ស្អាតឡើងដោយមានកិច្ចសហការជាមួយនឹងប្រជាជន។ ឈ្មោះរបស់គំរោងសាកល្បងនេះគឺ ***ការលើកកំពស់ការយល់ដឹងរបស់ប្រជាជនសំរាប់ "ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង"***។

**៣. យុទ្ធសាស្ត្រ**

ដើម្បីធ្វើឱ្យសំរេចគោលដៅខាងលើ អ្នករៀបចំគំរោងបានអនុវត្តយុទ្ធសាស្ត្រចំនួន ៣ គឺ ៖

ក) ដោយចាប់ផ្តើមជាដំបូងជាមួយនឹងក្រុមគោលដៅតូចៗ (សាលារៀន) និងបន្ទាប់មកពង្រីកជាបន្តបន្ទាប់ទៅកាន់តំបន់គោលដៅ

ខ) ដោយតំរង់ទិសដៅទៅប្រជាជនដែលមានក្រុមអាយុផ្សេងៗគ្នាដោយប្រើប្រាស់វិធីសាស្ត្រខុសៗគ្នា

គ) ដោយការប្រើប្រាស់ដើមទុនសង្គមដែលមានស្រាប់។

## ៤. គោលនយោបាយសំរាប់ការអនុវត្តន៍

ដើម្បីធ្វើឱ្យសំរេចគោលបំណងខាងលើ ក្រុមសិក្សាបានប្រើប្រាស់វិធីផ្សេងៗដូចខាងក្រោម ៖

ក) សមភាគីត្រូវតែមានលទ្ធភាពគ្រប់គ្រងគំរោងសាកល្បងនេះដោយខ្លួនគេផ្ទាល់

ខ) គំរោងសាកល្បងនេះត្រូវតែប្រើប្រាស់ធនធានដែលមានស្រាប់នៅមូលដ្ឋាន ដើម្បីឱ្យគេអាចពង្រីកធនធានទាំងនោះបាន ។

គ) ក្រុមសិក្សានឹងគ្រាន់តែផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់បង្កើតគំរោងប៉ុណ្ណោះ ។

### ៩.១.២ ការពិពណ៌នាគំរោងដែលបានបង្កើតឡើង

គំរោងសាកល្បងមានគំរោងតូចចំនួនពីរ ៖ គំរោងតូចទីមួយផ្តោតគោលដៅលើសិស្សសាលាបឋមសិក្សា និងមាតាបិតារបស់គេ និងគំរោងតូចទីពីរគឺសំរាប់មនុស្សពេញវ័យដទៃទៀត ។ វិធីសាស្ត្រទូទៅមានបង្ហាញក្នុងរូប និងតារាងដូចខាងក្រោម ៖




**ប្រភព៖ ក្រុមសិក្សា JICA**

**រូបទី ៦៥ ៖ គោលគំនិតនៃគំរោងសាកល្បង**

**តារាង ២៥ : បញ្ជីសកម្មភាពក្នុងគំរោងសាកល្បង**

| ក្រុមគោលដៅ | លេខសំគាល់ | ឈ្មោះសកម្មភាព | ការពិពណ៌នា |
|---|---|---|---|
| សិស្ស និងមាតាបិតា | A | ការកែច្នៃសំណល់នៅតាមសាលារៀន | សិស្សត្រូវឱ្យនាំយកសំរាមដែលអាចកែច្នៃបានពីផ្ទះរបស់គេមានដូចជាកំប៉ុងអាលុយមីញ៉ូមទទេ ដប។ល។ ហើយដាក់ឱ្យដាច់ដោយឡែកពីគ្នា រួចរក្សាទុកនៅក្នុងឃ្លាំងស្តុក។ បន្ទាប់មកលក់ឱ្យឈ្មួញកណ្តាល ហើយលុយលក់បានត្រូវប្រើសំរាប់ទិញសម្ភារៈសំរាប់សាលារៀន។ គំរោងនេះមានគោលបំណងបណ្តុះផ្តត់គំនិតកុមារឱ្យចេះសង្គ្រោះអេកូឡូស៊ី។ គំរោងនេះត្រូវអនុវត្តក្នុងសាលាបឋមសិក្សា ៩។ |
| | B | ការអប់រំដល់មាតាបិតាសិស្ស | ការបង្កើនការយល់ដឹងស្តីពីបរិស្ថានរបស់មាតាបិតាមានភាពចាំបាច់ដើម្បីគាំទ្រការអនុវត្តន៍គំរោង ក ពីព្រោះមាតាបិតាគឺជាអ្នកចូលរួមដោយប្រយោល។ ខិតប័ណ្ណនឹងត្រូវបោះពុម្ពចែកចាយទៅឱ្យមាតាបិតាសិស្សក្នុងសាលាបឋមសិក្សាទាំង ៩។ |
| | C | ការអប់រំដល់សិស្សសាលា | កូនសៀវភៅរូបភាពសំរាមចំនួន ៣.២២០ ច្បាប់ត្រូវបោះពុម្ព និងចែកជូនទៅអោយសាលាបឋមសិក្សាទាំង ៤១ នៅក្នុងស្រុកសៀមរាប។ សៀវភៅរូបភាពធំៗសំរាប់បង្រៀននឹងត្រូវផលិតផងដែរ។ |
| | D | ការកែលំអសោភ័ណភាពក្នុងសាលារៀន | ក្រុមសិក្សាបានផ្តល់មូលនិធិដល់សាលាបឋមសិក្សាចំនួន ៩ សំរាប់ធ្វើការកែលំអសោភ័ណភាពនៅជុំវិញសាលារៀនតាមរយៈការបណ្តុះផ្នត់គំនិតសិស្សឱ្យចេះស្រលាញ់សោភ័ណភាព ដោយការបង្កើតសួនផ្កា ដាំរុក្ខជាតិ។ល។ |
| មនុស្សពេញវ័យទូទៅ | E1 | ផ្លាកសញ្ញាបរិស្ថាន | បង្កើតផ្លាកសញ្ញាបរិស្ថានមួយ។ ផលិត និងចែកចាយប័ណ្ណបិទផ្សាយចំនួន ១០.០០០សន្លឹកដោយមានសញ្ញាបរិស្ថាន។ |
| | E2 | ធុងសំរាមតាមវិថី | ធុងសំរាមចំនួន ១០០ ដែលមានបង្ហាញផ្លាកសញ្ញាបរិស្ថាន និងម្ចាស់ឧបត្ថម្ភត្រូវបានដាក់នៅតាមបណ្តោយវិថីសំខាន់ៗ។ |
| | E3 | ការផ្សព្វផ្សាយដោយខិតប័ណ្ណ | ខិតប័ណ្ណសំរាប់ការអប់រំបរិស្ថាននឹងត្រូវចែកចាយ។ |
| | F | យុទ្ធនាការសំអាតបរិស្ថាន | យុទ្ធនាការមួយដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជនស្តីពីបរិស្ថាននឹងត្រូវអនុវត្តដោយមានអ្នកស្ម័គ្រចិត្តជាច្រើនពាក់អាវយឺតដែលមានពិសស្លោកថា "ធ្វើអោយសៀមរាបកាន់តែស្រស់ស្អាតឡើង"។ |

## ៩.១.៣ មេរៀនជាបទពិសោធន៍ និងអនុសាសន៍

## ១. គំរោងសំរាប់បង្កើនការយល់ដឹងពីបរិស្ថានដល់សិស្ស

### លទ្ធផល

ការកំណត់លទ្ធផលនៃគំរោងនៅពេលនេះគឺជាការប្រញាប់ពេក ពីព្រោះសកម្មភាពភាគច្រើនទើបតែបានចាប់ផ្តើមពីរបីខែនេះប៉ុណ្ណោះ។ ជាទូទៅគំរោងប្រព្រឹត្តិទៅបានល្អ និងបង្ហាញឱ្យឃើញនូវសមិទ្ធិផលល្អជាច្រើនរួចស្រេចទៅហើយ នៅតាមសាលារៀនមួយចំនួន។ បើពិចារណាពីព្រឹត្តិការណ៍បង្ហាញថា ភាគីពាក់ព័ន្ធជាច្រើនគាំទ្រយ៉ាងខ្លាំងដល់គំរោង ហើយសកម្មភាពជាច្រើនកំពុងប្រព្រឹត្តិទៅដោយរលូន។ មានការរំពឹងថាគំរោងនឹងដំណើរការប្រកបដោយជោគជ័យ។

គន្លឹះសំខាន់ៗដែលនាំឱ្យជោគជ័យមានដូចតទៅ :

- មានតំរូវការខ្ពស់សំរាប់ការការពារបរិស្ថាន
- គំរោងមិនត្រឹមតែសមស្របទៅនឹងតំរូវការនាពេលបច្ចុប្បន្ន ប៉ុណ្ណោះទេ តែប៉ុន្តែសកម្មភាពនីមួយៗគឺងាយអនុវត្ត ដោយសារភាពសមញ្ញរបស់វា ។

គំរោងបង្ហាញពីលទ្ធផលដែលមាននិរន្តភាពបរិស្ថានខ្ពស់រួមមាន :

១) ភាពសមរម្យទៅនឹងតំរូវការខ្ពស់

២) ការអនុវត្តន៏មានភាពងាយស្រួល

៣) ប្រាក់ចំណូលត្រូវបានធានាដោយគ្មានហានិយភ័យហិរញ្ញវត្ថុ ។ល ។

បន្ថែមលើនោះ ការចូលរួមពីមាតាបិតាបានធ្វើអោយគំរោងកាន់តែមាននិរន្តរភាពឡើង ។

## អនុសាសន៍

តាមការវាយតំលៃបង្ហាញថា គ្រប់សាលារៀនគោលដៅទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបន្តគំរោងដោយខ្លួនឯង បន្ទាប់បញ្ឈប់ជំនួយ ។

គំរោងនេះទទួលបានការចាប់អារម្មណ៍ពីសាលាបឋមសិក្សាផ្សេងៗ ហើយគ្រប់នាយកសាលានៃសាលារៀនគោលដៅទាំងអស់ មានការប្តេជ្ញាចិត្តគាំទ្រដល់ការពង្រីកគំរោងដល់សាលារៀនផ្សេងៗទៀត ។ ហេតុដូច្នេះ គួរធ្វើការត្រួតពិនិត្យទៅលើលទ្ធភាពពង្រីកគំរោងទៅកាន់សាលាបឋមសិក្សា និងអនុវិទ្យាល័យដទៃទៀត ។

បើទោះបីជាគោលបំណងគំរោង គឺដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជនស្តីពីបរិស្ថានដោយមិនគិតពីការបង្កើតប្រាក់ចំណូលក៏ដោយ ក៏ប្រាក់ចំណូលដែលបានពីគំរោងពិតជាបានបង្កើននិរន្តរភាពរបស់គំរោង ។ ទោះបីជាយ៉ាងនេះក៏ដោយ ជួនកាលប្រជាជនជ្រើសរើស ដើម្បីរកប្រាក់ចំណូលដោយបំភ្លេចចោលវត្ថុបំណងចំបង ហើយបញ្ឈប់សិស្សពីការចាត់ប្រភេទសំភារៈដែលជាដំណើរការសំខាន់មួយដើម្បីឱ្យសិស្សរៀនសូត្រពីសារៈសំខាន់នៃការកែច្នៃសំណល់យកមកប្រើប្រាស់ ។ ដូច្នេះប្រសិទ្ធភាពនៃការអប់រំបរិស្ថាន គួរតែត្រូវបានរក្សាទុកក្នុងចិត្តដើម្បីធ្វើឱ្យកើនឡើងជាអតិបរមានូវប្រសិទ្ធភាពគំរោង ។

## មេរៀនជាបទពិសោធន៍

ការជាប់ពាក់ព័ន្ធរបស់មាតាបិតារបស់សិស្សមានសារៈប្រយោជន៏សំរាប់គំរោង ហើយការចែកខិតប័ណ្ណមានប្រសិទ្ធភាពសំរាប់គោលបំណងនេះ ។ ដូចនេះ ខិតប័ណ្ណដែលបានផលិតគួរត្រូវប្រើប្រាស់ឱ្យបានពេញលេញ ។ ការជំរុញសិស្សឱ្យចាត់ប្រភេទសំណល់ ដើម្បីកែច្នៃគឺជាការសំខាន់ ពីព្រោះគោលបំណងរបស់គំរោង គឺដើម្បីឱ្យសិស្សរៀនសូត្រពីសារៈសំខាន់នៃការទាញយកសំភារៈពីសំណល់ ដើម្បីរួមចំណែកដល់ការការពារបរិស្ថាន ជាពិសេស ការជំរុញលើកទឹកចិត្តសិស្សចូលរួមថែរក្សាឃ្លាំងស្តុកឱ្យបានល្អ ។

*ការបង្កើតកន្លែងផ្ទុកសំរាមដំបូងនៅក្បែរបន្ទប់រៀន ដែលសិស្សចោលសំណល់អាចកែច្នៃនៅគ្រប់ពេលបានអាចបង្កលក្ខណៈងាយស្រួលដល់សិស្សនាំយកសំណល់ពីផ្ទះមកកែច្នៃបាន ។*

ក្នុងគំរោងកែច្នៃនៅតាមសាលារៀន មានការលើកឡើងថា ដើម្បីប្រមូលសំភារៈអាចកែច្នៃបានគ្រប់គ្រាន់ ដើម្បី

ធ្វើឱ្យគំរោងជោគជ័យតំរូវការសិស្សអប្បបរមាប្រហែល១០០០ នាក់ ប៉ុន្តែតាមពិត សាលាមួយដែលមានសិស្សតិចជាង ៥០០នាក់ក្នុងគំរោងសាកល្បងក៏អាចធ្វើឱ្យគំរោងកែច្នៃឡើងវិញនេះទទួលបានជោគជ័យដែរ។ នេះបញ្ជាក់ថា សាលាដែលមានសិស្សតិចជាង ៥០០ នាក់ក៏មានលទ្ធភាពអនុវត្តគំរោងកែច្នៃតាមសាលារៀនរបស់គេបានដែរ។

ក្រុមសិក្សាបានរកឃើញថា សាលារៀនខ្លះប្រមូលសំណល់គរទុកនៅក្នុងឃ្លាំងស្តុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយសារមិនអាចលក់បាននៅទីផ្សារ។ ការនេះអាចបំបាក់ទឹកចិត្តសិស្សពីការបន្តការកែច្នៃនៅសាលារៀន។ ហេតុដូចនេះ សាលាគួរធ្វើការសំរេចចិត្តដោយប្រុងប្រយ័ត្នចំពោះវត្ថុប្រមូល។

## ២. គំរោងសំរាប់ "បង្កើនការយល់ដឹងពីបរិស្ថានដល់មនុស្សពេញវ័យ"

### លទ្ធផល

ការកំណត់លទ្ធផលរួមនៃគំរោងនៅពេលនេះគឺជាការប្រញាប់ពេក ពីព្រោះសកម្មភាពភាគច្រើនទើបតែបានចាប់ផ្តើមពីរ ឬបីខែនេះប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក៏ដោយ យុទ្ធនាការត្រូវបានធ្វើពីរលើករួចមកហើយដោយគ្មានបញ្ហារាំងស្ទះធ្ងន់ធ្ងរអ្វីឡើយ។ យុទ្ធនាការទាំងនោះហាក់បីដូចជាបង្ហាញថា អាជ្ញាធរខេត្ត ជាស្ថាប័នអនុវត្តន៍គំរោងដោយខ្លួនឯង។ ការនេះគឺដោយសារគំរោងអនុវត្តឆ្លើយតបទៅនឹងតំរូវការរបស់ខេត្ត។

### អនុសាសន៍

ការលើកកំពស់ការយល់ដឹងពីបរិស្ថានដល់មនុស្សពេញវ័យមានសារៈសំខាន់ណាស់ ពីព្រោះថាមនុស្ស ពេញវ័យទាំងនោះគឺជាចំនួនភាគច្រើនក្នុងសង្គម និងជាក្រុមដ៏សំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណា ក៏ដោយការអប់រំដល់ពួកគេគឺជាពិបាកណាស់ ដោយសារពួកគេគ្មានឱកាសផ្លូវការណាមួយសំរាប់ទទួលការអប់រំ។ ម្យ៉ាងទៀត ពួកគេមានការចាប់អារម្មណ៍ផ្សេង និងមានឯកភាពរួមជាងសិស្ស។ ការអប់រំមនុស្សពេញវ័យគួរអនុវត្តជាបណ្តើរៗ គ្រប ដោយភាពអត់ធ្មត់ជាមួយនឹងការសាកល្បង និងកំហុស។

យុទ្ធនាការសំអាតបរិស្ថានគួរផ្តោតលើការលើកទឹកចិត្តប្រជាជន និងសាធារណៈជាជាងការយកចិត្តទុកដាក់ឥទ្ធិពលជាក់ស្តែងតាមរយៈការអនុវត្តន៍ ដូចជាការសំអាតក្រុង។

ក្រដាសបិទផ្លាកសញ្ញាបរិស្ថានដ៏ស្រស់ស្អាតដែលបានបិទលើធុងសំរាមត្រូវបានបាត់បង់ ហើយការនេះប្រហែលជាប្រជាជនស្រលាញ់ផ្លាកទាំងនោះ។ បើដូចនេះមែន ការលក់ទំនិញដែលបង្ហាញពីរូបភាពបរិស្ថានដូចជាអាវយឺតគួរត្រូវពិចារណាបង្កើតឡើង។

គំរោងបានតំរង់ទិសដៅទៅរកការកែលំអសោភ័ណភាព។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីសំរេចបានការការពារបរិស្ថាន ការអប់រំគួរមិនត្រូវគ្របដណ្តប់ត្រឹមតែផ្នែកសំណល់រឹងប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវគ្របដណ្តប់លើការ ផ្គត់ផ្គង់ទឹកសំណល់រាវ អគ្គិសនី។ល។ គំរោងកែលំអសោភ័ណភាពគួរចាត់ទុកជាដំណាក់កាលដំបូងការសំរាប់ពង្រីកថែមទៀតនៃគំរោងអប់រំ។

### មេរៀនជាបទពិសោធន៍

ក្រុមសិក្សាបានផ្តល់ធុងសំរាមជាច្រើនឱ្យអាជ្ញាធរខេត្តសំរាប់ដាក់តាមទីសាធារណៈជាច្រើន ចំណែកក្រុមហ៊ុន MICC

ធ្វើការប្រមូលសំរាមពីធុងទាំងនោះ ហើយទាំងក្រុមសិក្សា ទាំងក្រុមហ៊ុនទទួលបានផលប្រយោជន៍ពី សាធារណជន ដោយការដាក់ឈ្មោះផ្សាយនៅតាមធុងសំរាមទាំងនោះ។ ធុងសំរាមទាំងនោះត្រូវបានដាក់ពង្រាយនៅតាមវិថីមមាញឹកសំរាប់អ្នកថ្មើរជើង។ ហេតុដូច្នេះ ក្រុមហ៊ុនអាចផ្តល់ជំនួយសំរាប់ទិញធុងសំរាមដាក់តាម ទីសាធារណៈដោយប្រើប្រាស់ធុងសំរាមទាំងនោះសំរាប់ផ្សាយពាណិជ្ជកម្មដល់សាធារណជន។ ក្នុងបរិបទនេះ រដ្ឋបាលមូលដ្ឋានគួរលើកកំពស់ភាពជាដៃគូរវាងឯកជន និងសាធារណៈសំរាប់កិច្ចការពារបរិស្ថាន ដោយអនុវត្តតួនាទីជាអន្តរការីដើម្បីតភ្ជាប់វិស័យទាំងពីរនេះ។

យុទ្ធនាការសំអាតបរិស្ថានគឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយ ដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជន។ ដូច្នេះ យុទ្ធនាការគួរតែមានភាពសាមញ្ញទៅតាមលទ្ធភាពដែលអាចធ្វើបាន និងពាក់ព័ន្ធនឹងមនុស្សជាច្រើនដើម្បីធ្វើពួកគេរួបរួមគ្នា និងធ្វើឱ្យយុទ្ធនាការមាននិរន្តរភាពជាជាងការអនុវត្តន៍យុទ្ធនាការមួយមានលក្ខណៈស្មុគស្មាញ ដែលត្រូវការការរៀបចំផ្សេងៗជាច្រើន។



ឃ្លាំងស្តុកដែលបានសាងសង់នៅសាលាបឋមសិក្សាហ៊ុន សែន



ការពង្រីកកម្មវិធីដល់មាតាបិតា



វត្ថុដែលអាចកែច្នៃបានជាច្រើនត្រូវបានរក្សាទុកនៅក្នុងឃ្លាំងស្តុកបន្ទាប់ពីចំណាត់ថ្នាក់ត្រឹមត្រូវ



ប្រជាជនជាច្រើនបានប្រមូលផ្តុំនៅពីមុខសណ្ឋាគារហ្គ្រេនអូតែល



ក្រុមសិក្សាប្រគល់ធុងសំរាមចំនួន ១២០ ដល់អាជ្ញាធរខេត្ត



លោកអភិបាលខេត្តជួយប្រមូលសំរាមដែលរាយប៉ាយលើវិថី



លោកអភិបាលរងទីមួយដឹកនាំយុទ្ធនាការ



ផ្លាកសញ្ញាបរិស្ថានសំរាប់សៀមរាប



ការផ្សព្វផ្សាយដោយខិតប័ណ្ណ

## ៩.២ គំរោងសាកល្បង : ការតាំងពិព័រណ៍ផលិតផលអង្គរ ២០០៥

### ៩.២.១ ខ្លឹមសាររួមរបស់គំរោង

### ១. ប្រវត្តិដើមនៃគំរោងសាកល្បង

ភ្ញៀវអន្តរជាតិជាច្រើនទស្សនាមជ្ឈមណ្ឌលក្រុងសៀមរាបធ្វើឱ្យមជ្ឈមណ្ឌលនេះក្លាយទៅជាច្រកលក់ទំនិញមួយក្នុងចំណោមច្រកលក់ទំនិញដ៏មានសក្តានុពលខ្ពស់បំផុតសំរាប់ផលិតផលក្នុងស្រុករបស់ខេត្តសៀមរាប និងប្រទេសកម្ពុជាទាំងមូល។ ការតាំងពិព័រណ៍ផលិតផលអង្គរគឺជាការប៉ុនប៉ងដំបូងមួយនៅសៀមរាប ដើម្បីតាំងបង្ហាញផលិតផលក្នុងស្រុកមួយចំនួន ដែលអាចមានសក្តានុពលចូលទីផ្សារអន្តរជាតិ។ អ្នកលក់ អ្នកទិញ និងអ្នកជំនួញជាច្រើនមកពីសៀមរាប ភ្នំពេញ និងបរទេសបានបង្ហាញការចាប់អារម្មណ៍ខ្ពស់លើការការតាំងពិព័រណ៍។

### ២. គោលបំណង

គោលបំណងនៃការតាំងពិព័រណ៍គឺដើម្បីលើកកំពស់ឧស្សាហកម្មសហគមន៍ និងក្នុងស្រុក ដោយបង្កើតឱ្យមានឱកាសជាច្រើនសំរាប់ភ្ជាប់បណ្តាញព័ត៌មាន បង្កើតវត្ថុលើកទឹកចិត្ត និងការលើកទឹកចិត្តដើម្បីលើកកំពស់ និងកែលំអដល់ការរៀបចំម៉ូត និងបច្ចេកទេស និងឱកាសសំរាប់ទំនាក់ទំនងសាធារណៈ និងបង្កើនការលក់ទំនិញ។ គោលដៅចុងក្រោយនៅពេលអនាគតខាងមុខគឺការអភិវឌ្ឍន៍ផលិតផលក្នុងស្រុក និងផ្លាកសញ្ញាថ្មី។

### ៩.២.២ ការពិពណ៌នាគំរោង

ការពិពណ៌នារួមរបស់គំរោង ការរំពឹងទុកក្នុងការភ្ជាប់ "**អ្នកលក់ និងអ្នកទិញ**" និង ប្រវត្តិសង្ខេបនៃអ្នកតាំងពិព័រណ៍មានបង្ហាញក្នុងតារាងដូចខាងក្រោម :

**តារាង ២៦ : ការពិពណ៌នានៃគំរោងតាំងពិព័រណ៍ផលិតផលអង្គរ២០០៥**

| រាយមុខ | ការពិពណ៌នា |
|---|---|
| អ្នកចូលរួម ( អ្នកតាំងពិព័រណ៍) | អ្នកតាំងពិព័រណ៍ គឺជាអ្នកផលិត ឬអ្នកច្នៃផលិតផលក្នុងស្រុកដ៏ពិសេសប្រកបដោយភាពទាក់ទាញ។ ផលិតផលក្នុងស្រុករួមមានសិល្បៈ វត្ថុអនុស្សាវរីយ៍ ផលិតផលកសិកម្មផ្អែកលើវប្បធម៌ប្រពៃណី ធម្មជាតិ និងធនធាន។ មានការរំពឹងថានឹងមានអ្នកចូលរួមតាំងពិព័រណ៍ប្រមាណ៦០នាក់ ( សូមមើលតារាង) |
| ទីកន្លែង | សណ្ឋាគារអង្គរសិនជូរីស្ព៉ា និងរីស៊ត ក្រុងសៀមរាប ( កន្លែងតាំងពិព័រណ៍ទាំងក្នុង និងក្រៅមានចំនួន ៦០តូប ) ។ |
| កាលបរិច្ឆេទ | ថ្ងៃទី០៩ ដល់ ១១ ខែធ្នូ ២០០៥ ( ពីម៉ោង ៩ព្រឹក ដល់ម៉ោង៩យប់ រៀងរាល់ថ្ងៃ)<br>ថ្ងៃទី០៩ ទិវាអាជីកម្ម ពិព័រណ៍ផលិតផលអង្គរប្រកបដោយគុណភាព<br>ថ្ងៃទី១០ ដល់ ១១ ការចូលទស្សនារបស់សាធារណៈជន |
| ថ្លៃចូលទស្សនា និងថ្លៃស្តង់ | មិនគិតថ្លៃ |
| អ្នករៀបចំ | សាលាខេត្តសៀមរាប<br>ដឹកនាំដោយអភិបាលខេត្ត/ ប្រធានប្រតិបត្តិៈអភិបាល : ខេត្តរង/ នាយកប្រតិបត្តិ = អ្នកដឹកនាំក្រុមការងារ |

| | |
|---|---|
| | សហអ្នករៀបចំ : អប្សរា និង JICA<br>អ្នកគាំទ្រ : ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ : ក្រសួងកសិកម្ម សភាពាណិជ្ជកម្មខេត្តសៀមរាប សភាពាណិជ្ជកម្ម រាជធានីភ្នំពេញ សមាគមសណ្ឋាគារកម្ពុជា សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា |
| ក្រុមការងារ ( ការិយាល័យរដ្ឋបាល និងប្រតិបត្តិ) | ក្រុមការងាររួមមានរដ្ឋាភិបាលខេត្ត និងក្រុមសមភាគី<br>មន្ត្រីប្រធានប្រតិបត្តិនៃក្រុមត្រូវបានជ្រើសតាំងពីអភិបាលរងខេត្តពីររូប និងនាយកប្រតិបត្តិត្រូវបានជ្រើសរើសជាមេដឹកនាំក្រុម ។ ក្រុមនេះទទួលបន្ទុកជ្រើសរើសផលិតផលអង្គរ និងការប្រតិបត្តិការតាំងពិព័រណ៍ទាំងមូល ។<br>ក្រុមសិក្សា JICA គាំទ្រក្រុមនេះ ក្នុងឋានៈជាទីប្រឹក្សាផ្តល់យោបល់ និងផ្តល់ជំនួយ ជូលអ្នកជំនួយការនៅមូលដ្ឋានសំរាប់ជួយការងារតាំងពិព័រណ៍ និងជាក្រុមជួយដល់ក្រុមការងារ ។ |
| ក្រុមវាយតំលៃ | ក្រុមសិក្សារៀបចំធ្វើការប្រកួតប្រជែងផលិតផលអង្គរដែលមានគុណភាពក្នុងអំឡុងពេលតាំងពិព័រណ៍ ។ ផលិតផលឆ្នើមនឹងត្រូវគេជ្រើសរើសផ្តល់រង្វាន់។ ក្រុមវាយតំលៃ រួមមាន ក្រុមសិក្សា ក្រុមការងារ អ្នកឯកទេសសិប្បកម្ម និងផលិតផលកសិកម្មត្រូវ បានគេរៀបចំសំរាប់ការកោតសរសើរ ។ ក្រុមវាយតំលៃពិនិត្យឫត្រួតពិនិត្យឡើងវិញ ពីភាពសុទ្ធ និងលក្ខណៈពិសេសនៃផលិតផលដែលកំពុងដាក់តាំង។ លក្ខណៈវិនិច្ឆ័យសំរាប់ការវាយតំលៃរួមមានសំភារៈ ការគូរ ដំណើរការផលិតកម្ម និងគុណភាពនៃផលិតផល ។ ក្រុមវាយតំលៃ,ផ្តល់រង្វាន់ផលិតគុណភាពអង្គរដល់ផលិតផលឆ្នើមត្រូវបានជ្រើសរើស ។ |

**តារាង ២៧ : ប្រភេទនៃអ្នកទិញសំខាន់សំរាប់ជាការគិតគូររបស់អ្នកតាំងពិព័រណ៍ (តាមប្រភេទអ្នកទិញ)**

| ប្រភេទអ្នកលក់ | | (១) ប្រភេទគូរមានគំនិតផ្តួចផ្តើម | | (២) ប្រភេទអ្នកផលិតមានគំនិតផ្តួចផ្តើម | | (៣) ប្រភេទការងារ |
|---|---|---|---|---|---|---|
| លក្ខណៈអ្នកលក់ | ម្ចាស់ហាង | ម្ចាស់កម្មសិទ្ធិជនជាតិបរទេសភាគច្រើន | | ម្ចាស់កម្មសិទ្ធិក្នុងស្រុកភាគច្រើន | | គំនិតផ្តួចផ្តើមតាមភូមិ |
| | ប្រភេទរោងជាង | រោងជាងតាមភូមិ ឬក្នុងផ្ទះ | | រោងជាងក្នុងផ្ទះ | | រោងជាងតាមភូមិ និងក្នុងផ្ទះ |
| | ផលិតផលសំខាន់ | ផលិតផលសូត្រ ចំលាក់ថ្ម និងឈើ និងថ្នាំលាប | | ចំលាក់ថ្ម និងឈើ សិល្បៈស្មូន សូត្រ ថ្នាំលាប និងផលិតផលកូតុង | | កញ្ជើ ល្អី ផលិតផលសូត្រ ចំលាក់ស្បែក |
| | គុណភាពផលិតផល | ខ្ពស់ | កណ្តាល | ខ្ពស់ | កណ្តាល | កណ្តាល-ទាប |
| សក្តានុពលសំរាប់ទីផ្សារ : ប្រភេទអាជីវកម្ម | សណ្ឋាគាថ្នាក់ខ្ពស់ និងហាង | ក | ខ | ក | ខ | |
| | សណ្ឋាគារថ្នាក់ខ្ពស់ និងហាង | | ក | ខ | ក | ក |
| | អ្នកធ្វើជំនួញធំ និងអ្នកនាំចេញ | ក | ក | ក | ខ | |
| | អាហារដ្ឋាន | ខ | ខ | ខ | ខ | ខ |
| | ហាងលក់វត្ថុអនុស្សាវរីយ៍ | | ខ | ខ | ក | ក |

| | | | | | | |
|---|---|---|---|---|---|---|
| | ហាងលក់វត្ថុអនុស្សាវរីយ៍ | | | | ខ | ខ |
| ក្រុមគោលដៅសំខាន់ៗសំរាប់ផលិតផល | | សណ្ឋាគារថ្នាក់ខ្ពស់ ហាង និង អ្នកនាំចេញ | សណ្ឋាគារថ្នាក់កណ្តាល ហាង និងអ្នកនាំចេញ | សណ្ឋាគារថ្នាក់ខ្ពស់ ហាង និង អ្នកនាំចេញ | សណ្ឋាគារកណ្តាល ហាង និងហាងវត្ថុអនុស្សាវរីយ៍ | សណ្ឋាគារកណ្តាល ហាង និងហាងវត្ថុអនុស្សាវរីយ៍ |

**កំណត់សំគាល់៖ ក : អ្នកទិញគោលដៅបឋម ខ : អ្នកទិញគោលដៅ**

**តារាង ២៨ : សេចក្តីសង្ខេបនៃអ្នកចូលរួមតាំងពិព័រណ៌នៅក្នុង "ការតាំងពិព័រណ៌ផលិតផលរង្គសរ២០០៥"**

| **ក្រុមអ្នកផលិត** | **ប្រភេទផលិតផល** | **ចំនួនអ្នកតាំងពិព័រណ៌** |
|---|---|---|
| ក្រុមអ្នកកែច្នៃ និងអ្នកផលិត | ផលិតផលសូត្រ | 10 |
| | សិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ | 10 |
| | ចំលាក់ឈើ ថ្ម និងគំនូរ | 10 |
| ក្រុមផលិតតាមភូមិ និង ការងារសង្គម | ផលិតផលសូត្រ | 5 |
| | ចំលាក់ស្បែក | 2 |
| | ល្អី កញ្ជើ | 2 |
| | ផ្កាសិប្បនិម្មិត | 2 |
| | សំលី និង ផ្សេងៗ | 2 |
| ក្រុមអ្នកផលិតនៃផលិតផលកសិកម្ម | ធ្វើម្ហូប | 3 |
| | បន្លែ | 4 |
| | ការចិញ្ចឹមសត្វ | 2 |
| | ផ្លែឈើ | 1 |
| | អង្ករ | 1 |
| សរុប | | 54 |

### ៩.២.៣ លទ្ធផលនៃគំរោងសាកល្បង

### ១. ចំនួនអ្នកចូលទស្សនាការតាំងពិព័រណ៌

អំឡុងពេលបីថ្ងៃនៃការតាំងពិព័រណ៌ មានអ្នកចូលទស្សនាប្រមាណ១០.០០០ នាក់ ក្នុងនោះ ១៥% គឺជាភ្ញៀវទេសចរ ៧% គឺជាអ្នកធ្វើជំនួញ និង ៧៨% គឺជាអ្នកស្រុក។




ប្រភព: ក្រុមសិក្សា JICA

រូបទី ៦៦ : ចំនួនអ្នកចូលទស្សនាការតាំងពិព័រណ៍

## ២. បទសំភាសន៍ ដើម្បីវាយតំលៃជាមួយអ្នកចូលរួមតាំងពិព័រណ៍ និងអ្នកចូលទស្សនា

អំឡុងពេលនៃការតាំងពិព័រណ៍ កិច្ចសម្ភាសន៍វាយតំលៃការត្រូវបានធ្វើឡើង។ លទ្ធផលបង្ហាញថា ក្រុមអ្នកចូលរួមទាំងអស់យល់ថា ការតាំងពិព័រណ៍មានសារៈប្រយោជន៍ និងធ្វើការវាយតំលៃជាវិជ្ជមានពីសក្តានុពលនៃការតាំងពិព័រណ៍សំរាប់ថ្ងៃអនាគត។ លទ្ធផលចំបងនៃការស្ទង់មតិ និងការពន្យល់មានសង្ខេបដូចខាងក្រោម:

**<u>លទ្ធផលនៃបទសម្ភាសន៍ ក (សំរាប់អ្នកចូលរួមតាំងពិព័រណ៍ ២៦ នាក់)</u>**

បានទទួលស្គាល់គុណសម្បត្តិនៃការចូលរួមពិព័រណ៍នេះ (១០០% : មានគុណសម្បត្តិ និងគ្មានគុណសម្បត្តិ : ០%)

| ការពិពណ៌នាលំអិត | បាទ | ទេ |
|---|---|---|
| ១. ការលើកកំពស់ទីផ្សារ | 100% | 0% |
| ២. ទទួលបានព័ត៌មាន និងតំរូវការពីអ្នកទិញ | 88% | 12% |
| ៣. ជួបជាមួយអ្នកទិញមកពី | 88% | 12% |
| - សណ្ឋាគារ ភោជនីយដ្ឋាន | 88% | 12% |
| - ហាងទំនិញ | 65% | 35% |
| - អ្នកជំនួញ | 58% | 42% |
| ៤. ជួបភ្ញៀវទេសចរ | 100% | 0% |
| ៥. ជួបជាមួយអ្នកស្រុកមូលដ្ឋាន | 100% | 0% |
| ៦. ទទួលតំរូវការកែលំអគុណភាព | 85% | 15% |
| ៧. មានស្មារតីប្រកួតប្រជែង | 96% | 4% |
| ៨. ត្រូវការកិច្ចសហប្រតិបត្តិការក្នុងចំណោមផលិតករក្នុងស្រុក | 73% | 27% |
| ៩. ត្រូវការកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន | 50% | 50% |
| ១០. ចូលរួមការតាំងពិព័រណ៍លើកក្រោយ | 100% | 0% |

## លទ្ធផលកិច្ចសំភាសន៍ ខ សំរាប់អ្នកទិញ (សណ្ឋាគារ ភោជនីយដ្ឋាន ហាង អ្នកជំនួញ (១១ នាក់)

ការចាប់អារម្មណ៍នៃការតាំងពិព័រណ៍ ( ល្អ ១00% និងទេ 0 %)

បានទទួលស្គាល់គុណសម្បត្តិនៃការចូលរួមពិព័រណ៍នេះ ( បាន ១00% និង ទេ 0%)

| ការពិពណ៌នាលំអិត | បាន | ទេ |
|---|---|---|
| ១) រកឃើញផលិផលថ្មី | 91% | 9% |
| ២) ជួបជាមួយអ្នកផលិតថ្មី | 82% | 18% |
| ៣) រកឃើញផលិតផលមានគុណភាព | 100% | 0% |
| ៤) ទទួលស្គាល់ផលិតផលអង្គរ ( ផលិតផលក្នុងស្រុក) | 91% | 9% |
| ៥) ទទួលព័ត៌មានពីអ្នកផលិត និងផលិតផល | 91% | 9% |
| ៦) រីករាយនឹងការតាំងពិព័រណ៍ ព្រឹត្តិការណ៍ អាហារ | ពិព័រណ៍ភាគច្រើន 91% | ព្រឹត្តិការណ៍ភាគច្រើន 9% |
| ៧) ចូលរួមការតាំងពិព័រណ៍លើកក្រោយ | 100% | 0% |

## លទ្ធផលកិច្ចសម្ភាស៍ គ សំរាប់ភ្ញៀវទេសចរ (១0 នាក់)

*ការចាប់អារម្មណ៍លើការតាំងពិព័រណ៍ ( ល្អ ១00% ទេ 0 %)*

បានទទួលស្គាល់គុណសម្បត្តិនៃការចូលរួមការតាំងពិព័រណ៍នេះ ( បាន ១00% និងទេ 0%)

| ការពិពណ៌នាលំអិត | បាន | ទេ |
|---|---|---|
| ១) រកឃើញផលិផលថ្មី | 90% | 10% |
| ២) ជួបជាមួយអ្នកផលិតថ្មី | 90% | 10% |
| ៣) រកឃើញផលិតផលមានគុណភាព | 90% | 10% |
| ៤) ទទួលស្គាល់ផលិតផលអង្គរ ( ផលិតផលក្នុងស្រុក) | 80% | 20% |
| ៥) ទទួលព័ត៌មានពីអ្នកផលិត និងផលិតផល | 70% | 30% |
| ៦) រីករាយនឹងការតាំងពិព័រណ៍ ព្រឹត្តិការណ៍ អាហារ | ពិព័រណ៍ភាគច្រើន 100% | ព្រឹត្តិការណ៍ភាគច្រើន 0% |
| ៧) ចូលរួមការតាំងពិព័រណ៍លើកក្រោយ | 100% | 0% |

## លទ្ធផលកិច្ចសម្ភាស ឃ សំរាប់ (អ្នកស្រុក) (២៣ នាក់)

ការចាប់អារម្មណ៍លើការតាំងពិព័រណ៍ ( ល្អ ១00% និង ទេ 0 %)

បានទទួលស្គាល់គុណសម្បត្តិនៃការចូលរួម ពិព័រណ៍នេះ ( បាន ១00% ទេ 0%)

| ការពិពណ៌នាលំអិត | បាន | ទេ |
|---|---|---|
| ១) រកឃើញផលិផលថ្មី | 100% | 0% |
| ២) ជួបជាមួយអ្នកផលិតថ្មី | 78% | 12% |
| ៣) រកឃើញផលិតផលមានគុណភាព | 100% | 0% |

| | | |
|---|---|---|
| ៤) ទទួលស្គាល់ផលិតផលអង្គរ (ផលិតផលក្នុងស្រុក) | 96% | 4% |
| ៥) ទទួលព័ត៌មានពីអ្នកផលិតនិងផលិតផល | 96% | 4% |
| ៦) រីករាយនឹងការតាំងពិព័រណ៍ ព្រឹត្តិការណ៍ អាហារ | ពិព័រណ៍ភាគច្រើន 96% | ព្រឹត្តិការណ៍ភាគច្រើន 4% |
| ៧) ចូលរួមពិព័រណ៍លើកក្រោយ | 100% | 0% |

**៩.២.៤ មេរៀនជាបទពិសោធន៍ និងអនុសាសន៍**

**១. ពិព័រណ៍ផលិតផលអង្គរបានក្លាយទៅជាគំរូមាននិរន្តរភាពមួយ**

- គំរោងសាកល្បង "ការតាំងពិព័រណ៍ផលិតផលអង្គរ ២០០៥" បង្ហាញពីគំរូនៃវិធានការផ្សព្វផ្សាយផលិតផលក្នុងស្រុកប្រកបដោយជោគជ័យ។
- ក្រុមការងារតាំងពិព័រណ៍ (APPC) ត្រូវបានបង្កើតឡើងដែលមានជាអ្នកដឹកនាំមូលដ្ឋានដែលមានសមត្ថភាព និងមានការអនុវត្តការងារជាក្រុមបានល្អ។ APPC បានសហការជាមួយនឹងផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចាត់ចែង និងរៀបចំការតាំងពិព័រណ៍។
- APPC មិនត្រឹមតែបានទទួលការគាំទ្រដោយមន្ទីរខេត្តនានាប៉ុណ្ណោះទេ ថែមទាំងក្រសួងជាច្រើននៃ រដ្ឋាភិបាលរបស់ថ្នាក់ជាតិផងដែរ ដូចជា ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ និងវិចិត្រសិល្បៈ កសិកម្ម និងទេសចរណ៍។
- អ្នកចូលរួមតាំងពិព័រណ៍ និងអ្នកទស្សនាស្ទើរតែទាំងអស់បានវាយតំលៃពិព័រណ៍យ៉ាងវិជ្ជមាន និងបានបង្ហាញក្តីសង្ឃឹមសំរាប់ពិព័រណ៍លើកក្រោយៗ។ ពួកគេបានត្រៀមខ្លួនជាស្រេចសំរាប់ការតាំងពិព័រណ៍ថ្មីៗ។
- APPC ទទួលបានអ្នកគាំទ្រ ឬអ្នកធានាសំរាប់ការតាំងពិព័រណ៍លើកក្រោយ ដូចជា សភាពាណិជ្ជកម្ម សៀមរាប អង្គការ ILO អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនធំៗ។

**២. ភាពចាំបាច់នៃ APPC ក្នុងឋានៈជាអង្គការចាត់តាំងកណ្តាលអចិន្ត្រៃយ៍សំរាប់ការតាំងពិព័រណ៍**

- អាជ្ញាធរខេត្តមិនទាន់មានអង្គការចាត់តាំងកណ្តាលសំរាប់សំរបសំរួល ឬណែនាំឱ្យបានទូលំទូលាយសំរាប់ផ្សព្វផ្សាយផលិតផលក្នុងស្រុកនៅឡើយទេ។ បើពិនិត្យស្ថានភាពបច្ចុប្បន្ន ក្រុមការងារសំរាប់តាំងពិព័រណ៍ (APPC) អាចបំពេញមុខងារនេះបាននៅពេលអនាគត។
- APPC បានធ្វើការស្រាវជ្រាវសំរាបសារពើភ័ណ្ឌ និងទិន្នន័យអំពីអ្នកផលិត និងបានចងក្រងព័ត៌មានទាក់ទងនឹងអ្នកផលិតទាំងនោះ។ ទន្ទឹមនឹងនេះ ពួកគេបានប្រមូលព័ត៌មានស្តីពីអ្នកទិញ ផលិតផលក្នុងស្រុក ដែលមានសក្តានុពល និងលើកកំពស់ការលក់ផលិតផលទាំងនោះ។ ព័ត៌មានបែបនេះអាចប្រើសំរាប់សកម្មភាពផ្សព្វផ្សាយផលិតផលថែមទៀត។
- APPC បានពង្រីកបណ្តាញសហប្រតិបត្តិការជាមួយក្រសួង មន្ទីរ សភាពាណិជ្ជកម្ម អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជនសំខាន់ៗ តាមរយៈការងាររៀបចំតាំងពិព័រណ៍។ បណ្តាញដូចនេះគួរតែត្រូវបានរក្សាទុក។

- APPC មិនត្រឹមតែមានព័ត៌មានដែលប្រមូលបានប៉ុណ្ណោះទេ ថែមទាំងបានសិក្សា និងស្គាល់ពីទំហំនៃការកែលំអ និងការអភិវឌ្ឍន៍ផលិតផលក្នុងស្រុក។ ព័ត៌មានបែបនេះអាចប្រើសំរាប់ សកម្មភាពផ្សព្វផ្សាយ ផលិតផលថែមទៀត។
- តាមរយៈការរៀបចំការតាំងពិព័រណ៍ និងសកម្មភាពគ្រប់គ្រងនានា APPCបានបង្ហាញពីតួនាទីគំរូមួយនៃអង្គការចាត់តាំងកណ្តាលសំរាប់លើកកំពស់ និងផ្សព្វផ្សាយផលិតផលក្នុងស្រុក។

## ៣. ការធ្វើអោយឱ្យផុសចេញទីផ្សារលំដាប់ថ្នាក់កណ្តាលថ្មី សំរាប់អ្នកស្រុកមូលដ្ឋាន

- តាមរយៈការរៀបចំការតាំងពិព័រណ៍បង្ហាញថា ទីផ្សារសំរាប់អ្នកស្រុកមូលដ្ឋានបាន និងកំពុងកើតឡើង។ ចំនួនអ្នកទស្សនាមូលដ្ឋានមានរហូតដល់ ៨.០០០ នាក់ ដែលចំនួននេះច្រើនជាងពីរដងនៃការរំពឹងទុក។ ជាមួយគ្នានេះ ពួកគេបានជាវទំនិញយ៉ាងច្រើន ដែលមានតំលៃសមរម្យ។
- បន្ថែមលើការរីកលូតលាស់ទីផ្សារទាក់ទងនឹងទេសចរណ៍ ការកើតឡើងនៃទីផ្សារសំរាប់អ្នកស្រុកមូលដ្ឋានមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់ផលិតករក្នុងស្រុក ដែលជាទីផ្សារថ្មីមួយនាថ្ងៃអនាគត។ ការអភិវឌ្ឍន៍ផលិតផលមានគុណភាពលំដាប់ថ្នាក់កណ្តាលសំដៅលើទីផ្សារនេះគឺជាការងារដែលមិនអាចខ្វះបានឡើយ( សូមមើលរូបខាងលើ)។
- ការតាំងពិព័រណ៍ផលិតផលអង្គរនឹងក្លាយទៅជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ដើម្បីភ្ជាប់ការផ្សព្វផ្សាយ ឬពង្រីកផលិតផលក្នុងស្រុកសំរាប់វិស័យទេសចរណ៍ និងទីផ្សារសំរាប់ប្រជាជនមូលដ្ឋាន។

## ៤. ការបង្ហាញពីភាពជះឥទ្ធិពល និងការផ្ទេរបច្ចេកវិទ្យាតាមរយៈការតាំងពិព័រណ៍

- អ្នកចូលរួមតាំងពិព័រណ៍ចំនួន៥៦នាក់ ដែលមានទំនិញគ្រប់បែបយ៉ាង និងអ្នកទស្សនាជាង ១០.០០០ នាក់ បានចូលរួមការតាំងពិព័រណ៍។ មនុស្សស្ទើរតែទាំងនេះបានវាយតំលៃពិព័រណ៍យ៉ាងវិជ្ជមាន។ ការនេះបង្ហាញថា ការតាំងពិព័រណ៍គឺជាវិធានការមួយក្នុងការផ្សព្វផ្សាយ និងលើកកំពស់ផលិតផលក្នុងស្រុក។
- ទោះបីជាយ៉ាងណាក៏ដោយ មានតែអ្នកចូលរួមតាំងពិព័រណ៍ចំនួន ៥០% ប៉ុណ្ណោះ ដែលបានផ្តល់បទសម្ភាសន៍បានបញ្ចេញប្រតិកម្មវិជ្ជមានចំពោះតំរូវការសហការជាមួយអាជ្ញាធរមូលដ្ឋាន។ ការនេះបង្ហាញឱ្យឃើញថា ការបញ្ជ្រាបគោលនយោបាយផ្សព្វផ្សាយ និងវិធានការរបស់អាជ្ញាធរខេត្តនៅមិនទាន់បានទូលំទូលាយនៅឡើយ។
- ក្រុមការងារតាំងពិព័រណ៍ APPCដែលមានអ្នកដឹកនាំម្នាក់ដែលមានសមត្ថភាពឆ្លុះបញ្ចាំងឱ្យឃើញថា ការផ្ទេរបច្ចេកទេសរបស់ក្រុមសិក្សា JICA ទៅឱ្យសមភាគីការងារមូលដ្ឋានមានប្រសិទ្ធភាពខ្ពស់។
- APPC បានពិនិត្យការងារតាំងពិព័រណ៍ឡើងវិញ ហើយបានរកឃើញពីរបៀបកែលំអការងារតាំងពិព័រណ៍នៅពេលក្រោយៗទៀត។ ក្រុមការងារមានគំនិតជាមូលដ្ឋានសំរាប់ធ្វើផែនការតាំងពិព័រណ៍លើកក្រោយ។



ការតាំងពិព័រណ៍ក្រៅអាគារ



ការតាំងពិព័រណ៍ក្នុងអាគារ



ពិធីជូនរង្វាន់

## ១០. ការវាយតំលៃឥទ្ធិពលទេសចរណ៍លើសេដ្ឋកិច្ចក្នុងស្រុក

ផ្នែកនេះ ក្រុមសិក្សាធ្វើការពិនិត្យពីឥទ្ធិពលនៃវិស័យទេសចរណ៍លើសេដ្ឋកិច្ចក្នុងស្រុកក្នុងខេត្តសៀមរាប។ ការវិភាគនេះនឹងយកចិត្តទុកដាក់លើរចនាសម្ព័ន្ធចំណាយជាក់ស្តែងរបស់ភ្ញៀវទេសចរនៅក្នុងខេត្តសៀមរាប[2]។ ចំណុចសំខាន់ៗដែលត្រូវពិនិត្យមើលនោះ គឺថាតើការចំណាយទាំងនេះបង្កើតឱ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុក តម្លៃបន្ថែម (ប្រាក់ចំណូល) និងការងារបន្ថែមដែរឬយ៉ាងណា។

និយាយជារួម គេអាចធ្វើការសន្និដ្ឋានថា ការពង្រឹង "ទិសដៅទៅរកភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់" គឺជាកត្តាមួយក្នុងចំណោមកត្តាគ្រឹះទាំងឡាយដើម្បីធ្វើឱ្យសំរេចនូវកំណើនសេដ្ឋកិច្ច និងក្នុងពេលជាមួយគ្នានោះ រក្សាចំនួនភ្ញៀវទេសចរឱ្យនៅត្រឹមកម្រិតមួយដែលអាចគ្រប់គ្រងបាន ដើម្បីជាប្រយោជន៍ដល់បរិស្ថានក្រុង និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌បានយ៉ាងល្អផងដែរ។ "ការតំរង់ទិសដៅទៅរកភ្ញៀវទេសចរដែលមានការចំណាយខ្ពស់" នេះត្រូវបានប្រើប្រាស់ជាផ្នែកនៃគោលគំនិតទាំងឡាយក្នុងការធ្វើផែនការមេទាំងមូល។ ផ្នែកខាងក្រោមនេះនឹងអធិប្បាយអំពីមូលដ្ឋានវិភាគដើម្បីបញ្ជាក់ថា "ការតំរង់ទិសដៅទៅរកភ្ញៀវទេសចរមានការចំណាយខ្ពស់" នឹងផ្តល់ផលប្រយោជន៍ខ្ពស់ដល់ខេត្តសៀមរាប។

### ១០.១ ឥទ្ធិពលនៃការចំណាយរបស់ភ្ញៀវទេសចរលើសេដ្ឋកិច្ចបច្ចុប្បន្ន

#### ១០.១.១ ចំណាយរបស់ភ្ញៀវទេសចរដែលរក្សាទុកក្នុងខេត្តសៀមរាប

នៅឆ្នាំ២០០៤ ភ្ញៀវទេសចរអន្តរជាតិសរុបដែលបានមកទស្សនាខេត្តសៀមរាបមានចំនួនរហូតដល់៥៦០.០០០ នាក់។ តាមការប៉ាន់ស្មានឱ្យដឹងថា ការចំណាយរបស់ទេសចរអន្តរជាតិសរុប (ឬចំណាយលើការប្រើប្រាស់សរុប) មានចំនួន៩៧ លានដុល្លារ ដែលក្នុងនោះទឹកប្រាក់ចំនួន ៦៦,៥ លានដុល្លារត្រូវបានរក្សាទុកក្នុងខេត្តសៀមរាប។ ទឹកប្រាក់ចំនួន៣៧,២ លានដុល្លារគឺជាចំណាយទូទាត់នៅក្នុងស្រុក និង២៩,៣ លានដុល្លារ គឺជាទឹកប្រាក់បានមកពីតម្លៃបន្ថែម (បើប្រៀបធៀបជាមួយនឹងផលិតផលក្នុងស្រុកតាមតំបន់(GRDP)) ដែលទទួលបានពីវិស័យទេសចរណ៍ក្នុងស្រុក។ ការងារនៅក្នុងស្រុកចំនួន២៩.០០០ កើតចេញផ្ទាល់ពីវិស័យទេសចរណ៍។ ក្រៅពីនេះ ទឹកប្រាក់៣១,៧ លានដុល្លារនឹងហូរចេញពីខេត្តសៀមរាបក្នុងទម្រង់ជាចំណាយទូទាត់ (១៥លានដុល្លារ) និងជាទំរង់បែងចែកប្រាក់ចំណេញ (១៦,៧លានដុល្លារ) ទៅឱ្យការិយាល័យកណ្តាល វិនិយោគិន និងមនុស្សដែលរស់នៅកន្លែងផ្សេងៗទៀត។

មានមនុស្សជាច្រើនបានផ្តល់ហេតុផលថា កំណើនវិស័យទេសចរណ៍ និងតម្រូវការទំនិញប្រើប្រាស់ក្នុងក្រុងសៀមរាបពុំមានទំនាក់ទំនងឱ្យបានទូលំទូលាយជាមួយនឹងសេដ្ឋកិច្ចក្នុងស្រុកទេ។ ការផ្តល់ហេតុផលនេះគឺជាការត្រឹមត្រូវម្យ៉ាងដែរ ប្រសិនបើពិនិត្យលើទំនិញប្រើប្រាស់ ដែលភាគច្រើនគឺជាទំនិញនាំចូលពីខាងក្រៅ។

ទោះជាយ៉ាងនេះក្តី ការសន្និដ្ឋាននេះពុំមែនពិតទាំងស្រុងឡើយ ដោយឈរលើមូលដ្ឋានថា ថវិកាចំណាយទាំងអស់របស់ភ្ញៀវទេសចរមិនមែនហូរចេញទៅបរទេសនោះទេ។ ដូចបានលើកឡើងខាងលើរួចហើយថា ការប៉ាន់ស្មានបញ្ជាក់ថា

---

[2] ការចំណាយរបស់ទេសចររួមមាន : ចំណាយលើការស្នាក់នៅ ការធ្វើដំណើរក្នុងស្រុក វត្ថុអនុស្សាវរីយ៍ អាហារ និងវត្ថុផ្សេងៗទៀត ដែលភ្ញៀវបានទូទាត់ដោយផ្ទាល់ទៅអ្នកធ្វើអាជីវកម្មដែលមានទីតាំងនៅក្នុងខេត្តសៀមរាប។ ចំណាយលើសំបុត្រយន្តហោះ ថ្លៃព្រលានយន្តហោះ និងថ្លៃចូល ប្រាសាទអង្គរវត្តមិនត្រូវបានបញ្ចូលទៅក្នុងចំណាយខាងលើនេះទេ ព្រោះចំណាយទាំងនេះត្រូវបានចាត់ទុកថា គ្មានទាក់ទងគួរចាប់អារម្មណ៍ជាមួយនឹងសេដ្ឋកិច្ចក្នុងស្រុកសម្រាប់ពេលអនាគតទេ ដូច្នេះហើយបានជាមិនត្រូវបានបញ្ចូលទៅក្នុងគំរូរចនាសម្ព័ន្ធចំណាយ។

ការចំណាយរបស់ភ្ញៀវទេសចរច្រើនជាងពីរភាគបីនៃការចំណាយរបស់ភ្ញៀវទេសចរសរុបស្ថិតក្នុងខេត្តសៀមរាប ។ មានកត្តាសំខាន់ៗពីរដែលភ្ជាប់ការចំណាយរបស់ភ្ញៀវទេសចរទៅនឹងសេដ្ឋកិច្ចក្នុងស្រុកគឺ : ការបង្កើតឱ្យមានការងារធ្វើនៅក្នុងស្រុក និងការបង្កើតវិស័យពាណិជ្ជកម្មក្នុងស្រុកដែលមានសន្ទុះកាន់តែសកម្មឡើង ។

គេដឹងថា វិស័យទេសចរណ៍[3] និងសេវាកម្មជាទូទៅផ្តល់ការងារប្រើកំលាំងពលកម្មច្រើន ។ លក្ខណៈនៃវិស័យទេសចរណ៍បែបនេះត្រូវបានគេប្រទះឃើញនៅសៀមរាបផងដែរ ។ និយាយជារួម ការចំណាយរបស់ភ្ញៀវទេសចរចំនួន១៤ លានដុល្លារ ឬច្រើនជាង១៤%នៃការចំណាយសរុបត្រូវបានទូទាត់លើប្រាក់ខែបុគ្គលិកធ្វើការក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប ។ ជាងនេះទៀត ដោយសារតំលៃនៃកំលាំងពលកម្មទាប ចំនួនការងារដែលបានបង្កើតឡើងមានចំនួនច្រើន ។




**ប្រភព: ការប៉ាន់ស្មានរបស់ក្រុមសិក្សា JICA**

**រូបទី ៦៧ : រចនាសម្ព័ន្ធចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាបនៅឆ្នាំ ២០០៤**

ទំនិញនាំចូលក៏កំពុងបង្កើតឱ្យមានការងារធ្វើនៅក្នុងស្រុកយ៉ាងច្រើនផងដែរ ។ តាមការសង្កេតឱ្យដឹងថា អ្នកប្រើប្រាស់នៅក្នុងវិស័យទេសចរណ៍ ដូចជានៅតាមសណ្ឋាគារ ឬភោជនីយដ្ឋានភាគច្រើនទិញផលិតផលបរទេសពីហាងលក់ទំនិញរាយនៅសៀមរាប ។ ក្នុងករណីសណ្ឋាគារ ទំនិញចំនួន៦០% គឺជាទំនិញនាំចូលដែលម្ចាស់សណ្ឋាគារទិញពីហាងលក់ទំនិញរាយ និង១៨ % ទៀតទិញពីកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ។ បើទោះបីមានការទិញទំនិញច្រើនដូចនេះសំរាប់បំរើវិស័យទេសចរណ៍ក៏ដោយ វិស័យពាណិជ្ជកម្មចំណាយទឹកប្រាក់តែចំនួន២០%ដែលបានមកពីចំណូលនៃការលក់ទំនិញសរុបសំរាប់ប្រាក់ខែប៉ុណ្ណោះ ។ ទាក់ទងនឹងការបង្កើតឱ្យមានការងារពីផ្នែកសេវាកម្មក្នុងស្រុកវិញ ប្រភពដើមនៃការផ្គត់ផ្គង់ទំនិញពុំមានទំនាក់ទំនងអ្វីច្រើនឡើយ ។

កំណើននៃវិស័យពាណិជ្ជកម្មក៏ជាប្រការមួយល្អផងដែរ សម្រាប់អ្នកផលិតវត្ថុធាតុដើមនៅក្នុងស្រុក ។ នៅពេលមាន

[3] វិស័យទេសចរណ៍ត្រូវបានកំណត់ដោយបញ្ចូលវិស័យតូចៗទាំង៥ខាងក្រោមនេះគឺ : ភោជនីយដ្ឋាន សណ្ឋាគារ និងផ្ទះសំណាក់ សេវាកម្មដឹកជញ្ជូន ក្នុងស្រុក អ្នកលក់វត្ថុអនុស្សាវរីយ៍ និងអ្នកផ្តល់សេវាកម្មធ្វើដំណើរក្នុងស្រុកផ្សេងៗទៀត ។

បណ្តាញលក់ទំនិញធំៗ និងកាន់តែច្រើន អ្នកផលិតវត្ថុធាតុដើមកាន់តែមានឱកាសច្រើនក្នុងការរកទីផ្សារសំរាប់ផលិតផលរបស់គេ។ ទីផ្សារសំរាប់តំរូវការរបស់ភ្ញៀវទេសចរអាចជំរុញឱ្យអ្នកផលិតមួយចំនួនយកចិត្តទុកដាក់ខ្ពស់ក្នុងការផលិតផលិតផលដែលមានគុណភាពកាន់តែខ្ពស់ឡើង។

## ១០.១.២ ឥទ្ធិពលដែលកើតមានលើសេដ្ឋកិច្ច

បន្ថែមលើឥទ្ធិពលផ្ទាល់នៃការចំណាយក្នុងខេត្តរបស់ភ្ញៀវទេសចរនោះ មានឥទ្ធិពលសេដ្ឋកិច្ចផ្សេងៗទៀត ដែលបានកើតចេញពីឥទ្ធិពលផ្ទាល់ទាំងនោះ។ តាមការប៉ាន់ស្មានឱ្យដឹងថា ទឹកប្រាក់ចំនួន ៦៦.៥ លានដុល្លារដែលបានចំណាយជាដំបូងក្នុងវិស័យទេសចរណ៍នៅមូលដ្ឋានបានបង្កើតឱ្យមានការប្រើប្រាស់បន្ថែមចំនួន៣៨ លានដុល្លារ តំលៃបន្ថែមចំនួន៣៨ លានដុល្លារ (ស្មើនឹង GRDP) និងការងារមូលដ្ឋានក្នុងខេត្តសៀមរាបចំនួន១៤.៥ ពាន់ដុល្លារ ដែលជាផ្នែកផ្សេងៗទាក់ទងនឹងសេដ្ឋកិច្ច។

រចនាសម្ព័ន្ធរួមនៃឥទ្ធិពលសេដ្ឋកិច្ច នៃវិស័យទេសចរណ៍មានបង្ហាញនៅក្នុងរូបខាងក្រោម។




ប្រភព: ការប៉ាន់ស្មានរបស់ក្រុមសិក្សា JICA

**រូបទី ៦៨ : រចនាសម្ព័ន្ធនៃការជះឥទ្ធិពលលើសេដ្ឋកិច្ចដែលកើតពីការចំណាយរបស់ភ្ញៀវទេសចរនៅសៀមរាបឆ្នាំ ២០០៤**

ជារួម ការប៉ាន់ស្មានឥទ្ធិពលសរុបលើសេដ្ឋកិច្ចត្រូវបានសង្ខេបដាក់ក្នុងតារាងដូចខាងក្រោម។ តារាងនេះបង្ហាញយ៉ាងច្បាស់ថា វិស័យទេសចរណ៍គឺជាវិស័យមួយសំខាន់បំផុតចំពោះសេដ្ឋកិច្ចរបស់ខេត្តសៀមរាប។ តម្លៃបន្ថែមដែលបាន

មកពីទេសចរណ៍ និងដែលបានរក្សាក្នុងខេត្តសៀមរាបមានចំនួន១ភាគបួន(១/៤) នៃGRDP សរុបរបស់ខេត្ត។ ការងារសរុបចំនួនជិត១០%ត្រូវបានបង្កើតឡើង។

**តារាង ២៩ : ឥទ្ធិពលនៃវិស័យទេសចរណ៍លើសេដ្ឋកិច្ចបច្ចុប្បន្នក្នុងសៀមរាប ២០០៤**

| | (លាន ដុល្លា) ការប្រើប្រាស់ | (លាន ដុល្លា) GRDP | (000 នាក់) ការងារ | ចំណែក GRDP | ក្នុងខេត្ត ការងារ |
|---|---|---|---|---|---|
| **ខេត្ត សៀមរាប** | - | 285 | 456 | 100,0% | 100,0% |
| វិស័យទេសចរណ៍បង្កើតឱ្យមានឥទ្ធិពលក្នុងខេត្តសៀមរាប(ក+ខ+គ) | 172 | 67 | 44 | 23,5% | 9,6% |
| ភ្ញៀវទេសចរអន្តរជាតិក្នុងខេត្តសៀមរាប (ក) | 97 | - | - | - | - |
| វិស័យទេសចរណ៍ | 52 | 46 | - | 16,2% | - |
| ត្រូវរក្សាទុកក្នុងខេត្តសៀមរាប (ខ) | 37 | 29 | 29 | 10,3% | 6,4% |
| ឥទ្ធិពលដែលកើតមានក្នុងខេត្តសៀមរាប(គ) | 38 | 38 | 15 | 13,4% | 3,2% |

**ប្រភព: JST ប៉ាន់ស្មាន។**

## ១០.២ សេចក្ដីរំពឹងនៅពេលអនាគត

### ១០.២.១ ការកំណត់គោលដៅបន្ថែមលើ "ភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់"

សេចក្ដីរំពឹងនាពេលអនាគតអំពីឥទ្ធិពលវិស័យទេសចរណ៍លើសេដ្ឋកិច្ចអាស្រ័យលើកត្តាជាច្រើន រាប់តាំងពីសេវាកម្មទេសចរណ៍ប្រកបដោយគុណភាពខ្ពស់រហូតដល់ស្ថិរភាពសង្គម។ ទោះជាយ៉ាងនេះក៏ដោយ ចំណាយរបស់ភ្ញៀវទេសចរគឺជាចំណុចផ្ដើមនៃឥទ្ធិពលទេសចរណ៍ទៅលើសេដ្ឋកិច្ចដែលត្រូវតែពិនិត្យ និងអនុវត្ត។ ចំនួននៃការចំណាយនេះត្រូវកំណត់ដោយកត្តាបីយ៉ាងគឺ : ចំនួនភ្ញៀវទេសចរ រយៈពេលនៃការស្នាក់នៅ និងការចំណាយក្នុងមួយថ្ងៃរបស់ភ្ញៀវទេសចរម្នាក់ៗ។ ក្នុងផ្នែកក្របខ័ណ្ឌសកម្មភាពសំរាប់ធ្វើផែនការ ចំនួនភ្ញៀវទេសចរអន្តរជាតិនៅពេលអនាគតត្រូវបានកំណត់ថានឹងមានការកើនឡើងពី៥៦០.០០០ នាក់នៅឆ្នាំ២០០៤ ទៅ២ លាននាក់នៅឆ្នាំ២០២០។ ការកំណត់ដូចនេះគឺផ្អែកលើសេណារីយូ ដែលបានប៉ាន់ស្មានសំរាប់និរន្តរភាពនៃ "កំណើនទេសចរណ៍គុណភាព" ពុំមែនកំណើន "ទេសចរណ៍ប្រមូលផ្ដុំ" ទេ។

**តារាង ៣០ : រយៈពេលស្នាក់នៅជាមធ្យម និងការចំណាយរបស់ភ្ញៀវទេសចរក្នុងមួយនាក់ដោយលំដាប់តំលៃផ្សេងគ្នានៃសណ្ឋាគារ (ដុល្លារ ឆ្នាំ២០០៤)**

| លំដាប់តំលៃសណ្ឋាគារ | ចំណែកក្នុងភ្ញៀវទេសចរសរុប | រយៈពេលស្នាក់នៅជាមធ្យម(ក) | តំលៃជាមធ្យមសំរាប់ម្នាក់នៅសណ្ឋាគារមួយយប់ | ចំណាយសរុបសំរាប់ម្នាក់ក្នុងមួយថ្ងៃក្រៅពីសណ្ឋាគារ | ចំណាយសរុបសំ-រាប់ម្នាក់ក្នុង១ថ្ងៃ (ខ) | ចំណាយសរុបសំរាប់ម្នាក់ក្នុងមួយការធ្វើដំណើរ (ក)x(ខ) |
|---|---|---|---|---|---|---|
| ភ្ញៀវទេសចរបុគ្គល | 49% | 3,5 | 24 | 29 | 53 | 187 |
| 5 star: $200+ | 2% | 3,0 | 160 | 122 | 282 | 848 |
| 4 star: 100-199 | 4% | 3,4 | 75 | 44 | 119 | 403 |
| 3 star: 50-99 | 5% | 3,3 | 36 | 34 | 70 | 233 |
| 2 star: 20-49 | 12% | 3,6 | 16 | 28 | 44 | 159 |
| 1 star or less: LT20 | 25% | 3,6 | 3 | 16 | 19 | 70 |
| ភ្ញៀវទេសចរជាក្រុម | 51% | 2,1 | 39 | 38 | 77 | 163 |
| 5 star: $200+ | 5% | 2,5 | 100 | 55 | 155 | 389 |
| 4 star: 100-199 | 10% | 2,1 | 61 | 37 | 98 | 210 |
| 3 star: 50-99 | 20% | 2,0 | 31 | 44 | 75 | 150 |
| 2 star: 20-49 | 13% | 2,0 | 17 | 28 | 45 | 90 |
| 1 star or less: LT20 | 3% | 2,2 | 7 | 20 | 27 | 60 |
| **សរុប** | 100% | 2,8 | 32 | 34 | 65 | 183 |

**ប្រភព ការប៉ាន់ស្មានរបស់ក្រុមសិក្សា**។ ការអង្កេតលើវិស័យទេសចរណ៍ក្នុងក្រុងសៀមរាប/អង្គរ ២០០៥ របស់ក្រុមសិក្សា មើលព័ត៌មានលំអិតនៅក្នុងផ្នែក ៣.២ នៃជំពូកនេះ។
កំណត់សំគាល់ : ចំនួនសរុបមិនសុទ្ធតែមានលក្ខណៈដូចគ្នាឡើយ ដោយសារការគិតសំរួល

បើទោះបីមានកំណើនចំនួនភ្ញៀវទេសចរអន្តរជាតិរហូតដល់ ១,៤៦លាននាក់ក៏ដោយ ក៏កត្តាសំខាន់នោះគឺត្រូវតំរង់ទិសដៅទៅលើភ្ញៀវទេសចរដែល"ស្នាក់នៅយូរ" និង "ចំណាយច្រើនក្នុងមួយថ្ងៃ " ជាប្រយោជន៍ធ្វើឱ្យសំរេចកំរិតចំណាយខ្ពស់ជាអតិបរមា។ មានប្រភេទភ្ញៀវទេសចរដែលសមស្របបំផុតនឹងលក្ខណៈទាំងនេះ ពោលគឺជា "ភ្ញៀវទេសចរមិនមែនដើរកំសាន្តជាក្រុម" និងស្នាក់នៅតាមសណ្ឋាគារផ្កាយ៤ ឬលើសពីនេះ។ ដូចបានបង្ហាញក្នុងតារាង៣០ ភ្ញៀវប្រភេទនេះយ៉ាងហោចណាស់ស្នាក់នៅយូរជាងភ្ញៀវទេសចរជាក្រុមជាមធ្យមមួយយប់ដែរ និងចំណាយយ៉ាងហោចណាស់ច្រើនជាងពីរដង (ប្រហែល១០០ ដុល្លារ ឬច្រើនជាង) ក្នុងមួយថ្ងៃ បើប្រៀបធៀបជាមួយភ្ញៀវទេសចរ ដែលស្នាក់នៅសណ្ឋាគារផ្កាយ២ ឬថ្នាក់ទាបជាងនេះ។ ភ្ញៀវទេសចរ "ដែលមានការចំណាយច្រើន " ទាំងនោះគឺត្រូវតែជាក្រុមគោលដៅចំបងនាពេលអនាគត។

កត្តាដែលគួរចាប់អារម្មណ៍នោះគឺថា ភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់" នោះ ចំណាយច្រើនក្នុងពេលស្នាក់នៅរបស់គេ។ ដូចគ្នានេះដែរ ឥទ្ធិពលរួមនៃការចំណាយរបស់គេលើសេដ្ឋកិច្ចមានទំហំធំជាងឥទ្ធិពលនៃការចំណាយរបស់ភ្ញៀវទេសចរ "ដែលមានកំរិតចំណាយមធ្យម និងទាប"។ តារាង ៣១ បង្ហាញពីការគណនាសាកល្បងអំពីឥទ្ធិពលរបស់ភ្ញៀវទេសចរចំនួន ១០០០ នាក់ក្នុងក្រុមពីរផ្សេងគ្នាទៅលើសេដ្ឋកិច្ច។ ករណីទី១ គឺជាឥទ្ធិពលនៃភ្ញៀវទេសចរ ១០០០ នាក់ដែលធ្វើដំណើរកំសាន្តជាក្រុម និងស្នាក់នៅសណ្ឋាគារផ្កាយ៣។ ភ្ញៀវទេសចរប្រភេទនេះមានច្រើននាពេលបច្ចុប្បន្ន។ ករណីទី២គឺជាប្រភេទភ្ញៀវទេសចរមិនមែនជាក្រុម (ជាបុគ្គល)ចំនួន១០០០ នាក់ ដែលស្នាក់នៅសណ្ឋាគារផ្កាយ៤ និងជាក្រុមគោលដៅសំខាន់នាពេលអនាគត។ ភ្ញៀវទេសចរមិនមែនជាក្រុមដែលស្នាក់នៅសណ្ឋាគារផ្កាយ៤ចំណាយប្រាក់ចំនួន ២,៦ ដង និងបង្កើតឱ្យមានប្រាក់ចំណូល និងការងារ ២,៧ ដងច្រើនជាងភ្ញៀវទេសចរជាក្រុម ដែលស្នាក់នៅតាម

សណ្ឋាគារផ្កាយ៣។

**តារាង ៣១ : ការប្រៀបធៀបនៃការគណនាសាកល្បងនៃឥទ្ធិពលនៃការចំណាយរបស់ភ្ញៀវទេសចរអន្តរជាតិ ១០០០ នាក់ ដោយប្រភេទផ្សេងគ្នា**

| | ការជះឥទ្ធិពលនៃភ្ញៀវទេសចរ អន្តរជាតិ ១០០០នាក់ | | |
|---|---|---|---|
| | (000 ដុល្លារ) ការប្រើប្រាស់ | (000 ដុល្លារ) GRDP | (នាក់) ផ្តល់ការងារ |
| ករណីទី ១:ភ្ញៀវទេសចរជាក្រុម លំដាប់ផ្កាយ ៣ | | | |
| ឥទ្ធិពលនៃភ្ញៀវទេសចរសរុបក្នុងខេត្តសៀមរាប(ក+ខ+គ) | 268 | 103 | 67 |
| ភ្ញៀវទេសចរ ១០០០ក្នុងខេត្តសៀមរាប (ក) | 150 | - | - |
| វិស័យទេសចរណ៍ | 86 | 64 | - |
| ត្រូវរក្សាទុក ក្នុងខេត្តសៀមរាប (ខ) | 59 | 43 | 46 |
| ឥទ្ធិពលដែលកើតមាន ក្នុងខេត្តសៀមរាប (គ) | 60 | 60 | 22 |
| ករណីទី ២:ភ្ញៀវទេសចរមិនមែនជាក្រុមលំដាប់ផ្កាយ ៤ | | | |
| ឥទ្ធិពលនៃភ្ញៀវទេសចរសរុបក្នុងខេត្តសៀមរាប (ក+ខ+គ) | 701 | 275 | 179 |
| ភ្ញៀវទេសចរ ១០០០ក្នុងខេត្តសៀមរាប (ក) | 403 | - | - |
| វិស័យទេសចរណ៍ | 203 | 200 | - |
| ត្រូវរក្សាទុក ក្នុងខេត្តសៀមរាប (ខ) | 146 | 125 | 132 |
| ឥទ្ធិពលដែលកើតមានក្នុងខេត្តសៀមរាប (គ) | 153 | 151 | 47 |
| ប្រៀបធៀប :ករណីទី១ និង ករណីទី២ | អនុបាត = ករណី 2 ÷ ករណី 1 | | |
| ឥទ្ធិពលនៃភ្ញៀវទេសចរណ៍សរុបក្នុងខេត្តសៀមរាប (ក+ខ+គ) | 2,6 | 2,7 | 2,7 |
| ភ្ញៀវទេសចរ ១០០០ក្នុងខេត្តសៀមរាប (ក) | 2,7 | - | - |
| វិស័យទេសចរណ៍ | 2,4 | 3,1 | - |
| ត្រូវរក្សាទុក ក្នុងខេត្តសៀមរាប (ខ) | 2,5 | 2,9 | 2,9 |
| ឥទ្ធិពលដែលកើតមាន ក្នុងខេត្តសៀមរាប (គ) | 2,6 | 2,5 | 2,2 |

## ១០.២.២ របនាសម្ព័ន្ធទីផ្សារបច្ចុប្បន្ន

ម្យ៉ាងទៀត នាពេលបច្ចុប្បន្ននេះ ភ្ញៀវទេសចរមួយភាគធំនៅសៀមរាប គឺជាភ្ញៀវទេសចរ "ដែលមានកំរិតចំណាយមធ្យម និងទាប "។ ពាក់កណ្តាលភ្ញៀវទេសចរមិនមែនធ្វើដំណើរកំសាន្តជាក្រុម គឺជាភ្ញៀវដែលស្នាក់នៅសណ្ឋាគារ "ផ្កាយ ១ ឬទាបជាងនេះ (ចំណាយ ២០ ដុល្លារ ឬទាបជាងនេះ)។ ភ្ញៀវទេសចរម្នាក់ចំណាយប្រាក់តិចជាង ២០ ដុល្លារក្នុងមួយយប់។ ភ្ញៀវទេសចរជាក្រុមច្រើនស្នាក់នៅសណ្ឋាគារ "ផ្កាយ ៣ (ចំណាយ ៥០-១០០ដុល្លារ)។ ក្រុមគោលដៅសំខាន់ដែល "ធ្វើដំណើរកំសាន្តមិនមែនជាក្រុម និងស្នាក់នៅសណ្ឋាគារផ្កាយ ៤ និងខ្ពស់ជាងនេះ" មានចំនួនសរុបតែ៦% ប៉ុណ្ណោះ។ បច្ចុប្បន្ននេះ សៀមរាបហាក់ដូចជាមិនទាន់ទាក់ទាញបានភ្ញៀវទេសចរមិនមែនជាក្រុមដែល "មានកំរិតចំណាយខ្ពស់ " នៅ

ឡើយទេ។




ប្រភព: ការប៉ាន់ស្មានរបស់ក្រុមសិក្សា JICA

*រូបទី ៦៩ : ចំនួននៃភ្ញៀវទេសចរបែងចែកតាមកំរិតតំលៃស្នាក់នៅក្នុងសណ្ឋាគារនៅឆ្នាំ ២០០៤*

សៀមរាបនៅមានកិច្ចការជាច្រើនត្រូវធ្វើដើម្បីកំណត់ឡើងវិញនូវស្ថានភាពទីផ្សាររបស់ខ្លួនឱ្យក្លាយទៅជាកន្លែងដែលមានការទាក់ទាញភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់ "។ គុណភាពសេវាកម្មនៅតាមផ្នែកទាំងអស់នៅមានចន្លោះខ្វះខាតជាច្រើន ដែលត្រូវកែលំអ។ ការចង់ឱ្យមានដំណើរកំសាន្តជាក្រុមកាន់តែខ្លាំងឡើងបញ្ជាក់អោយឃើញថាកង្វះខាតសេវាកម្មសាធារណៈសមស្រប ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ដែលជួយទ្រទ្រង់ដល់ភ្ញៀវទេសចរមិនមែនធ្វើដំណើរកំសាន្តជាក្រុម។ និយាយជារួម សៀមរាបមិនទាន់មានភាពទាក់ទាញ ឬមិនទាន់បានបង្កលក្ខណៈងាយស្រួលឱ្យភ្ញៀវទេសចរមិនមែនជាក្រុមដើរកំសាន្តដោយខ្លួនឯងឡើយ។ នេះជាបញ្ហាមួយនៃបញ្ហាសំខាន់ៗជាច្រើនដែលត្រូវគិតគូរសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ និងអភិវឌ្ឍន៍ក្រុងសៀមរាប។ សូមមើលជំពូកពាក់ព័ន្ធផ្សេងៗចំពោះផែនការលំអិត ដើម្បីធ្វើឱ្យសំរេចឱ្យបាននូវ "វិស័យទេសចរណ៍មួយដែលមានគោលដៅលើភ្ញៀវទេសចរមានកំរិតចំណាយខ្ពស់ "។

## ១០.២.៣ ឥទ្ធិពលលើសេដ្ឋកិច្ចនៃការបង្វែរទៅរកភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់

បើធ្វើការគិតគូរថា ភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់ " ជាក្រុមគោលដៅសំខាន់នៅពេលអនាគត ករណីបីផ្សេងគ្នានៃឥទ្ធិពលដែលអាចកើតឡើងនៅឆ្នាំ២០២០ ត្រូវយកមកពិនិត្យសំរាប់ធ្វើការប្រៀបធៀប។ តារាង ៣២ គឺជាសេចក្តីសង្ខេបនៃការប៉ាន់ស្មានមួយចំនួន។

### ១. ការប៉ាន់ស្មានលើករណីគោល : "ទេសចរណ៍ប្រមូលផ្តុំ "

ករណីទីមួយគឺ "ករណីជាគោល" ដែលតំណាងនិន្នាការបច្ចុប្បន្ន ពោលគឺជានិន្នាការ "ទេសចរណ៍ប្រមូលផ្តុំ "។ ឥទ្ធិពលនេះត្រូវបានប៉ាន់ស្មានជាការពង្រីកបរិមាណធម្មតានៃរចនាសម្ព័ន្ធទីផ្សារបច្ចុប្បន្ន ដូចមានបង្ហាញនៅក្នុងរូបទី៧០។ ចំនួនភ្ញៀវទេសចរអន្តរជាតិ និង"ការស្នាក់នៅរបស់ភ្ញៀវទេសចរ" ត្រូវបានសន្មតថានឹងកើនឡើងដល់ ៣,៣៤ លាននាក់ និងស្នាក់នៅចំនួន ១១,៦៩ លានយប់នៅឆ្នាំ២០២០។ កំរិតចំនួននេះគឺស្របគ្នាទៅនឹងការព្យាករណ៍ទេសចរណ៍ "ដោយ

គ្មានអន្តរាគមន៍ពីគោលនយោបាយ "។

## ២. ករណីជំរើស : ពិនិត្យលើចំនួននៃភ្ញៀវទេសចរ និងការស្នាក់នៅ ដោយគ្មាន ឬមានការផ្លាស់ប្តូរទីផ្សារ

មានករណីជំរើសពីរសំរាប់ធ្វើការប្រៀបធៀប។ ក្នុងករណីទាំងពីរនេះ ចំនួនសរុបនៃភ្ញៀវទេសចរអន្តរជាតិមាន ២,០១ លាននាក់ ចំនួនសរុបនៃការ "ស្នាក់នៅរបស់ភ្ញៀវទេសចរ" មាន ៧,០២ លានយប់ និងរយៈពេលនៃការស្នាក់នៅជាមធ្យមមាន ៣,៥ យប់។ កំរិតទាំងនេះត្រូវបានកំណត់ជាផ្នែកនៃក្របខ័ណ្ឌសកម្មភាពសំរាប់ទេសចរណ៍ (ដោយមានករណីអន្តរាគមន៍ពីគោលនយោបាយ) ដូចមានពិភាក្សាក្នុងជំពូក ១០ ខាងក្រោម។ នេះមានន័យថា ចំនួនសរុបនៃ ភ្ញៀវទេសចរអន្តរជាតិត្រូវបានកំណត់ថាមានចំនួនស្មើគ្នារវាងករណីជំរើសទាំងពីរ។

"ករណីជំរើសទី១ : សមាសភាពទេសចរមិនផ្លាស់ប្តូរ " គឺជាករណីដែលធ្វើការកំណត់ចំនួនភ្ញៀវទេសចរ ដោយមិនកែប្រែប្រភេទទេសចរណ៍បច្ចុប្បន្ន "ដែលមានកំរិតចំណាយមធ្យម-ទាប"។ ដូច្នេះ ករណីនេះត្រូវបានគណនាជារបៀបនៃការពង្រីកទីផ្សារបច្ចុប្បន្ន ដោយសន្មត់ថា ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំនួននៃ "ការស្នាក់នៅរបស់ភ្ញៀវទេសចរ " នឹងកើនឡើងដល់ត្រឹមកំរិតនៃក្របខ័ណ្ឌសកម្មភាពទេសចរណ៍។

"ករណីជំរើសទី២ : សមាសភាពនៃភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់ " គឺជាករណីនៃការផ្លាស់ប្តូរទៅភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់ " របស់ខេត្តសៀមរាប។ តាមការប៉ាន់ស្មានឱ្យដឹងថា ចំណែកនៃភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់" នឹងកើនឡើង ហើយក្រុមភ្ញៀវទេសចរសំខាន់នេះនឹងត្រូវបានកែប្រែ ដូចមានបង្ហាញក្នុងរូបទី៧១[4]។ ចំណែកនៃក្រុមផ្សេងៗគ្នាត្រូវបានកំណត់ ស្របទៅតាមក្របខ័ណ្ឌសកម្មភាពសំរាប់ទេសចរណ៍នៅពេលអនាគត។




**រូបទី ៧០ : ការប៉ាន់ស្មានរបាយភ្ញៀវទេសចរតាមតំលៃសណ្ឋាគារសំរាប់ "ករណីជំរើសទី ២: សមាសភាពភ្ញៀវ ទេសចរ ដែលមានកំរិតចំណាយខ្ពស់ " នៅឆ្នាំ ២០២០**

[4] ទំរង់នៃរយៈពេលស្នាក់នៅដោយក្រុមតំលៃផ្សេងៗត្រូវបានកំណត់ដោយតំលៃប៉ាន់ស្មាន ដោយផ្អែកលើការពង្រីកនៃទំរង់បច្ចុប្បន្នដូចមានបង្ហាញនៅក្នុងតារាង ៣២។

**តារាង ៣២ : សេចក្តីសង្ខេបនៃការប៉ាន់ស្មានផ្សេងៗសំរាប់ធ្វើការគណនាសាកល្បង**

| សូចនាករវិស័យទេសចរណ៍ | 2004 ចំនុចស្ថាន | ការសន្និដ្ឋានលើការគណនាសាកល្បង ឆ្នាំ ២០២០ | | |
|---|---|---|---|---|
| | | ករណីគោល | ករណីជំរើស | |
| | | និន្នាការទេសចរណ៍បរិមាណ | ទី១:សមាសភាពមិនផ្លាស់ប្តូរ | ទី២:ចំណាយខ្ពស់ |
| ភ្ញៀវទេសចរបរទេសសរុប (000) | 561 | 3.340 | 2.007 | 2.007 |
| មិនមែនជាក្រុម | 275 | 1.637 | 983 | 973 |
| ជាក្រុម | 286 | 1.703 | 1.024 | 1.033 |
| ការស្នាក់នៅសរុបរបស់ភ្ញៀវទេសចរ (000) | 1.571 | 9.352 | 7.025 | 7.025 |
| ការចំណាយរបស់ទេសចរណ៍សរុប (លាន ដុល្លារ) | 96 | 575 | 433 | 702 |
| ការចំណាយជាមធ្យម របស់ភ្ញៀវទេសចរម្នាក់ក្នុងមួយថ្ងៃ (ដុល្លារ) | 61 | 61 | 62 | 100 |
| មិនមែនជាក្រុម | 53 | 53 | 53 | 113 |
| ជាក្រុម | 77 | 77 | 77 | 91 |
| រយៈពេលស្នាក់នៅជាមធ្យម (យប់) | 2,8 | 2,8 | 3,5 | 3,5 |
| មិនមែនជាក្រុម | 3,5 | 3,5 | 4,1 | 4,0 |
| ជាក្រុម | 2,1 | 2,1 | 2,9 | 3,0 |

| ប្រភេទភ្ញៀវទេសចរតាមលំដាប់ តំលៃសណ្ឋាគារ | 2004 ចំនុចប្រមាណ | | ការសន្និដ្ឋានលើការគណនាសាកល្បង ឆ្នាំ ២០២០ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ករណីគោល | | ករណីជំរើស | | | |
| | | | និន្នាការទេសចរណ៍បរិមាណ | | ទី១:សមាសភាពមិនផ្លាស់ប្តូរ | | ទី២:ចំណាយខ្ពស់ | |
| | ចំណែក | រយៈពេលស្នាក់នៅ | ចំណែក | រយៈពេលស្នាក់នៅ | ចំណែក | រយៈពេលស្នាក់នៅ | ចំណែក | រយៈពេលស្នាក់នៅ |
| ភ្ញៀវទេសចរគ្រប់ប្រភេទ | 100% | 2,8 | 100% | 2,8 | 100% | 3,5 | 100% | 3,5 |
| ភ្ញៀវទេសចរមិនមែនជាក្រុម | 49% | 3,5 | 49% | 3,5 | 49% | 4,1 | 49% | 4,0 |
| 200+ | 2% | 3,0 | 2% | 3,0 | 2% | 3,5 | 10% | 3,6 |
| 100-199 | 4% | 3,4 | 4% | 3,4 | 4% | 3,9 | 13% | 4,0 |
| 50-99 | 5% | 3,3 | 5% | 3,3 | 6% | 3,8 | 10% | 4,0 |
| 20-49 | 12% | 3,6 | 12% | 3,6 | 12% | 4,2 | 7% | 4,3 |
| LT20 | 25% | 3,6 | 25% | 3,6 | 25% | 4,2 | 9% | 4,3 |
| ភ្ញៀវទេសចរជាក្រុម | 51% | 2,1 | 51% | 2,1 | 51% | 2,9 | 51% | 3,0 |
| 200+ | 5% | 2,5 | 5% | 2,5 | 5% | 2,9 | 10% | 3,0 |
| 100-199 | 10% | 2,1 | 10% | 2,1 | 10% | 2,9 | 13% | 3,0 |
| 50-99 | 20% | 2,0 | 20% | 2,0 | 20% | 2,9 | 20% | 3,0 |
| 20-49 | 13% | 2,0 | 13% | 2,0 | 13% | 3,1 | 6% | 3,2 |
| LT20 | 3% | 2,2 | 3% | 2,2 | 3% | 3,2 | 1% | 3,4 |

## ៣. លទ្ធផល និងការប្រៀបធៀប

លទ្ធផលនិងការប្រៀបធៀបនៃការគណនាសាកល្បង ក្នុងចំណោមករណីទាំងបីត្រូវបានសង្ខេបក្នុងតារាង៣៣ ។

"ករណីជំរើសទី១ : សមាសភាពនៃភ្ញៀវទេសចរមិនផ្លាស់ប្តូរ" មានឥទ្ធិពលសេដ្ឋកិច្ចចំនួន ២៥% និងមានការងារចំនួន ៣៣% តិចជាងឥទ្ធិពលនៃ "ករណីជាគោល" ដែលមានចំពោះសេដ្ឋកិច្ចនៅសៀមរាប ។ ករណីនេះបង្ហាញថា ការបន្តឱ្យមាននិន្នាការទេសចរណ៍ដោយគ្មានការធ្វើអន្តរាគមន៍ណាមួយដើម្បីកែប្រែទីផ្សារទេសចរណ៍ក្នុងគោលបំណងកាត់បន្ថយសំពាធទេសចរណ៍លើប្រាសាទ និងក្រុងសៀមរាបទេនោះនឹងបណ្តាលឱ្យមានការខាតបង់យ៉ាងច្រើននូវឱកាសសេដ្ឋកិច្ច ។

"ករណីជំរើសទី២ : សមាសភាពនៃភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់គឺ "ជាករណីនៃទស្សនៈផ្សេងមួយសម្រាប់អនាគត ។ ទស្សនៈនេះកំណត់កំរិតដូចគ្នានៃចំនួនភ្ញៀវទេសចរ ២ លាននាក់ជាជំរើសមួយ ដែលក្នុងនេះកំរិតចំណាយមានចំនួន១.៣៤ តិចជាង "ករណីគោល (ករណីទេសចរណ៍ប្រមូលផ្តុំ) ។ ទោះជាយ៉ាងដូច្នេះក៏ដោយករណីទី២

នេះមានឥទ្ធិពលលើសេដ្ឋកិច្ចចំនួន១.២ ដងច្រើនជាងករណីគោល និងមានកំរិតនៃចំនួនការងារដូចជាករណីគោលដែរ។ ដូចនេះ ការបង្វែរទិសដៅទៅរកភ្ញៀវទេសចរ "ដែលមានកំរិតចំណាយខ្ពស់" គឺជាកត្តាចាំបាច់ដើម្បីធ្វើឱ្យសំរេចនិរន្តរភាព ដែលមិនចាំបាច់ព្រួយបារម្ភពីកំណើនភ្ញៀវទេសចរឡើយ ។

***តារាង ៣៣ : លទ្ធផលនៃការគណនាការធ្វើតេស្តការវាស់ឥទ្ធិពលលើសេដ្ឋកិច្ចនៃសមាសភាពផ្សេងគ្នារបស់ភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ ២០២០***

| ករណីគោល | ឥទ្ធិពលនៃភ្ញៀវទេសចរចំនួន ៣,៣៤ លាននាក់នៅឆ្នាំ 2020 | | |
|---|---|---|---|
| | ការប្រើប្រាស់ (លានដុល្លារ) | GRDP (លានដុល្លារ) | ការងារ (000 នាក់) |
| កំណើនតាមនិន្នាការ (ទេសចរណ៍ប្រមូលផ្តុំ) | | | |
| ឥទ្ធិពលសរុបក្នុងខេត្តសៀមរាប (a+b+c) | 1023 | 401 | 82 |
| ការចំណាយរបស់ភ្ញៀវទេសចរណ៍ក្នុងខេត្តសៀមរាប (a) | 575 | - | - |
| វិស័យទេសចរណ៍ | 310 | 265 | - |
| ចំនួយដែលរក្សាទុកក្នុងខេត្តសៀមរាប (b) | 221 | 175 | 55 |
| ឥទ្ធិពលដែលកើតមានក្នុងសៀមរាប (c) | 227 | 226 | 27 |
| ករណីជំរើស | ឥទ្ធិពលនៃភ្ញៀវទេសចរចំនួន ២ លាននាក់នៅឆ្នាំ 2020 | | |
| | ការប្រើប្រាស់ (លានដុល្លារ) | GRDP (លានដុល្លារ) | ការងារ (000 នាក់) |
| ករណីជំរើស១ : សមាសភាពមិនកែប្រែនៃភ្ញៀវទេសចរ | | | |
| ឥទ្ធិពលសរុបក្នុងខេត្តសៀមរាប (a+b+c) | 771 | 308 | 51 |
| ការចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាប (a) | 433 | - | - |
| វិស័យទេសចរណ៍ | 234 | 200 | - |
| ចំនួយដែលរក្សាទុកក្នុងខេត្តសៀមរាប (b) | 167 | 134 | 34 |
| ឥទ្ធិពលដែលកើតមានក្នុងសៀមរាប (c) | 171 | 174 | 17 |
| ករណីជំរើស២ : សមាសភាពភ្ញៀវចំណាយខ្ពស់ | | | |
| ឥទ្ធិពលសរុបក្នុងខេត្តសៀមរាប (a+b+c) | 1243 | 487 | 82 |
| ការចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាប (a) | 702 | - | - |
| វិស័យទេសចរណ៍ | 369 | 344 | - |
| ចំនួយដែលរក្សាទុកក្នុងខេត្តសៀមរាប (b) | 266 | 214 | 57 |
| ឥទ្ធិពលដែលកើតមានក្នុងសៀមរាប (c) | 275 | 273 | 25 |
| ការប្រៀបធៀប ករណីគោល vs ករណីជំរើស១ | អត្រាផលធៀប = ករណីជំរើស១ : ករណីគោល | | |
| ឥទ្ធិពលសរុបក្នុងខេត្តសៀមរាប (a+b+c) | 0,75 | 0,77 | 0,62 |
| ការចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាប (a) | 0,75 | - | - |
| វិស័យទេសចរណ៍ | 0,76 | 0,75 | - |
| ចំនួយដែលរក្សាទុកក្នុងខេត្តសៀមរាប (b) | 0,75 | 0,77 | 0,62 |
| ឥទ្ធិពលដែលកើតមានក្នុងសៀមរាប (c) | 0,75 | 0,77 | 0,62 |
| ការប្រៀបធៀប ករណីគោល vs ករណីជំរើស២ | អត្រាផលធៀប = ករណីជំរើស២ : ករណីគោល | | |
| ឥទ្ធិពលសរុបក្នុងខេត្តសៀមរាប (a+b+c) | 1,21 | 1,21 | 1,00 |
| ការចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាប (a) | 1,22 | - | - |
| វិស័យទេសចរណ៍ | 1,19 | 1,30 | - |
| ចំនួយដែលរក្សាទុកក្នុងខេត្តសៀមរាប (b) | 1,20 | 1,22 | 1,03 |
| ឥទ្ធិពលដែលកើតមានក្នុងសៀមរាប (c) | 1,21 | 1,21 | 0,94 |

**ប្រភព : ការប៉ាន់ស្មានរបស់ក្រុមសិក្សា និងការគណនាសាកល្បង**

# ១១. ក្របខ័ណ្ឌសកម្មភាពសំរាប់ធ្វើផែនការ

ដោយផ្អែកទៅលើស្ថានភាព ភាពខ្លាំង និងបញ្ហានានាខាងលើ ជំពូកនេះរៀបរាប់ពីក្របខ័ណ្ឌសកម្មភាពសំរាប់ធ្វើផែនការ ដើម្បីឈានទៅសំរេចចក្ខុវិស័យជាយុទ្ធសាស្ត្រ។ ក្របខ័ណ្ឌសកម្មភាពសំរាប់ធ្វើផែនការគឺជាវិធានការមួយសំរាប់សំរួលដល់កិច្ចសម្របសម្រួលអន្តរស្ថាប័ននៅថ្នាក់ខេត្ត/ស្រុក។ ក្របខ័ណ្ឌសំរាប់ធ្វើផែនការមាន : សេដ្ឋកិច្ច-សង្គម តំបន់ និងទេសចរណ៍។

## ១១.១ ក្របខ័ណ្ឌសកម្មភាពសេដ្ឋកិច្ចសង្គម

### ១១.១.១ ប្រជាជន

### ១. លក្ខណៈខេត្ត

ខេត្តសៀមរាបមានស្រុក ១២។ របាយប្រជាជនក្នុងស្រុកទាំង១២ មានបង្ហាញក្នុងរូបដូចខាងក្រោម។




ប្រភព : សាលាខេត្តដោយផ្អែកលើចំនួនប្រជាជនដែលបានចុះបញ្ជីក្នុងការិយាល័យឃុំ និងប៉ុស្តិ៍ប៉ូលិស។ ដូចនេះតួលេខនេះមានចំនួនប្រជាជនតិចជាងទិន្នន័យជំរឿន ដែលបានរាប់បញ្ចូលទាំងប្រជាជនដែលមិនបានចុះបញ្ជី។

**រូបទី ៧១ : ស្រុកទាំង ១២ និងរបាយប្រជាជនក្នុងខេត្តសៀមរាប**

តារាង ៣៤ : ផ្ទៃដី និងដង់ស៊ីតេប្រជាជនតាមស្រុក (ឆ្នាំ២០០៤)

| ឈ្មោះស្រុក | (គម²)<br>ផ្ទៃក្រឡាដី | (000)<br>ចំនួនប្រជាជន ២០០៤ | (នាក់/គម²)<br>ដង់ស៊ីតេប្រជាជន |
|---|---|---|---|
| សៀមរាប | ២៩២.៨ | ១២៦.៦ | ៤៣២.៥ |
| ប្រាសាទបាគង | ៣៤១.៩ | ៥៩.៥ | ១៧៣.៩ |
| សូត្រនិគម | ៦៧១.២ | ៩៧.៨ | ១៤៥.៧ |
| អង្គរជុំ | ៤១២.២ | ៥៤.៣ | ១៣១.៧ |
| ពួក | ៩៣៥.៥ | ១២១.៤ | ១២៩.៧ |
| ក្រឡាញ់ | ៤៨៨.៧ | ៥៨.៦ | ១១៩.៨ |
| អង្គរធំ | ៣០៧.៥ | ២១.០ | ៦៨.៣ |
| បន្ទាយស្រី | ៥១៧.១ | ៣៤.៥ | ៦៦.៧ |
| ស្រីស្នំ | ៤៧៩.៨ | ៣២.០ | ៦៦.៧ |
| ជីក្រែង | ២០៣៣.៩ | ១១៤.៧ | ៥៦.៤ |
| វ៉ារិន | ១៥៦៩.៨ | ២៤.១ | ១៥.៤ |
| ស្វាយលើ | ២២៤៨.៥ | ១៨.៩ | ៨.៤ |
| សរុប | ១០២៩៨.៩ | ៧៦៣.៣ | ៧៤.១ |

ប្រភព : ibid




ប្រភព : ទិន្នន័យមកពីប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់អាជ្ញាធរអប្សរា។ លទ្ធផលបឋម

រូបទី ៧២ : ទីតាំងនៃកន្លែងតាំងទីលំនៅថ្មី និងភូមិនានាក្នុងខេត្តសៀមរាប

ស្រុកសៀមរាប ដែលជាមជ្ឈមណ្ឌលក្រុងមានប្រជាជនច្រើនជាងគេ គឺ១២៧.០០០ នាក់ និងដង់ស៊ីតេខ្ពស់ជាងគេ គឺ៤៣២.៥ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ ២០០៤ បើធ្វើការប្រៀបធៀបជាមួយនឹងស្រុកផ្សេងៗទៀត ក្នុងខេត្ត (មើលតារាង ៣៤)។ ពួក ដែលជាស្រុកស្ថិតនៅភាគខាងលិចស្រុកសៀមរាបមានប្រជាជនច្រើនបន្ទាប់គឺ ១២១.០០០ នាក់។ តាមការសង្កេតបង្ហាញយ៉ាងច្បាស់ថា ប្រជាជនយ៉ាងច្រើនបានតាំងទីលំនៅក្នុងស្រុក នានាស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ ដូចជា ស្រុកប្រាសាទបាគង ស្រុកសូត្រនិគម ស្រុកពួក និងក្រឡាញ់។ ស្រុកអង្គរជុំ ដែលជាស្រុកមួយមានទិន្នផលស្រូវខ្ពស់ជាងគេក្នុងខេត្ត ប៉ុន្តែមិនស្ថិតនៅតាមផ្លូវជាតិលេខ៦ មានដង់ស៊ីតេប្រជាជនខ្ពស់បង្គួរគឺ ១៣១.៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

*ហេតុដូច្នេះ តំបន់តាំងទីលំនៅសំខាន់ៗ និងមជ្ឈមណ្ឌលភូមិត្រូវផ្តោតនៅតាមបណ្តោយផ្លូវជាតិលេខ៦។* ចំពោះស្រុកស្ថិតនៅភាគខាងជើង និងតំបន់ដីសើមភាគខាងត្បូងក្បែរបឹងទន្លេសាបមានដង់ស៊ីតេប្រជាជនទាប ដូច្នេះសកម្មភាពប្រកបមុខរបរកសិកម្មនៅមានកំរិត (មើលរូបទី ៧៣)។

## ២. រចនាសម្ព័ន្ធនៃកំណើនប្រជាជន

រហូតដល់ពេលថ្មីៗនេះ ស្រុកសៀមរាបមានការកើនឡើងនៃចំនួនប្រជាជនដោយសារនិន្នាការមួយយ៉ាងច្បាស់លាស់គឺការស្រូបយកប្រជាជនមកពីស្រុកនានាតាមបណ្តោយផ្លូវជាតិលេខ៦ ដូចមានបង្ហាញក្នុងតារាង៣៥។ ស្រុកសៀមរាបគឺជាស្រុកដែលមានកំណើនប្រជាជនច្រើនជាងគេបង្អស់។ ចំណែកស្រុកពួក និងស្រុកប្រាសាទបាគង ដែលស្ថិតនៅជិតស្រុកសៀមរាបក៏មានកំណើនប្រជាជនយ៉ាងច្រើនដែរ ហើយកំពុងក្លាយ ***ជាតំបន់តាំងទីលំនៅក្រុងថ្មី***។

ចំពោះស្រុកស្វាយលើ វ៉ារិន និងបន្ទាយស្រី គ្មានបុព្វហេតុច្បាស់លាស់ដែលនាំឱ្យមានកំណើនប្រជាជនច្រើនឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ចំណុចខាងក្រោមនេះគឺជាការពន្យល់ពីបុព្វហេតុនៃកំណើនប្រជាជនក្នុងស្រុកខាងលើ។

- ដីជាតិដីនៅតាមស្រុកជាប់នឹងជើងភ្នំប្រសើរជាងស្រុកនានានៅភាគខាងត្បូង និងជាការទាក់ទាញប្រជាកសិករកាន់តែច្រើនឡើង។
- អត្រាកំណើតខ្ពស់នៅក្នុងតំបន់ជនបទ ដោយសារកង្វះខាតផែនការគ្រួសារ/ផែនការពន្យាកំណើតកូន។
- មានអត្រាទាបនៃការបំលាស់ទីលំនៅចេញក្រៅស្រុក ដោយសារមួយផ្នែក កំរិតអប់រំទាប ហើយអាស្រ័យហេតុនេះពួកគេមានឱកាសតិចតួចក្នុងការរកការងារធ្វើបានក្នុងក្រុង ក្រៅពីកសិកម្ម។

**តារាង ៣៥ : ប្រជាជនតាមស្រុកក្នុងខេត្តសៀមរាបនៅឆ្នាំ២០០១ និងឆ្នាំ២០០៤**

| ឈ្មោះស្រុក | (000) ចំនួនប្រជាជន ២០០១ | (000) ចំនួនប្រជាជន ២០០៤ | (000 នាក់) កំនើន ២០០១-០៤ | កំនើនក្នុងប្រជាជនអចិន្ត្រៃយ៍ | កំនើនក្នុងប្រជាជនបណ្តោះអាសន្ន | % ចំណែកក្នុងកំណើន |
|---|---|---|---|---|---|---|
| សៀមរាប | ១១៧.៥ | ១២៦.៦ | ៩.១ | ៣.៣ | ៥.៨ | ២១.១% |
| ពួក | ១១៥.៨ | ១២១.៤ | ៥.៦ | ៥.៦ | ០.០ | ១២.៩% |
| ស្វាយលើ | ១៤.៤ | ១៨.៩ | ៤.៥ | ២.៧ | ១.៨ | ១០.៤% |
| ប្រាសាទបាគង | ៥៥.៤ | ៥៩.៥ | ៤.១ | ៤.០ | ០.១ | ៩.៥% |

| | | | | | | |
|---|---|---|---|---|---|---|
| វ៉ារិន | ២០.៣ | ២៤.១ | ៣.៨ | ៣.៦ | ០.២ | ៨.៩% |
| បន្ទាយស្រី | ៣០.៧ | ៣៤.៥ | ៣.៨ | ៣.៨ | ០.០ | ៨.៨% |
| ជីក្រែង | ១១១.៨ | ១១៤.៧ | ២.៩ | ៣.៣ | -០.៤ | ៦.៧% |
| អង្គរធំ | ១៨.៧ | ២១.០ | ២.៣ | ២.៤ | ០.០ | ៥.៤% |
| សូត្រនិគម | ៩៥.៥ | ៩៧.៨ | ២.៣ | ២.១ | ០.២ | ៥.២% |
| អង្គរជុំ | ៥២.១ | ៥៤.៣ | ២.២ | ២.២ | ០.០ | ៥.១% |
| ស្រីស្នំ | ៣០.៥ | ៣២.០ | ១.៤ | ១.៤ | ០.០ | ៣.៣% |
| ក្រឡាញ់ | ៥៧.៥ | ៥៨.៦ | ១.១ | ១.១ | ០.០ | ២.៤% |
| សរុប | ៧២០.១ | ៧៦៣.៣ | ៤៣.២ | ៣៥.៦ | ៧.៦ | ១០០.០% |

**ប្រភព : ទិន្នន័យពីសាលាខេត្ត**

រចនាសម្ព័ន្ធនៃកំណើនប្រជាជនក្នុងអំឡុងពេលពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៤ មានបង្ហាញក្នុងតារាង៣៥។ និន្នាការគួរឱ្យកត់សំគាល់បំផុតនោះគឺ ចំនួនប្រជាជនដែលបានកើនឡើងក្នុងស្រុកសៀមរាបចុះបញ្ជីជា "ប្រជាជនបណ្តោះអាសន្ន"។ ការនេះមួយផ្នែកដោយសារថា ប្រជាជនបំលាស់ទីចូលស្រុកគឺជាកម្មករសំណង់សណ្ឋាគារ និងផ្សារលក់ទំនិញធំៗ។ ចំពោះស្រុកស្វាយលើវិញ បុព្វហេតុដែលនាំឱ្យមានកំណើនប្រជាជនបណ្តោះអាសន្នច្រើនមិនបានបញ្ជាក់ឱ្យបានច្បាស់ឡើយ ។

## ៣. ការព្យាករណ៍ចំនួនប្រជាជន

ទិន្នន័យមួយចំនួនពី "ទិន្នន័យកែសំរួលលើកទី១ទាក់ទងនឹងការព្យាករណ៍ចំនួនប្រជាជនសំរាប់ប្រទេសកម្ពុជាឆ្នាំ ២០០១-២០២១ (*ការពិនិត្យរបាយការណ៍ដើមលើកទី៦នៃជំរឿនឆ្នាំ ១៩៩៨*)" ត្រូវបានសន្មតយកជាកំរិតមូលដ្ឋាននៃចំនួនប្រជាជនក្នុងក្របខ័ណ្ឌសកម្មភាពរបស់ក្រុមសិក្សា ដោយផ្អែកលើមូលហេតុដូចខាងក្រោម ។ ចំនួនប្រជាជននៅពេលអនាគតនឹងត្រូវកំណត់ដោយអត្រាកំណើនតាមធម្មជាតិ រចនាសម្ព័ន្ធអាយុ និងទំហំនៃការហូរចូលចេញរបស់ប្រជាជនទៅក្នុងខេត្តសៀមរាប ។ កត្តាទាំងអស់នេះនឹងត្រូវរាប់បញ្ចូលក្នុងការព្យាករណ៍ទាំងឡាយនាពេលថ្មីៗ។

ជាងនេះទៀត ការព្យាករណ៍លំអិតត្រូវបានធ្វើឡើងដោយការបែងចែកស្រុកក្នុងខេត្តយ៉ាងលំអិតដើម្បីធ្វើការឆ្លុះបញ្ចាំងពីលក្ខណៈភូមិសាស្ត្ររបស់ស្រុក ។ តាមការបែងចែកកំរិតថ្នាក់ស្រុកនេះ ក្រុមសិក្សាបានធ្វើការពិនិត្យរចនាសម្ព័ន្ធនៃទិន្នន័យប្រជាជនដែលបានពីជំរឿនឆ្នាំ១៩៩៨ និងទិន្នន័យសាលាខេត្តពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៤។

លទ្ធផលនៃការពិនិត្យទិន្នន័យមានបង្ហាញក្នុងតារាង៣៦ និង៣៧។

ការប៉ាន់ស្មានសំខាន់ៗដើម្បីកំណត់កំរិតនៃការព្យាករណ៍ត្រូវបានសង្ខេបជាចំណុចដូចខាងក្រោម :

- ចំនួនប្រជាជនសរុបក្នុងខេត្តសៀមរាបត្រូវបានកែសំរួលឱ្យស៊ីគ្នាទៅនឹងកំរិតនៃ "ការព្យាករណ៍ជំរឿន ដែលបានពីការកែសំរួល" ដែលមានចំនួន៩%ច្រើនជាងទិន្នន័យប្រជាជនដែលបានចុះបញ្ជី និងដែលបានបោះពុម្ពផ្សាយដោយសាលាខេត្ត។ យោងតាមរបាយការណ៍បច្ចេកទេសពីការព្យាករណ៍ដែលបានកែសំរួល ការខុសគ្នានេះមួយផ្នែកធំ ដោយសារការមិនរាប់បញ្ចូលក្នុងបញ្ជីនៃ " ចំនួនកុមារមានអាយុពី ០ ដល់ ៤ ឆ្នាំ "។

- ប្រជាជនក្នុងតំបន់ទី១ និងទី២ (តំបន់ការពារដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា) ត្រូវបានសន្មតថាគ្មានការកើនឡើងចាប់ពីឆ្នាំ២០០៤។ ស្រុកសៀមរាប អង្គរធំ បន្ទាយស្រី ប្រាសាទបាគង និងពួកមានប្រជាជនរស់នៅក្នុងតំបន់ទី១ និងតំបន់ទី២ ដែលមានចំនួនសរុប ១០៨.០០០ នាក់នៅឆ្នាំ២០០៤។
- ស្រុកសៀមរាបត្រូវបានសន្មតថានឹងមានចំនួនប្រជាជនច្រើនមករស់នៅ ដែលប្រជាជនទាំងនោះមកពីស្រុកផ្សេងៗក្នុងខេត្តនៅពេលអនាគត។ ការសន្មតដូចនេះបង្ហាញពីកំណើនប្រជាជនពី១៦.៦%នៅឆ្នាំ២០០៤ ដល់ ១៧.១% នៅឆ្នាំ២០២០។
- ស្រុកផ្សេងៗទៀតនៅក្នុងខេត្តត្រូវបានសន្មត់ថានឹងគ្មានការប្រែប្រួលរបាយប្រជាជនច្រើនចាប់ពីឆ្នាំ២០០៤។

ដូចមានបង្ហាញក្នុងតារាង ៣៦ ខេត្តសៀមរាបទាំងមូលត្រូវបានព្យាករណ៍ថានឹងមានអត្រាកំណើនប្រជាជនខ្ពស់ជាងកំរិតកំណើនជាមធ្យមនៅថ្នាក់ជាតិ។ ការនេះបញ្ជាក់ថា ខេត្តសៀមរាបមានចំនួនប្រជាជនផ្លាស់ចូលខេត្តថេរ ក្នុងអំឡុងពេលធ្វើផែនការ។ ក្នុងខេត្ត ការសន្មត់បានធ្វើឡើងដោយផ្អែកទៅលើនិន្នាការពីរផ្សេងគ្នា។ និន្នាការមួយគឺថា ការផ្លាស់ទីលំនៅចូលក្នុងស្រុកសៀមរាបកើតមានជាប្រចាំ។ កំណើននៃចំនួនប្រជាជននេះអាចធ្វើឱ្យមានការពង្រីកក្រុងក្នុងស្រុកជាបន្តបន្ទាប់ទៅកាន់តំបន់ជាយក្រុង។ ម្យ៉ាងវិញទៀត តំបន់នានាក្នុងតំបន់ហាមឃាត់ទី១ និងទី២ នឹងមានការផ្លាស់ទីលំនៅចេញ ដែលប្រជាជនទាំងនោះអាចទៅរស់នៅទីកន្លែងផ្សេងៗទៀតក្នុងខេត្ត (មើលរូបទី៧៤)។

**តារាង ៣៦ : ការព្យាករណ៍ចំនួនប្រជាជនតាមស្រុក**

| | ផ្ទៃក្រឡាដី (គម$^{២}$) | ២០០០ (ជា ០០០) | ២០១០ (ជា ០០០) | ២០២០ (ជា ០០០) | ការបែងចែក | អត្រាលូតលាស់ ២០០០-២០១០ | អត្រាលូតលាស់ ២០១០-២០២០ |
|---|---|---|---|---|---|---|---|
| ចំនួនសរុបក្នុងខេត្តសៀមរាប | ១០.២៩៩ | ៧៦៨ | ៩៧១ | ១.២២៩ | ១០០.០% | ២.៤% | ២.៤% |
| ចំនួនប្រជាជនសរុបក្នុងតំបន់១និង២ | - | ៩៨ | ១០៨ | ១០៨ | ៨.៨% | ១.០% | ០.០% |
| ចំនួនប្រជាជនមិនរាប់តំបន់១និង២ | - | ៦៧០ | ៨៦៣ | ១.១២១ | ៩១.២% | ២.៦% | ២.៧% |
| | | | | | | | |
| ស្រុកសៀមរាប | ២៩៣ | ១២៦ | ១៦២ | ២១១ | ១៧.១% | ២.៥% | ២.៧% |
| ស្រុកដទៃផ្សេងៗទៀត | ១០.០០៦ | ៦៤២ | ៨០៩ | ១.០១៩ | ៨២.៩% | ២.៣% | ២.៣% |
| អង្គរជុំ | ៤១២ | ៥៥ | ៧០ | ៩១ | ៧.៤% | ២.៥% | ២.៦% |
| អង្គរធំ | ៣០៨ | ២០ | ២៦ | ៣១ | ២.៥% | ២.៦ | ១.៨% |
| បន្ទាយស្រី | ៩១៧ | ៣៣ | ៤១ | ៤៧ | ៣.៨% | ២.២% | ១.៣% |
| ជីក្រែង | ២.០៣៤ | ១២០ | ១៤៨ | ១៩១ | ១៥.៦% | ២.១% | ២.៦% |
| ក្រឡាញ់ | ៤៨៩ | ៦៣ | ៧៦ | ៩៨ | ៧.៩% | ១.៩% | ២.៦% |
| ប្រាសាទបាគង | ៣៤២ | ៥៩ | ៧៣ | ៨៧ | ៧.១% | ២.២% | ១.៨% |
| ពួក | ៩៣៦ | ១២៣ | ១៥១ | ១៨៦ | ១៥.១% | ២.១% | ២.១% |
| សូត្រនិគម | ៦៧១ | ១០១ | ១២៧ | ១៦៣ | ១៣.៣% | ២.២% | ២.៦% |
| ស្រីស្នំ | ៤៨០ | ៣២ | ៤១ | ៥៣ | ៤.៣% | ២.៥% | ២.៦% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ស្វាយលើ | ២.២៤៩ | ១៥ | ២៤ | ៣២ | ២.៦% | ៥.៣% | ២.៦% |
| វ៉ារិន<br>សំរាប់ឯកសារពិគ្រោះ | ១.៩៧០ | ២១ | ៣១ | ៤០ | ៣.៣% | ៣.៩% | ២.៦% |
| កម្ពុជា | ១៧៨.០៣៥ | ១២.៩៧៤ | ១៥.២៦៩ | ១៨.៧២៤ | - | ២.០% | ២.១% |
| ភ្នំពេញ | ២៩០ | ១.១១៤ | ១.៥២៩ | ១.៩៨៣ | - | ៣.២% | ២.៦% |
| កម្ពុជាមិនរាប់បញ្ចូលភ្នំពេញ | ១៧៧.៧៤៥ | ១១.៨៥៩ | ១៣.៧៣៩ | ១៦.៧៤១ | - | ១.៨% | ២.០% |
| ក្រុងព្រះសីហនុ | ៨៦៨ | ១៧៦ | ២៤៧ | ៣៣៥ | - | ៣.៥% | ៣.១% |
| បាត់ដំបង | ១១.៧០២ | ៩១៦ | ១.១០១ | ១.៣៥៨ | - | ១.៩% | ២.១% |

**ប្រភព: "ការកែសំរួលទិន្នន័យលើកទី ១ ទាក់ទងនឹងការព្យាករណ៍ចំនួនប្រជាជនសំរាប់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨-២០២០ នៅខែមិថុនា ឆ្នាំ ២០០៤" និងការវិភាគរចនាសម្ព័ន្ធដោយក្រុមសិក្សាដោយផ្អែកលើទិន្នន័យពីសាលាខេត្ត ។**

ដោយផ្អែកលើការព្យាករណ៍ចំនួនប្រជាជននេះ ការសិក្សាបានធ្វើការសន្មត់ចំនួនប្រជាជនក្នុងស្រុកសៀមរាប ដូចខាងក្រោម ។

**តារាង ៣៧ : ចំនួនប្រជាជនក្នុងស្រុកសៀមរាប**

| ឆ្នាំ | 2000 | 2004 | 2012 | 2020 |
|---|---|---|---|---|
| | ជាក់ស្តែង | ព្យាករណ៍ | | |
| ចំនួនប្រជាជនក្នុងស្រុកសៀមរាប | ១២៦.៦ | ១៣៩.៦ | ១៧០.៧ | ២១០.៦ |

ឯកតា: ពាន់នាក់

**ប្រភព : ក្រុមសិក្សា JICA**




**រូបទី ៧៣ : កំណើនប្រជាជននៅស្រុកសៀមរាប**

## ១១.១.២ ការងារ

កំរិតការងារនៅពេលអនាគតក្នុងស្រុកសៀមរាប និងស្រុកផ្សេងៗទៀតត្រូវបានប៉ាន់ស្មានដោយផ្អែកលើចំណុចរួមរបស់តំបន់ក្នុងខេត្តទាំងមូល ។ តាមការប៉ាន់ស្មានឱ្យដឹងថានឹងមានកំណើនកំលាំងពលកម្មពី ៨.០០០ ទៅ ៨.៥០០ ក្នុងមួយឆ្នាំៗ ។ កំណើនការងារសរុបនឹងមានរហូតដល់ ១៨០.០០០ ក្នុងអំឡុងពេលរវាងពីឆ្នាំ២០០០ និងឆ្នាំ២០២០ ។

ការប៉ាន់ស្មានការងារតាមវិស័យមានបង្ហាញក្នុងរូបទី៧៣។ ចំពោះវិស័យទី១ រចនាសម្ព័ន្ធបច្ចុប្បន្ននៃទំរង់បែងចែកការងារនៅតាមស្រុកនានាត្រូវបានសន្មតថានឹងមានកំរិតប្រហាក់ប្រហែលគ្នានឹងពេលបច្ចុប្បន្ននៅឆ្នាំ២០២០។

ចំណែកវិស័យទី២ និងទី៣ ការប៉ាន់ស្មានឱ្យដឹងថានឹងមានតំរូវការកំលាំងពលកម្មកើនឡើង។ ជាពិសេស វិស័យទី៣ នឹងបង្កើតឱ្យមានការងារចំនួន៥៦.០០០ ឬប្រហែលជាពាក់កណ្តាលនៃកំណើនការងារសរុប។ ស្រុកសៀមរាបដែលជាមណ្ឌលឧស្សាហកម្មទេសចរណ៍នឹងមានប្រជាជន ១០០.០០០ នាក់ ឬស្ទើរតែស្មើនឹង៦០%នៃការងារក្នុង វិស័យទី៣ ក្នុងខេត្តនៅឆ្នាំ២០២០។

កំរិតការងារតាមវិស័យផ្សេងៗក្រៅពីកសិកម្មត្រូវបានប៉ាន់ស្មានដោយផ្អែកលើ "មូលដ្ឋានទីកន្លែងការងារ" ពុំមែនផ្អែកលើ "មូលដ្ឋាននៃការតាំងទីលំនៅ" ឡើយ។ ដូចនេះ ក្រុមសិក្សាទទួលបានព័ត៌មានអំពីគំលាតរវាងប្រជាជនមានការងារធ្វើដោយផ្អែកលើមូលដ្ឋាន "កន្លែងការងារ" និង "លំនៅដ្ឋាន" តាមរយៈភាពខុសគ្នារវាងចំនួនប្រជាជន "ពេលថ្ងៃ" និង "ពេលយប់"។ ដូចមានបង្ហាញក្នុងតារាង៣៨ ការប៉ាន់ស្មានបង្ហាញថានឹងមានប្រជាជនប្រមាណជា ៦៥.០០០ នាក់គឺជាអ្នកធ្វើដំណើរពីស្រុកក្បែរស្រុកសៀមរាបចូលមកស្រុកសៀមរាបនៅឆ្នាំ ២០២០។

**តារាង ៣៨ : ការគណនាបឋមអំពីរចនាសម្ព័ន្ធការងារក្នុងខេត្ត និងស្រុកសៀមរាប**

## ១. ខេត្តសៀមរាប

| ការងារតាមវិស័យ | (000 នាក់) | | | ចំណែកតាមវិស័យ % | | | ការប្រែប្រួលប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|---|---|
| | 2000 | 2010 | 2020 | 2000 | 2010 | 2020 | 2000/2010 | 2010/2020 |
| 100 វិស័យទី១ សរុប | 324.8 | 356.0 | 356.0 | 77.2% | 68.4% | 59.1% | 0.9% | 0.0% |
| 200 វិស័យទី២ សរុប | 27.3 | 46.7 | 71.2 | 6.5% | 9.0% | 11.8% | 5.5% | 4.3% |
| 300 វិស័យទី៣ សរុប | 68.9 | 117.6 | 175.2 | 16.4% | 22.6% | 29.1% | 5.5% | 4.1% |
| 301 ជំនួញលក់ដុំ និងរាយ និងជួសជុលម៉ាស៊ីន | 40.3 | 69.0 | 105.2 | 9.6% | 13.3% | 17.5% | 5.5% | 4.3% |
| 302 សណ្ឋាគារ និងភោជនីយដ្ឋាន | 2.4 | 9.2 | 16.2 | 0.6% | 1.8% | 2.7% | 14.2% | 5.8% |
| 303 ការដឹកជញ្ជូន ការស្តុក និងទំនាក់ទំនង | 4.6 | 7.8 | 11.9 | 1.1% | 1.5% | 2.0% | 5.5% | 4.3% |
| 304 អន្តរកម្មហិរញ្ញវត្ថុ | 0.1 | 0.1 | 0.2 | 0.0% | 0.0% | 0.0% | 5.5% | 4.3% |
| 305 រដ្ឋបាលសាធារណៈ និងការការពារ | 10.1 | 12.0 | 12.0 | 2.4% | 2.3% | 2.0% | 1.7% | 0.0% |
| 306 អចលនទ្រព្យ សកម្មភាពជួល និងអាជីវកម្ម | 0.6 | 1.0 | 1.6 | 0.1% | 0.2% | 0.3% | 5.5% | 4.3% |
| 307 សេវាកម្មផ្សេងៗទៀត | 10.8 | 18.5 | 28.2 | 2.6% | 3.6% | 4.7% | 5.5% | 4.3% |
| អ្នកធ្វើការសរុបនៅកន្លែងធ្វើការ | 420.9 | 520.3 | 602.4 | 100.0% | 100.0% | 100.0% | 2.1% | 1.5% |
| ប្រជាជនសរុប | 767.8 | 970.7 | 1229.4 | ការងារ/ប្រជាជន | | | 2.4% | 2.4% |
| កម្លាំងការងារសរុបដែលបំពេញការងារនៅក្នុងលំនៅដ្ឋាន | 420.9 | 520.3 | 602.4 | 55% | 54% | 49% | 2.1% | 1.5% |
| ចំនួនប្រជាជនដើរដែលធ្វើដំណើរមកធ្វើការងារក្នុងស្រុកសៀមរាប | - | - | - | - | - | - | - | - |

## ២. ស្រុកសៀមរាប

| ការងារតាមវិស័យ | (000 នាក់) | | | ចំណែកតាមវិស័យ % | | | ការប្រែប្រួលប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|---|---|
| | 2000 | 2010 | 2020 | 2000 | 2010 | 2020 | 2000/2010 | 2010/2020 |
| 100 វិស័យទី១ សរុប | 24.1 | 26.3 | 26.3 | 32.0% | 22.5% | 16.0% | 0.9% | 0.0% |
| 200 វិស័យទី២ សរុប | 13.5 | 23.2 | 35.4 | 18.0% | 19.9% | 21.5% | 5.5% | 4.3% |
| 300 វិស័យទី៣ សរុប | 37.6 | 67.3 | 102.5 | 49.9% | 57.6% | 62.4% | 6.0% | 4.3% |
| 301 ជំនួញលក់រាយ ដុំនិង ការជួសជុលម៉ាស៊ីន | 23.4 | 40.0 | 61.0 | 31.1% | 34.3% | 37.2% | 5.5% | 4.3% |
| 302 សណ្ឋាគារ និងភោជនីយដ្ឋាន | 2.2 | 8.7 | 15.2 | 3.0% | 7.4% | 9.3% | 14.5% | 5.8% |
| 303 ការដឹកជញ្ជូន ការស្តុក និងទំនាក់ទំនង | 3.2 | 5.5 | 8.3 | 4.2% | 4.7% | 5.1% | 5.5% | 4.3% |
| 304 អន្តរកម្មហិរញ្ញវត្ថុ | 0.1 | 0.1 | 0.2 | 0.1% | 0.1% | 0.1% | 5.5% | 4.3% |
| 305 រដ្ឋបាលសាធារណៈ និងការការពារ | 3.5 | 4.1 | 4.1 | 4.6% | 3.5% | 2.5% | 1.7% | 0.0% |
| 306 អចលនទ្រព្យ សកម្មភាពជួល និងជំនួញ | 0.5 | 0.8 | 1.2 | 0.6% | 0.7% | 0.7% | 5.5% | 4.3% |
| 307 សេវាកម្មផ្សេងៗទៀត | 4.8 | 8.2 | 12.5 | 6.4% | 7.0% | 7.6% | 5.5% | 4.3% |
| អ្នកធ្វើការសរុបនៅកន្លែងធ្វើការ | 75.2 | 116.8 | 164.2 | 100.0% | 100.0% | 100.0% | 4.5% | 3.5% |
| ប្រជាជនសរុប | 126.0 | 161.9 | 210.6 | ការងារ/ប្រជាជន | | | 2.5% | 2.7% |
| កម្លាំងការងារសរុបដែលបំពេញការងារនៅក្នុងលំនៅដ្ឋាន | 66.8 | 82.6 | 99.0 | 53% | 51% | 47% | 2.1% | 1.8% |
| ចំនួនប្រជាជនដើរដែលធ្វើដំណើរមកធ្វើការងារក្នុងស្រុកសៀមរាប | 8.4 | 34.2 | 65.2 | - | - | - | 15.1% | 6.7% |

**ប្រភព : ការគណនាសាកល្បងលើកទី១ របស់ក្រុមសិក្សា**